# សម្លេងនៃទីសម្គាល់

កំពុងនៅឈរពីរបីនាទីក្នុងព្រះវត្តមានព្រះអម្ចាស់។ សូមឲ្យយើងអានពីព្រះបន្ទូល ព្រះអង្គក្នុងគម្ពីរនិក្ខមនំ ជំពូក៤។

*...តែម៉ូសេប្រកែកថា មើល គេនឹងមិនជឿទូលបង្គំ ឬស្តាប់តាមទូលបង្គំទេ: គេនឹងថា ព្រះយេហូវ៉ាទ្រង់មិនបានលេចមកឯអ្នកទេ។*

*នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលតបថា តើមានអ្វីនៅដៃឯងនោះ?...លោកទូលឆ្លើយថា មានដំបង។ រួចទ្រង់ប្រាប់ថា ចូរបោះទៅដីទៅ។ លោកក៏បោះទៅ។*

*តែព្រះយេហូវ៉ាទ្រង់បង្គាប់ថា ចូរលូកដៃទៅចាប់ត្រង់កន្ទុយវា លោកក៏លូកដៃទៅចាប់ រួចពស់នោះត្រឡប់ទៅជាដំបងនៅដៃលោកវិញ:*

*នេះគឺដើម្បីឲ្យគេជឿថា ព្រះយេហូវ៉ាដ៏ជាព្រះនៃពួកឰយុកោ ជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប ទ្រង់បានលេចមកឯឯង។*

*ព្រះយេហូវ៉ាទ្រង់បង្គាប់ទៀតថា ចូរឯងដាក់ដៃចូលទៅលើទ្រូងឥឡូវចុះ លោកក៏ដាក់ដៃចូលទៅ រួចដកមកញឃើញមានកើតឃ្លង់សដូចហិមៈ។*

*រួចទ្រង់ប្រាប់ថា ចូរដាក់ដៃចូលទៅលើទ្រូងម្តងទៀត លោកក៏ដាក់ចូលទៅ រួចដកចេញមក ហើយមើល ដៃបានត្រឡប់ទៅដូចជាធម្មតាដើមវិញ។*

*ទ្រង់មានព្រះបន្ទូលថា បើគេមិនជឿឯង ហើយមិនស្តាប់តាមទីសំគាល់មុន នោះគេនឹងជឿដោយសារទីសម្គាល់ក្រោយនេះដែរ។*

*តែបើគេមិនជឿដោយសារទីសម្គាល់ទាំង២នេះទេ ហើយមិនព្រមស្តាប់តាមឯងផង នោះត្រូវឲ្យយកទឹកទន្លេមកចាក់លើដីគោក រួចទឹកដែលឯងយកពីទន្លេមក នោះនឹងត្រឡប់ទៅជាឈាមនៅ...លើដីវិញ។*

2 ចូរយើងឱនក្បាលអធិស្ឋាន។ ឥឡូវអ្នកមានសំណើរសូមអីទេនៅល្ងាចនេះ ដើម្បីទូលដល់ព្រះអម្ចាស់ជ្រាប សូមលើកដៃរបស់អ្នក និងនិយាយ "ព្រះអម្ចាស់ សូមនឹកចាំពីទូលបង្គំឥឡូវនេះ។ ទូលបង្គំកំពុងត្រូវការ។"

3 ព្រះវរបិតាដែលនៅស្ថានសួគ៌ទូលបង្គំកំពុងចូលរកទ្រង់ម្តងទៀតនៅល្ងាចនេះ សូមព្រះអង្គជ្រាបពីការដែលទូលបង្គំឱនក្បាលចំពោះសេចក្តីគគ្រិចតាំងតែពីទូលបង្គំបានចូលមក ហើយបើទ្រង់នៅឆោ ទូលបង្គំនឹងត្រឡប់ទៅជាដីវិញ។ ប៉ុន្តែដោយសារសេចក្តីសង្ឃឹមដ៏មានព្រះពរនៃសេចក្តីសន្យាដែលមាននៅក្នុងព្រះគ្រិស្តគឺ អស់អ្នកណាដែលនៅក្នុងព្រះជាម្ចាស់ និងមានព្រះគ្រិស្តជាមួយដែរ។ ទូលបង្គំ—ទូលបង្គំអរព្រះគុណសម្រាប់សេចក្តីសន្យាដែលមានសិរីរុងរឿងនេះ។ ហើយទូលបង្គំអធិស្ឋាន ព្រះអម្ចាស់ ដែលព្រះអង្គនឹងចាំពីរឿងនីមួយៗដែលមាននៅក្នុងដៃរបស់ពួកគេ ទាំងដៃរបស់ទូលបង្គំផងដែរ ព្រះអម្ចាស់។

4 ទូលបង្គំកំពុងអធិស្ឋាននៅយប់នេះ នៅក្នុងការបញ្ចប់នៃជំនឿក្នុងម៉ោងនេះ ដែលព្រះអង្គនឹងប្រទានជំនឿដល់មនុស្សនៅយប់នេះ ដែលព្រះអម្ចាស់យេស៊ូនឹងក្លាយជាការពិតក្នុងជីវិតរបស់ពួកយើងខ្ញុំម្នាក់ៗ ដែលពួកគេនឹងមិននៅជាមនុស្សខ្សោយទៀតឡើយក្នុងចំណោមទូលបង្គំយើងខ្ញុំនៅក្នុងយប់នេះ។ សូមឲ្យអ្នកមានបាបដឹងថាខ្លួនកំពុងនៅក្នុងព្រះវត្តមាននៃព្រះអម្ចាស់យេស៊ូ ហើយគាត់នឹងប្រែចិត្តពីបាបរបស់ខ្លួន ហើយថ្វាយចិត្តដល់ព្រះអង្គ ហើយនឹងបំពេញដោយព្រះវិញ្ញាណនៅក្នុងម៉ោងវេលាដែលអាក្រក់នេះ ដូចដែលទូលបង្គំបានឃើញស្រមោលយ៉ាងធំបានលូនចូលផែនដី។

5 ទូលបង្គំយើងខ្ញុំអធិស្ឋាន ទៅកាន់ព្រះជាម្ចាស់ សម្រាប់ការដឹកនាំមកពីព្រះ នៅយប់នេះ សម្រាប់ទាំងការអធិប្បាយ និងការស្តាប់ផងដែរ។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធបានគ្រប់គ្រងការប្រជុំគ្នាឥឡូវនេះ និងសូមបំបែកនំប៉័ងជីវិតមកកាន់ទូលបង្គំម្នាក់ៗដែលទូលបង្គំត្រូវការ ហើយសូមអធិស្ឋានដោយព្រះនាមរបស់ទ្រង់។ អាម៉ែន។

សូមអង្គុយចុះ។

6 ខ្ញុំជឿជាក់ថានៅយប់នេះ យើងនឹងអាចសម្រេចនូវអ្វីដែលយើងព្យាយាមចង់ឲ្យមនុស្សបានឃើញ—ការពិតនៃជំនឿក្នុងព្រះជាម្ចាស់។

7 ឥឡូវនេះ រសៀលថ្ងៃស្អែកម៉ោងពីរ-កន្លះ អ្នកដែលមានកាតអធិស្ឋានដែលយើងនឹងអធិស្ឋានឲ្យ។ ហើយសូមពិនិត្យឲ្យច្បាស់ថា នឹងទទួលបានកាតមុននឹងចាកចេញទៅ យប់នីមួយៗយើងនឹងចែកកាតជូន។ ហើយខ្ញុំនឹងចែកម្តងទៀតនៅថ្ងៃស្អែក ប៉ុន្តែ...ខ្ញុំប្រហែលជាចាប់ផ្តើមម៉ោងមួយ-កន្លះ ឬប្រហែលនោះ គឺមុនការជួបជុំគ្នាចាប់ផ្តើម។ ហើយអស់អ្នកដែលចង់ទទួលបានការអធិស្ឋាន សម្រាប់អ្នកជាទីស្រឡាញ់ណាម្នាក់ សូមឲ្យពួកគេចូលមកដើម្បីទទួលកាតអធិស្ឋាន។ ពួកគេពិតជា—ទទួលការស្វាគមន៍ក្នុងការទទួលបានកាត។ ហើយយើងនឹង...

8 ខ្ញុំនឹងអធិស្ឋានសម្រាប់មនុស្ស ដោយដាក់ដៃលើគេ ហើយសូមអធិស្ឋានសម្រាប់គេ។ ឥឡូវបើសិនជាជំនឿរបស់អ្នកមិនបានងើបឡើងនៅក្នុងព្រះវត្តមានព្រះអម្ចាស់យេស៊ូគ្រិស្ត និងទទួលព្រះអង្គជាអង្គប្រោសឲ្យជាទេ ហើយអ្នកជឿថាបើយើងអធិស្ឋាន និងដាក់ដៃលើអ្នក ដែលនឹងអាចជួយអ្នកបាន ពិតមែនហើយពួកយើងនៅទីនេះដើម្បីធ្វើអ្វីដែលអ្នកប្រាថ្នាចង់បាន។

9 ហេតុផលដែលខ្ញុំពន្យាពេលឲ្យយឺត យូរ ដើម្បីមើលឃើញថាគ្រប់គ្នាដែលខ្ញុំអាច ដែលអាចឈោងចាប់ និងឱ្យព្រះជាម្ចាស់ធ្វើការនោះ។ ហើយយើងមិនមានមនុស្សច្រើនពេកទេ។ មាន...អាគារនេះមិនធំទេ ដូច្នេះយើងមិនអាចយកមនុស្សបានច្រើនពេកនោះទេ។ យើងអាចទទួលយកនៅរសៀលថ្ងៃស្អែក សម្រាប់គោលបំណងនោះ គឺអធិស្ឋានសម្រាប់អ្នកជំងឺ។

10 ហើយ យើងនៅទីនេះនឹងធ្វើអ្វីដែលអាចជួយជីវិតដែលមានភាពល្អប្រសើរឡើងខ្លះសម្រាប់អ្នក សម្រាលបន្ទុក នៅក្នុងដំណើរដែលយើងឆ្លងកាត់។

11 ហើយទោះបីពេលណាក៏ដោយ ដែលនរណាម្នាក់មានអារម្មណ៍ថា—ថាគេចង់ចូលមកក្នុងព្រះអម្ចាស់យេស៊ូ មិនថាការបម្រើតាម ផ្នែកណាមួយកំពុងតែដំណើរការ អ្នកសូមចូលមកចុះ។ កុំរង់ចាំរហូតដល់ការហៅមកខាងលើវេទិកាអាសនាខាងមុខនេះឡើយ។ កុំរង់ចាំរហូតដល់គេអញ្ជើញ។ អ្នកមកទទួលព្រះគ្រិស្តតែម្តង ហើយចូលមក និងសារភាពនៅចំពោះព្រះអង្គតែម្តង។ ព្រោះនេះជាគោលបំណងដែលយើងខ្ញុំមកទីនេះ គឺដើម្បីឃើញព្រលឹងជាច្រើនបានកើតនៅក្នុងនរគព្រះជាម្ចាស់។

12 ហើយឥឡូវ ថ្ងៃស្អែកជាថ្ងៃអាទិត្យ នឹងមានថ្នាក់រៀនថ្ងៃអាទិត្យ របស់ក្រុមជំនុំ។ ហេតុផលដែលយើងមានកម្មវិធីនៅពេលរសៀល នៅថ្ងៃអាទិត្យ ធ្វើដូច្នេះយើងនឹង

មិនកាត់កម្មវិធីឡើយ។ យើងខ្ញុំជឿថាគ្រប់គ្រិស្តបរិស័ទត្រូវមានក្រុមជំនុំ—តាមផ្ទះដែលត្រូវទៅ។ គ្រិស្តបរិស័ទត្រូវមានការជួបជុំគ្នាកន្លែងណាមួយជាមួយអ្នកជឿ។ ហើយកន្លែងណាដែលអ្នកជួបជុំគ្នានោះហើយហៅថាព្រះវិហារ។

13 ឥឡូវ បើសិនជាខ្ញុំរស់នៅទីនេះ ខ្ញុំអាចជាកម្មសិទ្ធិនៃព្រះវិហារណាមួយនៅទីនេះ ដែលមានគ្រូគង្វាលនៅទីនេះ នោះគឺជាការសហការគ្នា ជាតំណាង។ ហេតុអ្វី? ព្រោះពួកគេអង្គុយនៅវេទិការទីនេះ ដើម្បីមើលទៅកាន់មនុស្សគ្រប់គ្នាបានគាំទ្រឲ្យមានអ្វីកើតឡើង។ ពួកគេជឿថាអ្វីដែលកើតឡើងនៅក្នុងពន្ធ័កិច្ចនេះ ការប្រោសឲ្យជាមកពីព្រះជាម្ចាស់ ការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ និងអ្វីៗទៀត។ ពួកគេនៅទីនេះដើម្បីជាទីបន្ទាល់សម្រាប់ការនេះ។ ពួកគេជាអ្នកអញ្ជើញខ្ញុំមកទីនេះ ដែលជាព័ន្ធកិច្ចដែលព្រះអម្ចាស់ប្រទានមកឲ្យយើងអាចជួយដល់ពួកជំនុំនៅទីនេះបាន។

14 ឥឡូវ នេះជាគ្រូគង្វាលពិត ដែលសម្លឹងមើលអ្វីជាប្រយោជន៍ខាងវិញ្ញាណដែលគាត់អាច ពីអ្វីដែលព្រះជាម្ចាស់កំពុងធ្វើ ដែលគាត់ព្យាយាមអ្វីដែលល្អបំផុតរបស់គាត់ដើម្បីជួយក្រុមជំនុំរបស់គាត់ក្នុងចលនាទៅមុខសម្រាប់ព្រះជាម្ចាស់។ ខ្ញុំសូមដោះមួកដើម្បីជាការសរសើរ សម្រាប់គ្រូគង្វាលបែបនេះ។

15 ហើយ មនុស្សទាំងនេះបានធ្វើអ្វីដែលស្ថិតក្នុងភាពលំបាក ផងដែរ។ អ្នកអាចជឿបានថាវាជាការពិត។ ពួកគាត់ត្រូវធ្វើអ្វីស្ថិតក្នុងភាពលំបាក។ ហើយខ្ញុំ—ខ្ញុំសូមសម្តែងការដឹងគុណសម្រាប់មនុស្សដែលសំខាន់នេះរបស់ព្រះជាម្ចាស់ ជាអ្នកដែលចាប់យកកន្លែង និងតួនាទីរបស់គាត់តាមការកាត់សេចក្តីបង្ហាញក្នុងចិត្តនិង—និងជឿ។ ព្រះជាម្ចាស់នឹងប្រទានពរពួកគាត់ជានិច្ច!

16 ហើយខ្ញុំជឿថាពួកគាត់នឹងធ្វើអ្វីល្អសម្រាប់អ្នកទាំងអស់គ្នា។ ឥឡូវបើសិនជាអ្នកជាជនចម្លែកនៅទីនេះ ចូរស្វែងរកថាតើបងប្អូនប្រុសៗទាំងនេះមានព្រះវិហារនៅឯណា តើពួកគេនៅឯណា។ ទៅជួបពួកគេនៅថ្ងៃស្អែក។ ពួកគេមានកម្មវិធីពិសេសៗ ហើយមានអ្នកដឹកនាំជាច្រើន នឹងអធិប្បាយមកពីក្រុមជំនុំខុសៗគ្នាហើយ ពេលដែលត្រូវបានប្រកាស។ ហើយសូមទៅជួបពួកគេនៅថ្ងៃស្អែក។

17 ហើយនៅរសៀលថ្ងៃស្អែក បើអ្នកចង់មកចូលរួមកម្មវិធីបញ្ចប់ យើងខ្ញុំរីករាយនឹងការចូលរួមនេះ។ គ្រប់ទាំងក្រុមជំនុំ គ្រប់ទាំងនិកាយ គឺសម្រាប់គ្រប់គ្នា។ គ្រប់គ្នាត្រូវបានស្វាគមន៍ មេតូឌីស្ត បាបទីស្ត ព្រីសប៊ីធីរៀន ពេនទីកុស្ត ព្រះវិហារ

សម្រាប់ព្រះគ្រិស្ត ព្រះវិហារសម្រាប់ព្រះជាម្ចាស់ កាតូលិក អរតូដុកយូដា ពួកអ្នកមិនជឿលើសាសនា អ្នកនៅឯណាក៏ដោយ។ យើង...អ្នកត្រូវបានអញ្ជើញឲ្យចូលរួមបាន។

"អ្នកនិយាយ 'ពួកអ្នកមិនជឿព្រះឬ'?" ហ្នឹងហើយ។

18 បើសិនជាពួកអ្នកមិនជឿព្រះនឹងចូលរួមក្នុងការប្រជុំ និង អង្គុយចុះហើយសម្រួលឥរិយាបថ ពួកគាត់ក៏ត្រូវបានស្វាគមន៍ដូចអ្នកផ្សេងទៀតដែរ។ ត្រឹមត្រូវណាស់។ ជាអ្វីមួយ ដែលយើងចង់បានគាត់មកអង្គុយនៅទីនេះដែរ វានឹងអាចជួយឲ្យគាត់មើលឃើញពីកំហុសរបស់ពួកគាត់ និង ចូលមកក្នុងព្រះអម្ចាស់វិញ។ ព្រោះយើង...ជាការពិត។

19 តើប៉ុន្មាននាក់ដែលធ្លាប់អាននិមិត្តតូចមួយពីទស្សនាវដ្ដី ក្រុមធុរៈកិច្ចគ្រិស្តបរិស័ទបានចុះផ្សាយ ខ្ញុំជឿជាក់ថាមានទស្សនាវដ្ដីពីរទៅបីទៀត ទស្ស-...នៃ *ក្រលេកមើល វាំងននពេលវេលាអតីតកាល*? ឥឡូវពិតណាស់ មិត្តអើយ។ អ្នកមិនអាចភ្លេចវាបានទេ។ ខ្ញុំ—ខ្ញុំ បានក្លាយជាមនុស្សម្នាក់ផ្សេងបន្ទាប់ពីអានមក។ ខ្ញុំដឹងថាវាជាការពិត ដូច្នេះខ្ញុំ—ខ្ញុំ—ខ្ញុំជឿជាក់ថាគ្មាននរណាម្នាក់នៃអ្នករាល់គ្នាខកខានស្ថានសួគ៌ដ៏អស្ចារ្យដែលព្រះជាម្ចាស់បម្រុងសម្រាប់អ្នកជឿទេ។ បើសិនជាអ្នកធ្វើដូច្នេះ តើអ្នកបានធ្វើអ្វីសម្រេចនៅផែនដីនេះ? ព្រោះអ្នកមិនដឹងថា អ្នកនឹងចាកចេញពីផែនដីនេះពេលណាឡើយ។ ប៉ុន្តែអ្នកអាចដឹងរឿងមួយ គឺអ្នកពិតជាចាកចេញទៅ។ ហើយនោះជាការពិត បើដូច្នេះយើងនឹងក្លាយជាមនុស្សល្ងង់ក្នុងការព្យាយាម—ទទួលយកគ្រាន់តែជា...យើងមិនអាចរៀបចំឱកាសទេ។ ឃើញទេ សូមចងចាំ សូមជឿដល់ព្រះបន្ទូលព្រះជាម្ចាស់ និង សេចក្តីសន្យាគ្រប់យ៉ាងនោះក្នុងនោះ។

20 សូមគិតអ្វីដែលបង្ករឲ្យមានជំងឺគ្រប់យ៉ាង ជំងឺបេះដូង ការស្លាប់ បញ្ហាគ្រប់យ៉ាង ទុក្ខសោកគ្រប់យ៉ាង ក្មេងរឹងរូស ទាំងនេះជាភាពខ្ទិន ខ្វាក់ គ្រប់មន្ទីរពេទ្យត្រូវបានសង់ឡើង? ព្រោះដោយសារតែមនុស្សម្នាក់មិនស្តាប់បង្គាប់ផ្នែកតូចមួយនៃព្រះបន្ទូល។ នោះជាអេវ៉ា។ សាតាំងគ្រាន់តែលាបទៅលើនាង។ មិនមែន ដកស្រង់ពាក្យមកទេ គឺគ្រាន់តែលាបពាក្យលើនាង និយាយថា "ពិតមែនឬ...ព្រះអម្ចាស់ល្អពេកហើយ។"

21 អ្នកលឺច្រើនណាស់បច្ចុប្បន្នពីភាពជាព្រះ ព្រះជាម្ចាស់ជាព្រះដែលល្អ។ ព្រះអង្គជាព្រះល្អ ប៉ុន្តែសូមចងចាំព្រះអង្គជាព្រះនៃភាពបរិសុទ្ធ ជាព្រះដែលមិនមើលរំលងបាប។ ការដាក់ទោសត្រូវបានសងថ្លៃ ហើយអ្នកត្រូវតែទទួលវាតាមរបៀបរបស់ព្រះអង្គ។ ហើយសូមចងចាំ ព្រះអង្គក៏ជាព្រះនៃសេចក្តីក្រោធ ជាព្រះនៃសេចក្តីខ្ញាល់។ ហើយអ្នកឈរនៅពីមុខព្រះដែលមានសេចក្តីខ្ញាល់ មិនមែនត្រឹមតែព្រះជាម្ចាស់នៃសេចក្តីល្អ និងសេចក្តីសណ្តោសប្រណី។ យប់នេះព្រះអង្គជាព្រះសង្គ្រោះនៃយើង នៅថ្ងៃនោះព្រះអង្គជាចៅក្រមនៃយើងវិញ។

22 ដូច្នេះសូមអ្នកឲ្យប្រាកដថា អ្នកបន្សល់ទុកអ្វីមួយដែលមិនបានធ្វើ មិត្តអើយ។ វា—វាមិន…វាមិនត្រូវបង់ថ្លៃឡើយ។ កុំ—កុំចេះតែទៅដោយចៃដន្យ។ សូមឲ្យប្រាកដ ប្រាកដទ្វេដង ព្រោះអ្នកគ្មានឱកាសអ្វីផ្សេងទៀតដែរ។ នេះជាឱកាសតែមួយគត់របស់អ្នក កាលបើអ្នកកំពុងនៅលើផែនដីនេះ។

23 សូមចងចាំពីបុរសអ្នកមាន និងឡាសា មានឈូងលំហាយ៉ាងធំមួយរវាងអ្នក និងគាត់ ដែលគ្មានមនុស្សណាអាចនឹងឆ្លងបាន ឬអាចឆ្លងកាត់បានឡើយ។ ឃើញទេ? ពេលអ្នក—អ្នកស្លាប់ នោះត្រូវបានដាក់នៅទីនោះហើយ។ ខ្ញុំដឹងថាមនុស្សខ្លះប្រកាសខ្លួនថា ពួកគេអាចអធិស្ឋានសម្រាប់អ្នកអាចចេញពីកន្លែងនោះ ប៉ុន្តែសូមអ្នកកុំជឿ។ វាផ្ទុយទៅនឹងព្រះបន្ទូល។ ឃើញទេ? "របៀបដែលដើមឈើទ្រេត គឺវាដួលទៅខាងនោះហើយ។" ហើយព្រះយេស៊ូមានបន្ទូលដោយព្រះអង្គផ្ទាល់ថា "មានជ្រោះមួយ ដែលពេលមនុស្សស្លាប់ និងទៅស្ថាននរក គាត់មិន(មិនដែល)អាចមកស្ថានសួគ៌បានឡើយ។ គ្មានមនុស្សណាអាចឆ្លងវា និងមិនដែលមានអ្នកឆ្លងឡើយ។" វាត្រូវបានដាក់តាំងឡើង នោះជាអ្វីដែលខ្ញុំបារម្ភ។ ពេលព្រះយេស៊ូមានបន្ទូលពីវា នោះគឺវាបែបដូច្នោះហើយ។

24 ដូច្នេះសូមចងចាំ ឥឡូវនេះជាឱកាសរបស់អ្នក ហើយយប់នេះអាចជាឱកាសចុងក្រោយរបស់អ្នក។

25 តើអ្នកអាចចាប់យកអ្វីដែលកើតឡើងឬទេ? ឬអ្នកគ្រាន់តែឃើញវា! ខ្ញុំសង្ឃឹមថាអ្នកមិនគិតថានិយាយបែបនោះទេ ដែលយល់ថាខ្ញុំព្យាយាមចង់មានឥទ្ធិពលលើអ្នកដូចមនុស្សខ្លះ ឬ ជឿមនុស្សណាមួយ។ ខ្ញុំមិនធ្វើបែបនោះឡើយ មិត្តអើយ។ ខ្ញុំព្យាយាមចង់ឲ្យអ្នកជឿថាតើយើងកំពុងតែនៅក្នុងវត្តមានរបស់អង្គណានាឥឡូវនេះ។ ព្រះយេស៊ូគ្រិស្ត ជាព្រះតែមួយអង្គដែលនឹងជំនុំជម្រះអ្នកនៅ

ថ្ងៃនោះ ហើយព្រះអង្គគង់នៅទីនេះដោយសម្គាល់ព្រះអង្គទ្រង់ក្នុងវត្តមានរបស់អ្នកចំពោះអ្វីជាក់ច្បាស់ដែលព្រះអង្គសន្យា ព្រះអង្គនឹងធ្វើវានៅថ្ងៃចុងក្រោយ។

26 ខ្ញុំគិតពីបងប្រុស ប្រែស៍ នៅព្រឹកនេះនាពេលអាហារព្រឹក បានផ្តល់នូវការបង្ហាញយ៉ាងល្អរហូតមកដល់ជ្រុងមួយ រួចហើយបានត្រឡប់ជ្រុងនោះ។ តើអ្នករីករាយចំពោះការនោះទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] ពិតជាបានធ្វើ។ វាជាកន្លែង ជាកន្លែងល្អ។

27 ឥឡូវ សូមចងចាំចំណុចណាមួយនៃជ្រុងនោះ ប៉ុន្តែសូមឲ្យយើងចងចាំថាយើងត្រឡប់ជ្រុងទាំងនេះ។ ខ្ញុំអធិប្បាយពីសេចក្តីនោះ ម្តង ហើយហៅវាថា *ចំនុចប្រសព្វ*។ យើងវាយចំណុចប្រសព្វ ជាញឹកញាប់ យើងត្រូវទៅផ្លូវ*នេះ*និងជុំវិញវាដោយរបៀបផ្សេងៗ។

28 ឥឡូវយប់នេះ សម្រាប់បីបួននាទីក្រោយ ខ្ញុំចង់យកប្រធានបទនៃ—នៃ: *សម្លេងនៃទីសម្គាល់*។ ហើយឥឡូវសាច់រឿងរបស់យើងបានបើកនៅយប់នេះ ក្នុងសៀវភៅនិក្ខមនំ ហើយ *និក្ខមនំ* មានន័យថា "ចាកចេញក្រៅ នាំចេញក្រៅ។" ឥឡូវសូមព្យាយាមស្តាប់ឲ្យជិតដល់តាមតែអាចធ្វើបាន។

29 ខ្ញុំចង់អធិប្បាយទៅកាន់អ្នកពេលណាមួយ អ្នកទាំងអស់គ្នាជាអ្នកស្តាប់ល្អៗ ប៉ុន្តែខ្ញុំមិនមានសម្លេងទេ។ គឺមានរនាំងខ្លាំងពីការនេះ ហើយខ្ញុំដឹងថាអ្វីជាយ៉ាងណា។ ខ្ញុំត្រូវសម្រាកបន្តិចនៅពេលនេះ ប្រហែលជាប្រាំបីទៅដប់ថ្ងៃ មុននឹងខ្ញុំចាប់ផ្តើមការជួបជុំគ្នាជាថ្មី។ ឃើញទេ វាមិនមែនមានតែការជួបជុំតែម្តងនេះឡើយ។ វាជាការជួបជុំ ពីមួយថ្ងៃទៅមួយថ្ងៃ មួយសប្តាហ៍ទៅមួយសប្តាហ៍ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ឃើញទេ ហើយអ្នកអាចស្រមៃបាន។

30 ហើយសូមគិតពេលទាំងមូលនេះ ពីមួយឆ្នាំទៅមួយឆ្នាំ វាមិនមែនតែម្តងឡើយដែលព្រះអង្គធ្លាប់មានបន្ទូលពីអ្វីក្រៅពីដែលល្អឥតខ្ចោះ វាជាសេចក្តីពិតដ៏ពិតប្រាកដ នៅក្នុងគ្រប់ភាសា ជុំវិញពិភពលោកទាំងមូល ប្រាំពីរដង។ ឃើញទេ? គ្មានមនុស្ស គ្មានកន្លែងណាអាចនិយាយបានក្រៅពីអ្វីដែលជាភាពល្អឥតខ្ចោះ ជា ការប្រាកដថាជាចំណុចដិតគ្រប់ពេល។ ពេលព្រះអង្គមានបន្ទូលពីអ្វីមួយជាក់លាក់ដែលកើតឡើង វាកើតឡើងតាមរបៀបនោះ។ ប្រាប់វា ជាច្រើនសប្តាហ៍ទៅ ជាច្រើនខែ ហើយជាច្រើនឆ្នាំ ហើយទោះមុនវាកើតឡើងផង និងវាតែងជាមានភាពឥតខ្ចោះសម្រាប់ចំណុចដិត។ មិនមានម្តងណាដែលបរាជ័យឡើយ ហើយ

វានឹងមិន មែនទេឡើយ ព្រោះនោះជាព្រះជាម្ចាស់។ ឥឡូវខ្ញុំអាចដួល ព្រោះខ្ញុំជាមនុស្សម្នាក់។ កុំឲ្យមើលខ្ញុំថាជាគំរូឡើយព្រោះខ្ញុំដូចជា—ជាអ្នកដែរ ជាមនុស្សបាបដែលសង្គ្រោះ ដោយព្រះគុណ។ ប៉ុន្តែនោះគឺជាព្រះ អធិធម្មជាតិ ឃើញទេ សម្គាល់ពីព្រះអង្គ ផ្ទាល់។ ព្រះអង្គមិនត្រូវធ្វើដូច្នេះឡើយ ប៉ុន្តែព្រះអង្គសន្យាព្រះអង្គនឹងធ្វើ។

31 ព្រះយេស៊ូប្រោសឲ្យជាព្រោះវាបានបំពេញតាមព្រះបន្ទូល។ ព្រះអង្គធ្វើការនេះព្រោះថាព្រះបន្ទូលរបស់ព្រះនឹងបានបំពេញ។

32 នោះជាអ្វីដែលព្រះអង្គកំពុងធ្វើសម្រាប់សព្វថ្ងៃនេះ នោះជាព្រះបន្ទូលដែលអាចនឹងត្រូវបំពេញ ដែលខ្ញុំបានដកស្រង់សម្រាប់អ្នក ពីមួយយប់ទៅមួយយប់។

33 ឥឡូវ សម្គាល់ថាពេលព្រះវត្តមានព្រះជាម្ចាស់នៅក្បែរ វា វាជាការពិតណាស់នាំឲ្យមានអារម្មណ៍ដឹង។ ដូចខ្ញុំនិយាយព្រឹកនេះ "អ្វីដែលគ្មានអារម្មណ៍គឺស្លាប់។"ហើយសាសនាណាក៏ដោយបើមិនមានអារម្មណ៍នៅក្នុងនោះទេ អ្នកគួរតែកប់វាទៅព្រោះវាស្លាប់ហើយ។ វានាំមកអារម្មណ៍។ ព្រះអង្គអង្រួនយើង។ ប៉ុន្តែពេលដែលយើងទទួលបានការជម្រុញ ចូរចងចាំថាអ្វីដែលជម្រុញអង្រួនយើង។ វាជាអ្វី? វាជាវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រះយេស៊ូគ្រិស្តនៅក្នុងកណ្តាលយើងបង្ហាញព្រះអង្គផ្ទាល់ថាព្រះអង្គមានព្រះជន្មគង់នៅ។ មិនមែនរាងកាយធម្មតានោះទេ ជារាង កាយត្រឡប់ទៅស្ថានសួគ៌ពេលវេលានឹងគ្មានទៀតឡើយ។នោះគឺបែបនោះ ហើយ។ ហើយយើងដឹងថាយើងនៅក្នុងរស់នៅក្នុងសម័យចុងក្រោយ ពេលការនេះត្រូវកើតឡើង។

ឥឡូវ ព្រះជាម្ចាស់មាននាំចេញពីមុន។ មាន...

34 គ្រប់យ៉ាងធ្វើដំណើរជាបី ជាមួយនឹងព្រះជាម្ចាស់។ ព្រះជាម្ចាស់មានភាពល្អឥតខ្ចោះក្នុងទម្រង់បី។ ទីមួយ ការយាងមករបស់ព្រះគ្រិស្ត ដើម្បី*រំដោះ*កូនក្រមុំរបស់ព្រះអង្គ ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត ដើម្បី*ទទួល*កូនក្រមុំរបស់ព្រះអង្គការយាងមកជាលើកទីបីរបស់ព្រះគ្រិស្ត *ជាមួយ* កូនក្រមុំរបស់ព្រះអង្គដើម្បីគ្រងរាជ្យមួយពាន់ឆ្នាំ។ គ្រប់យ៉ាងមានដំណើរជាបី។

35 ឥឡូវមាននឹងមានការនាំចេញបី។មួយក្នុងចំណោមពួកគេ ព្រះជាម្ចាស់នាំពួកគេចូល*ក្នុង*ទូកធំ សម្រាប់នាំចេញពីលើផែនដី។ ពេលបន្ទាប់ ព្រះជាម្ចាស់នាំ

ពួកគេ*ចេញ* ពី—អេស៊ីព្ទ។ ហើយបន្ទាប់មក ព្រះជាម្ចាស់នាំពួកគេ*ឡើង*។ ក្នុងចេញក្រៅ ឡើង! ការនាំចេញបន្ទាប់កំពុងតែមកដល់។ យើងកំពុងប្រឈមមុខឥឡូវ ជាពេលឡើងទៅ។

36 ជីវិតដូចធម្មតា។ យើងចូលមក*ក្នុង*ជីវិត យើង*ចេញ*ពីជីវិត *ឡើង*ទៅឯជីវិត គឺដូចគ្នា។ ដូច្នេះយើង...

37 ទស្សនីយ៍ភាពរបស់យើងនៅយប់នេះគឺការនាំចេញ ហើយព្រះជាម្ចាស់កំពុងរៀបចំយកប្រជាជាតិរបស់ទ្រង់ចេញ។

38 អ៊ីស្រាអែលជាប្រជាជាតិមួយ។ ព្រះមិនដោះស្រាយជាមួយអ៊ីស្រាអែលតាមបុគ្គលម្នាក់ៗនោះទេ។ អ៊ីស្រាអែលគឺជាប្រជាជាតិ តែងតែដោះស្រាយ ជាមួយពួកគេ។ ហើយនៅថ្ងៃចុងក្រោយ បន្ទាប់ពី—ទៅឆ្ងាយពីក្រុមជំនុំ ព្រះជាម្ចាស់និងសង្គ្រោះអ៊ីស្រាអែលជាប្រជាជាតិ។ នៅក្នុងទឹកដីកំណើតឥឡូវ ត្រៀមរួចរាល់ហើយសម្រាប់ការនេះ។ ហើយ ពួកគេត្រូវបានទទួលការសង្គ្រោះ ព្រះគម្ពីរនិយាយ "ប្រជាជាតិនឹងកើតមកនៅថ្ងៃនោះ។" ព្រះជាម្ចាស់មិនដោះ ស្រាយជាមួយ យូដាជារបៀបបុគ្គលឡើយ។ ព្រះជាម្ចាស់តែងតែ ដោះស្រាយជាមួយពួកគេជាប្រជាជាតិអ៊ីស្រាអែល ព្រោះជាប្រជា ជាតិរបស់ព្រះអង្គ។

39 ហើយនៅទីនេះព្រះអង្គរៀបចំនាំប្រជាជាតិរបស់ព្រះអង្គចេញពីប្រជាជាតិមួយនៅក្នុងនិក្ខមនំ នាំរាស្ត្រព្រះអង្គចេញពីការជំនុំជម្រះ។

40 ហើយទឹកដែលលិចពិភពលោក បានសង្គ្រោះណូអេ។ ឃើញទេ? ហើយព្រះវិញ្ញាណបរិសុទ្ធ ដែលមនុស្សកំពុងបដិសេធសព្វថ្ងៃនេះ និងទទួលក្រុមជំនុំ និងលើកវាឡើង និង នាំការជំនុំជម្រះដល់អ្នកដែលមិនជឿ។ ព្រះយេស៊ូមានបន្ទូល។

41 ពេលគេហៅព្រះអង្គថា"បៀលសេបាប់" ពាក្យមួយទៀតគឺថា "ជាគ្រូទាយ។" ពួកគេ...

42 ព្រះអង្គមានបន្ទូល "ខ្ញុំអត់ទោសអ្នកបានសម្រាប់រឿងនោះ" ជាកូនមនុស្ស។ យញ្ញបូជាមិនទាន់បានធ្វើឡើង។ "ប៉ុន្តែពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកធ្វើការដូចគ្នា ពាក្យណាដែលទាស់នឹងវានឹងមិនដែលត្រូវបានអត់ទោសទាំងនៅក្នុងលោកនេះ និងលោកដែលនឹងត្រូវមក។" វាត្រូវបានបដិសេធ និង ការជំនុំជម្រះនឹងកើតមានបន្ទាប់ពីនោះ។ ឃើញទេ បញ្ហាគឺយើង...

43 ពេលដាក់ខ្ញុំនៅក្នុងគំនិតពេលណាមួយក្នុងរឿងដែលខ្ញុំអាន រឿងអ្នកបើកទូកក្តោងម្នាក់ចេញពីសមុទ្រ និង—អ្នកនិពន្ធកំណាព្យវ័យក្មេងជនជាតិអង់គ្លេសម្នាក់ទៅសមុទ្រ។ ដូច្នេះអ្នកកវីសរសេរយ៉ាងច្រើនពីសមុទ្រ ប៉ុន្តែគាត់មិនដែលឃើញសមុទ្រឡើយ ដូច្នេះគាត់ទៅតាមផ្លូវរបស់គាត់។ ហើយទាហានជើងទឹកចាស់មួយរូបដែលមានបំពង់ខ្យល់ពាក់នៅឡើយនិយាយទៅកាន់គាត់ "អ្នកទៅណា បុរសល្អរបស់ខ្ញុំអើយ?"

44 គាត់និយាយ "ខ្ញុំចុះទៅសមុទ្រ។" គាត់និយាយ "ខ្ញុំមិនដែលឃើញវាទេ។ ខ្ញុំសរសេរពីវាប៉ុណ្ណោះ ហើយអ្នកផ្សេងនិយាយថាម៉េចវិញ ប៉ុន្តែ" និយាយ "អូ ខ្ញុំរំ ភើបពេលខ្ញុំដឹងថាខ្ញុំនៅក្បែរសមុទ្រ។" គាត់និយាយ "អូ ដើម្បីហិតក្លិនទឹកប្រៃ! ឃើញថាវាធំ មានគម្របពណ៌សលេចចេញពីលើ ហើយមានមេឃឆ្លុះមក នឹងឮសម្លេងបោកបក់ពេលពួកវាហក់មក អូ ខ្ញុំរំភើបពេលគិតពីវា!"

45 ទាហានចាស់និយាយ "ខ្ញុំកើតនៅទីនេះ ហុកសិបឆ្នាំកន្លងទៅ ខ្ញុំមិនបានឃើញអ្វីដែលស្អាតបែបនោះទេ។" ឃើញទេ គាត់ឃើញច្រើនពេកក្លាយជាធម្មតាសម្រាប់គាត់ទៅហើយ។

46 ឥឡូវ តើមានអ្វីដែលជាបញ្ហាជាមួយក្រុមជំនុំពេនទីកុស្តសព្វថ្ងៃនេះ។ ដូចជា បានឃើញព្រះជាម្ចាស់ច្រើនពេក រហូតដល់ព្រះជាម្ចាស់ក្លាយជាធម្មតាចំពោះ ពួក គេ។ កុំឲ្យធ្វើបែបនេះ!

47 នៅត្រង់នេះ មិនជាយូរឆ្នាំឡើយ នៅឡូវីស កាន់តាក់គី។ ជាកន្លែងដែលជាស្រុករបស់ខ្ញុំ ជេហ្វិសាន់វីល អិនឌាអាយណា វាគ្រាន់តែឆ្លងទន្លេទៅដល់ហើយ។ មានស្ត្រីម្នាក់ដើរកាត់ហាងដប់-សេន។ ហើយគាត់(កាលនោះ)បីក្មេងប្រុសនៅនឹងដៃ គាត់បានទៅកាន់កន្លែងគិតលុយរួចក៏រំជួលចិត្ត។ គាត់យកអ្វីមួយ បង្ហាញដល់កូនប្រុសនោះ ក្មេងនោះបានត្រឹមតែអង្គុយសម្លឹងមើលប៉ុនោះ។ នាងទៅកន្លែងគិតលុយមួយទៀត គាត់ចាប់របស់មួយបង្ហាញទៅក្មេងប្រុសនោះគាត់គ្រាន់តែសម្លឹងមើលទៀត។ បន្ទាប់មកបន្តិចគាត់ចាប់កាន់កណ្តឹងរួចអង្រួនរួចក្មេងប្រុសគ្រាន់តែសម្លឹងមើលទៀត។ រួចនាងចាប់ស្រែករួចលើកដៃឡើង។ ហើយមនុស្សនៅក្នុងហាងដប់-សេនសម្លឹងមើលនាងរួចគេទៅជួបនាងដើម្បីរកមូលហេតុថាមានបញ្ហាអ្វី។

48 នាងនិយាយ "ខ្ញុំ...កូនប្រុសរបស់ខ្ញុំ" និយាយ "គាត់ទើបតែអាយុបីឆ្នាំ។" និង និយាយ "ខ្ញុំ...ពេលនោះ ប្រហែលមួយឆ្នាំកន្លងទៅកូនខ្ញុំត្រូវដាក់ឲ្យអង្គុយនិងសម្លឹងមើលអ្វីៗទទេប៉ុណ្ណោះ។" រួចនាងនិយាយ "ខ្ញុំ—ខ្ញុំយកកូននេះទៅជួបពេទ្យ" រួចប្រាប់បញ្ហានេះ "ហើយដុកទ័រព្យាយាមព្យាបាលដោយវិធីច្បាស់លាស់និងរបៀបផ្សេងទៀត។" រួចនិយាយទៀត "ហើយដុកទ័រប្រាប់ខ្ញុំថា ថ្ងៃនេះគាត់គិតថាកូនខ្ញុំប្រសើរឡើងហើយ។ ប៉ុន្តែ" និយាយ "កូននេះមិនធូរស្បើយសោះ។" និយាយ "ខ្ញុំអង្រួនអ្វីៗពីមុខគាត់ ដែលអាចទាក់ទាញក្មេងប្រុសអាយុប៉ុណ្ណឹង។ ធ្វើអ្វីៗដើម្បីទាក់ទាញក្មេងអាយុប៉ុនេះ ខ្ញុំអង្រួនពីមុខគាត់ គាត់បានត្រឹមតែអង្គុយហើយមើលជុំវិញប៉ុណ្ណោះ។" និយាយ "កូននេះមិនប្រសើរឡើងទេ។"

49 មានអ្វីមួយដូចជាក្រុមជំនុំពេនទីកុស្ត។ ព្រះជាម្ចាស់បានអង្រួនគ្រប់ទាំងអំណោយទាន នៅក្នុងព្រះគម្ពីរ នៅពីមុខពួកគេ ហើយពួកគេនៅតែអង្គុយនិងសម្លឹងមើលជុំវិញ ដូចជាមានអ្វីមួយខុសប្រក្រតី។ វាជាពេលវេលាដែលយើងភ្ញាក់ឡើង មិត្តអើយ មុននឹងវាយឺតពេល។ សូមចងចាំ ព្រះជាម្ចាស់មិនអង្រួនអំណោយទានទាំងនោះទាល់តែព្រះអង្គព្យាយាមចង់ធ្វើឲ្យអ្នកចាប់អារម្មណ៍។

ព្រះជាម្ចាស់នាំប្រជាជាតិចេញពីប្រជាជាតិមួយ។

50 ដូចជាអ្វីដែលព្រះអង្គកំពុងតែធ្វើឥឡូវនេះដែរ ព្យាយាមនាំកូនក្រមុំចេញពីក្រុមជំនុំ ចាកចេញពីសំណល់ដែលជាពូជរបស់ស្ត្រី។ ពួកអ្នកត្រូវបានជ្រើសរើសនឹងត្រូវនាំចេញពីក្រុមជំនុំ។ ក្រុមជំនុំនឹងនៅទីនេះតាមរយៈទុក្ខលំបាក។ នោះជាការជ្រើសរើស ពេលណាមួយដែលហៅថា "ការ*ជ្រើសរើស* ការរើសតាំង ឬ អ្នកសេសសល់។"

51 ចូរមើលពីរបៀបដែលព្រះអង្គធ្វើវា ព្រោះព្រះអង្គមិនដែលផ្លាស់ប្តូរពីរបៀបព្រះអង្គធ្វើឡើយ។ ព្រះជាម្ចាស់មានរបៀបមួយដែលធ្វើ ហើយនោះជារបៀបព្រះអង្គធ្វើវាហើយ ហើយវាជាផ្លូវត្រឹមត្រូវ ត្រូវជានិច្ច។ មើលបីរបៀបដែលព្រះអង្គធ្វើ និងកិរិយាដែលព្រះអង្គធ្វើក្នុងនោះ ដូច្នេះយើងអាចឃើញសេចក្តីនេះត្រួសៗ។

52 ឥឡូវ ខ្ញុំជាមនុស្សប្រភេទដាច់ដោយឡែកម្នាក់ ពិតណាស់។ ខ្ញុំមិនមានការសិក្សាអប់រំទេ។ ខ្ញុំត្រូវសម្លឹងមើលអ្វីដែលនៅពីមុន និងមើលពីអ្វីដែលព្រះអង្គធ្វើ។ យើងនឹងរៀនបានពីនោះ "សញ្ញាចាស់គឺជាស្រមោលនៃអ្វីដែលនឹងត្រូវមកឆាប់ៗ។" បើសិនជាខ្ញុំមើលត្រង់នេះហើយមិនសម្លឹងមើលដៃរបស់ខ្ញុំ ហើយខ្ញុំឃើញ

ស្រមោលដៃរបស់ខ្ញុំ ហើយខ្ញុំមានម្រាមប្រាំ ខ្ញុំមានគំនិតថាពេលមានដៃ ខ្ញុំនឹងមានម្រាមប្រាំ។ ដូច្នេះអ្វីដែលកើតឡើងជាមួយពួកគេគឺជាឧទាហរណ៍នៃរបៀបដែលព្រះជាម្ចាស់ធ្វើវា ជារបៀបដែលព្រះអង្គកំពុងតែធ្វើឥឡូវ។

53 ហើយរបៀបដែលទ្រង់ធ្វើវា ព្រះអង្គមិនដែលផ្លាស់ប្ដូរពីវាឡើយ។ ពេលនីមួយៗ តាមរយៈព្រះគម្ពីរ ទ្រង់មិនដែលប្ដូរវិធីធ្វើវាឡើយ។ បន្តនៅតែដដែល ព្រោះរបៀបដែលព្រះអង្គធ្វើលើកដំបូងជារបៀបល្អឥតខ្ចោះ។ ព្រោះព្រះអង្គមិនមានរបៀបផ្សេងទៀតឡើយក្នុងការធ្វើវា ព្រោះព្រះអង្គមានភាពឥតខ្ចោះ ព្រះអង្គ គ្រប់ទាំងផ្លូវរបស់ព្រះអង្គគឺល្អឥតខ្ចោះ។ ចូរសម្លឹងមើលពីរបៀបព្រះអង្គធ្វើ។

54 ម៉ូសេត្រូវបានត្រាស់ហៅពីការរើសតាំងជាមុនដើម្បីយកតួនាទីនេះពីមុន គាត់បាន—គាត់ត្រូវបានជ្រើសរើស។ ព្រះអង្គ...

55 ឥឡូវ ខ្ញុំគិតថា អ្នកដោះសារចំពោះវា...ខ្ញុំមិននិយាយថានេះជាចំណុចរសើបទេ។ ខ្ញុំត្រឹមតែនិយាយថា ក្នុងរឿងនេះ ខ្ញុំ—ខ្ញុំមិនដឹងអ្វីឡើយ ហើយខ្ញុំក៏មិនចង់ដឹងអ្វីក្រៅតែពីដឹងស្គាល់ពីព្រះជាម្ចាស់ដែរ។ ឥឡូវ ខ្ញុំគិតថាមានភ្លៀងចុងក្រោយរបស់យើងបងប្អូនបានលាយគ្នា មើល ពួកគេដាក់ដៃលើគ្នាទៅវិញទៅមករួចតាំងជាព្យាការី និងមុខងារផ្សេងទៀត។ ឥឡូវ វាមិនមែនស្របតាមបទគម្ពីរឡើយ។ "អំណោយទាន និងការត្រាស់ហៅដោយឥតកែប្រែចិត្ត។" អ្នកកើតមកតាមរបៀបអ្នកជានរណា។ អ្នកជាអ្នកដែលមានតាំងពីដំបូងមក។

56 មើលពួកផារ៉ាស៊ីនៅក្នុងសម័យនោះដែលកន្លងទៅបាត់ហើយ។ ពួកគេមានពន្លឺបន្តិច ព្រោះពួកគេអាច...មានក្រិត្យវិន័យ ហើយពួកគេរស់នៅតាមច្បាប់ ប៉ុន្តែនៅក្នុងចិត្តរបស់ពួកគេខ្មៅតាមតែរបៀបគេ។

57 ហើយមានក្មេងស្រីតូចម្នាក់ ជាស្ត្រីពេស្យា ជីវិតរួញរបស់នាង...ឡើងដល់*ត្រង់នេះ*មានភាពខ្មៅងងឹត នាងជាអ្នកមានកេរ្តិ៍ឈ្មោះ-អាក្រក់ ប៉ុន្តែក្នុងចិត្តរបស់នាងគឺត្រូវបានតម្រូវទុកសម្រាប់ជីវិតវិញ។

58 ហើយ ពេលដែលព្រះយេស៊ូ ជាព្រះបន្ទូល បានចូលមកត្រង់សាច់រឿង ពួកផារ៉ាស៊ីទាំងនោះនិយាយ "មនុស្សនេះជាបៀលសេបាប់។" តើវាមានន័យយ៉ាងណា? ពួកគេបានធ្វើឲ្យពន្លឺតិចតួចរបស់ពួកគេដែលមានទៅជាខ្មៅ។

59 ព្រះយេស៊ូមានបន្ទូលថា "អ្នកមានឪពុករបស់អ្នក ជាអារក្ខ ហើយអ្នកក៏ធ្វើការងាររបស់វាដែរ។"

60 ប៉ុន្តែ ពេលអ្នកតូចតាច ជាស្ត្រីកខ្វក់ចូលមក ហើយនាងឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ នាងស្គាល់។ នាងមិនបានរស់នៅតាមទេ ប៉ុន្តែនាងស្គាល់ព្រះបន្ទូល។ ហើយពេលពាក្យនោះនិយាយមកកាន់នាង នាងនិយាយថា "ខ្ញុំដឹងថាលោកជាហោរា៉។" ហើយទ្រង់...នាងនិយាយ "ខ្ញុំដឹងថាព្រះមេស៊ីនឹងធ្វើការនេះ។"

ព្រះអង្គមានបន្ទូលថា "គឺខ្ញុំនេះហើយជាព្រះអង្គនោះ។"

61 តើវាអាចធ្វើអ្វីបាន? វាសម្អាតភាពខ្មៅ និងធ្វើវាឲ្យទៅជាសវិញ។ ហេតុអ្វី? មានគ្រាប់ពូជនៅទីនោះ ជាគ្រាប់ពូជដែលបានតម្រូវទុកជាមុននៅក្នុង...វាជាព្រះហឫទ័យព្រះជាម្ចាស់មុននឹងដាក់គ្រឹះផែនដីនេះផង។

62 មានទម្រង់តែមួយប៉ុណ្ណោះនៃជីវិតអស់កល្ប។ បើអ្នកមានជីវិតអស់កល្បនោះមានន័យថាអ្នកមាននៅក្នុងព្រះទ័យព្រះជាម្ចាស់តាំងមុនផែនដីនេះបង្កើតទៅទៀត។ អ្នកជាផ្នែកនៃកេតណភ័ណ្ឌនៃការគិតរបស់ព្រះជាម្ចាស់ ព្រោះភាពអស់កល្បមិនមានការចាប់ផ្តើម ឬ ចុងបញ្ចប់ឡើយ។ អ្នកជាផ្នែកនៃសេដ្ឋកិច្ចក្នុងគ្រួសារព្រះជាម្ចាស់ គឺនៅជានិច្ច។ វាគ្រាន់តែជាការឆ្លុះបញ្ចាំង។ វាក្លាយជាបែបនេះនាពេលឥឡូវនេះហើយ។ ពួកគេមានរូបភាពមួយដែលត្រូវផ្តិតចេញ នោះជាសេចក្តីស្លាប់ ហេតុនោះភាពអវិជ្ជមានក្លាយជាវិជ្ជមាន រួចអ្នកក្លាយជាកូនក្រមុំ និងនៅជាមួយព្រះគ្រិស្ត ដូចដែលព្រះអង្គមានព្រះទ័យ។ ដូចជាប្តីនិងប្រពន្ធ សព្វថ្ងៃនេះ ដូច្នេះ(ព្រះជាម្ចាស់)ព្រះគ្រិស្ត និងក្រុមជំនុំគឺដូចគ្នា។ ឥឡូវ ជាអ្នករើសតាំងដែលបានហៅមក!

ម៉ូសេបានកើតមក "ជាក្មេងសក្តិសមម្នាក់។" ព្រះគម្ពីរនិយាយដូច្នោះ។

63 ព្យាការីម្នាក់ក្នុងចំណោមជាច្រើន លោកយេរ៉េមា។ ព្រះជាម្ចាស់មានបន្ទូល "មុនអ្នកមាននៅក្នុងផ្ទៃម្តាយរបស់អ្នក យើងបានរើសតាំងអ្នកជាព្យាការីសម្រាប់ប្រជាជាតិនេះ។"

64 លោកយ៉ូហានបាបទីស្ទ ហេតុអ្វី លោកត្រូវបានសម្គាល់នៅក្នុងបទគម្ពីរ។ អេសាយ ប្រាំពីររយដប់ពីឆ្នាំមិនការមកដល់ដល់របស់លោក និយាយថា

"មានសម្លេងមួយដែលស្រែកក្នុងទីរហោស្ថាន 'ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់!'" និង ប្រហែលមុនបួនរយឆ្នាំ មុនការលេចឡើងរបស់ព្រះអង្គ យើងឃើញម្តងទៀត ម៉ាឡាគីនិយាយ "មើលយើងចាត់អ្នកនាំសាររបស់យើងនៅពីមុខយើង ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់។"

65 មើល គាត់ត្រូវបានតែងតាំងជាមុន។ ក៏ដូចជាអ្នកផ្សេងទៀតដែលធ្វើការក្នុងការិយាល័យរបស់ព្រះជាម្ចាស់ គឺថាពួកគេត្រូវបានត្រាស់ហៅពីព្រះជាម្ចាស់។

66 បើសិនពួកគេត្រូវបានបង្រៀនឲ្យធ្វើការនេះ វាគ្រាន់តែជាកម្រងសៀវភៅប៉ុណ្ណោះ ឃើញទេ វាមិនអាចទេ គឺគ្មានអ្វីទេ។ បើមានសំបុត្រអាហារ អ្នកលក់សិទ្ធិកូនច្បងដើម្បីបានសំបុត្រអាហារនោះឬ អ្នកនឹងបានចុះចូលជាមួយអង្គការឬក្រុមមនុស្សណាមួយ។ ប៉ុន្តែបើវាមកពីព្រះ អ្នកនឹងឈរដោយព្រះបន្ទូល ដោយមិនខ្វល់ ព្រោះអ្នកត្រូវបានកើតមកសម្រាប់ឈរលើព្រះបន្ទូល។

67 ម៉ូសេ មិនអាចមាននរណាម្នាក់ទៀតជំនួសកន្លែងគាត់ឡើយ។ គ្មាននរណាម្នាក់ទៀតអាចធ្វើការនេះឡើយ។ គាត់ត្រូវបានតែងតាំងឲ្យធ្វើ។

68 បងប្អូនប្រុសស្រីអើយ បើអ្នកមានជីវិតអស់កល្ប អ្នកត្រូវបានតាំងឡើងសម្រាប់ធ្វើការនោះជាក់លាក់ណាមួយ។ អាចជាមេផ្ទះល្អ ឬអ្វីមួយផ្សេងទៀត ប៉ុន្តែគ្មាននរណាអាចយកកន្លែងអ្នកឡើយ។ ព្រះជាម្ចាស់បានបង្កើតអ្នកសម្រាប់កន្លែងមួយ។ កុំព្យាយាមយកកន្លែងអ្នកដទៃ។ នោះជាលក្ខណៈសាច់ឈាមបុគ្គលឃើញទេ បង្ហាញថាមានអ្វីមួយខុសជាមួយអ្នក។ ចូរធ្វើខ្លួនអ្នកជាអ្នកឲ្យជាក់ច្បាស់។ កុំធ្វើជាអ្វីទៀត។

69 ឥឡូវយើងបានរកឃើញថាព្រះជាម្ចាស់បានប្រទានលោកម៉ូសេ ជាទីសម្គាល់អំពីការប្រកាស និងការត្រាស់ហៅ។

70 ហើយរាល់ទីសម្គាល់ពិតទាំងអស់ រាល់ទីសម្គាល់ពិតទាំងអស់ នោះគឺត្រូវបានបញ្ជូនមកពីព្រះជាម្ចាស់...មានសម្លេងនៅពីក្រោយ។ ឥឡូវកុំខកខាន។ នេះជាមេរៀនចុងក្រោយរបស់ខ្ញុំសម្រាប់រឿងនេះឃើញទេ។គ្រប់ទីសម្គាល់ពិត...ឥឡូវយើងមានទី សម្គាល់ដែលមិនមែនមកពី ព្រះជាម្ចាស់សាតាំងអាចធ្វើត្រាប់គ្រប់យ៉ាងដែលអាច។ ប៉ុន្តែទីសម្គាល់ពិតគឺត្រូវ បានបញ្ជូនមកពីព្រះជាម្ចាស់គឺមានសម្លេង របស់ព្រះជាម្ចាស់នៅពីក្រោយ។

71 ព្រះជាម្ចាស់មានបន្ទូលទៅកាន់ម៉ូសេ "បើសិនពួកគេមិនជឿទីសម្គាល់ដំបូង ដូច្នេះចូរធ្វើទីសម្គាល់នេះនៅពីមុខគេ។ ហើយបើសិនជាគេមិនស្តាប់តាម ចូរយកទឹកចាក់ទៅលើដី។" ហើយនោះជាទីសម្គាល់សម្រាប់ពួកគេអាចលាយនឹងឈាមពួកគេបាន។

72 ចំណាំ ហើយដូចគ្នានឹងអ្វីដែលព្រះអង្គមានបន្ទូល "ចូររលាស់ដីចេញពីជើង។ក្រុងសូដុំនិងក្រុងកូម៉ូរ៉ានឹងទ្រាំទ្របានជាង ថ្ងៃនោះជាងក្រុងដែលបដិសេធអ្នករាល់គ្នាទៅទៀត។"

73 ឥឡូវ យើងមិនមែនជាក្រុមជំនុំលេងៗទេ។ នេះ*គឺជា* ក្រុមជំនុំ។ ព្រះគ្រិស្តជាក្រុមជំនុំ។ យើងនៅក្នុងព្រះគ្រិស្ត។ ជារាងកាយព្រះនៃព្រះគ្រិស្ត យើងកើតមកនៅក្នុងនោះ។ អ្នកមិនអាចចូលរួមឡើយ។

74 ខ្ញុំធ្លាប់នៅជាមួយគ្រួសារប្រានហាំប្រហែលហាសិប-ប្រាំឆ្នាំ ពួកគេមិនដែលស្នើរខ្ញុំឲ្យចូលរួមឡើយ។ ខ្ញុំកើតឡើងក្នុងគ្រួសារប្រានហាំ។

75 ហើយមានរបៀបដែលអ្នកក្លាយជាគ្រីស្ទាន។ អ្នកកើតជាគ្រីស្ទាន មិនមែនចូលរួមឡើយ។ អ្នកកើតមកនៅក្នុងនោះ។ គ្រប់គ្នាខ្លាចការកើតនោះ។ ពួកគេមានរបៀបស្អាតចាប់ដៃបន្តិចឬ ស៊ីញ៉េកាតមួយឬ ប្រោះទឹកជាមួយទឹកអំបិល។ នោះមិនមែនជាការកើតទេ។ ការកើតគឺជាការគួរឲ្យរន្ធត់។ ការកើតគឺ—ជាអ្វីមួយមិនជាទីចូលចិត្ត។ ខ្ញុំមិនខ្វល់ថានៅក្នុងទ្រុងជ្រូក—ឬ ក្រោលសេះ ឬនៅបន្ទប់តុបតែងមានពណ៌ផ្កាឈូកទេក្នុងមន្ទីរពេទ្យទេ ការកើតគឺគគ្រិចហើយចេញពីភាពគគ្រិចនោះគឺបានអ្នកចេញមក។ អ្នកមិនចង់បោះបង់ អ្នកមិនចង់*នេះ* មិនចង់*នោះឬអ្វីទៀត* ប៉ុន្តែទឹកភ្នែកនឹង លាងសម្អាតស្នាមប្រឡាក់លើមុខរបស់អ្នក និងធ្វើឲ្យអ្នកក្លាយជាមនុស្សខុសពីមុន។ បើអ្នកកើតជាថ្មី និងយកភាពអាក្រក់ចេញពីអ្នក ប៉ុន្តែអ្នកនឹងក្លាយជាមនុស្សថ្មី។ ឃើញទេ? ពួកគេមិនចង់បានដូច្នោះទេ។ ពួកគេចង់បានរបៀបស្រួលៗ អ្នកដឹងទេ គ្មានរបៀបស្រួលទេ។ ដូចជាចម្រៀង ច្រៀងថា "ខ្ញុំនឹងយកផ្លូវជាមួយព្រះអម្ចាស់ហើយបដិសេធផ្លូវមួយចំនួនទៀត។" គាត់ មិនចង់ក្លាយជារុក្ខជាតិក្នុងថ្នាលបណ្ដុះទេ។

គ្រប់ទីសម្គាល់ពិតរបស់ព្រះគឺមានសម្លេងព្រះជាម្ចាស់មកតាម។

76 ឥឡូវបើមនុស្សម្នាក់ផ្តល់ទីសម្គាល់នៅក្នុងប្រទេសមួយ ឬពេលណាក៏ដោយ ហើយសម្លេងដែលគាត់និយាយមិនមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូច្នេះសូមពិនិត្យមើលវា ហើយកុំជឿតាម។ ប្រសិនបើសាលាចាស់ បើមនុស្សម្នាក់ក្រោកឡើងហើយនិយាយ ចូរបង្ហាញទីសម្គាល់មកពីព្រះជាម្ចាស់ និងការបង្រៀនរបស់មនុស្សនោះដូចគ្នាផ្នែកទេវសាស្រ្តចាស់ អ្នកនឹងមានពេលវេលាទាំងនេះព្រះជាម្ចាស់មិនបានបញ្ជូនទីសម្គាល់ឡើយ។ ចូរមើលនៅក្នុងខគម្ពីរ ហើយមើលថាវាមែនឬអត់។ ស្រាវជ្រាវខគម្ពីរ។ មនុស្សនោះមកវិញហើយនិយាយ "ឥឡូវយើងទាំងអស់គ្នាចង់ចូលរួមការ*នេះ*។ វាជារឿងចាស់ធ្លាប់ធ្វើពីមុន។" អ្នកមិនជឿថាចឹងទេ។ យើងនឹងចូលទៅក្នុងនោះ ពីរបីនាទី ឃើញទេ។ ទេ អ្នកមិនជឿទេ។

77 ព្រះជាម្ចាស់តែងបញ្ជាក់ទីសម្គាល់របស់ព្រះអង្គថាត្រឹមត្រូវ។ ទីសម្គាល់ពីព្រះជាម្ចាស់តែងនិយាយពីសម្លេងរបស់ព្រះ។

78 ហើយបើវាដូចជាសាលាចាស់ដែលអ្នកធ្លាប់រៀនហេតុអ្វីបានជាព្រះអង្គចាំបាច់ប្រទានទីសម្គាល់។ បើអ្នកនៅក្នុងនោះស្រាប់ហើយ? ព្រះអង្គព្យាយាមយកអ្នកទៅកាន់ជ្រុងនោះ។ សញ្ញាឈប់! យឺតៗ! មើលតើអ្នកកំពុងទៅណាអ្នកនឹងចាក់ខ្លួនឯងចោលនៅជ្រុងម្ខាងបើអ្នកមិនមើល។ មានផ្លូវបត់កោង ហើយវាតែងតែមានសញ្ញាមុននឹងមកដល់ផ្លូវបត់កោង ដើម្បីការពារអ្នកកុំឲ្យទៅកកិត។ អ្នកកសាងផ្លូវល្អនឹងដាក់សញ្ញាសម្គាល់។ ហើយយើងជាអ្នកធ្វើដំណើរតាមផ្លូវទៅកាន់សិរីរុងរឿង។ បើសិនជាទីសម្គាល់និយាយដូចអ្វីដែលចាស់ វាមិនមែនមកពីព្រះជាម្ចាស់ឡើយ។

79 ព្រះជាម្ចាស់ប្រទានទីសម្គាល់សម្រាប់ទាក់ទាញចំណាប់ អារម្មណ៍រាស្រ្តរបស់ព្រះអង្គ។ ទីសម្គាល់គឺទាក់ទាញចំណាប់អារម្មណ៍រាស្រ្តរបស់ព្រះជាម្ចាស់ នោះហើយជាទីសម្គាល់របស់ព្រះជាម្ចាស់។ទីសម្គាល់ព្រះជាម្ចាស់គឺទាក់ទាញចំណាប់អារម្មណ៍រាស្រ្តរបស់ព្រះជាម្ចាស់។

80 ឥឡូវ នេះជាគម្ពោតព្រៃឆេះជាទីសម្គាល់ទាក់ទាញចំណាប់អារម្មណ៍ព្យាការីការសាកល្បង ព្រោះព្យាការីបានរត់ចេញឆ្ងាយពីព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ប្រទានគម្ពោតព្រៃឆេះជាទីសម្គាល់។ ហើយគាត់ឃើញទីសម្គាល់ចម្លែកនេះគាត់និយាយ "ខ្ញុំនឹងចូលទៅមើលតើទីសម្គាល់ចម្លែកនេះជាអ្វី នោះគឺ—មានគុម្ពោតព្រៃមានភ្លើងតែឆេះមិនសុះ។" ឥឡូវ ព្រះជាម្ចាស់ប្រទានទីសម្គាល់សម្រាប់

ទាក់ទាញចំណាប់អារម្មណ៍ព្យាការីរបស់ព្រះអង្គ។ ព្រះអង្គមានអ្នកផ្សេងទៀត ប៉ុន្តែព្រះជាម្ចាស់បានតាំងម៉ូសេសម្រាប់ការងារនេះ និងគ្មាននរណាអាចយកកន្លែងគាត់ឡើយ។

81 នៅក្នុងការធ្វើដំណើរ មានអ្នករួមសហការព្យាយាមធ្វើវា អ្នកដឹងហើយ។ ដាថាន ងើបឡើងហើយចង់ធ្វើជាក្រុមមួយ ចេញពីនោះមក។ ព្រះជាម្ចាស់មានបន្ទូលទៅកាន់ម៉ូសេ "ញែកចេញ យើងនឹងលេបពួកគេ។" ឃើញទេ?

82 ព្រះជាម្ចាស់ចាត់ចែងជាមួយបុគ្គល។ ឃើញទេ? ឥឡូវកត់សម្គាល់រឿងនេះ ព្រះអង្គព្យាយាម ទាក់ទាញចំណាប់អារម្មណ៍ព្យាការីរបស់ព្រះអង្គ ដើម្បីនាំព្យាការីទៅចំកន្លែងត្រូវ ឃើញទេ ហើយព្រះអង្គប្រទានទីសម្គាល់នៃគុម្ពោតព្រៃឆេះ។

83 ហើយ ពិនិត្យមើល សម្លេងដែលមកតាមទីសម្គាល់ជាសម្លេងខាងវិញ្ញាណ។ "អញបានឮសម្រែកនៃរាស្ត្ររបស់អញ និងការយំថ្ងូររបស់គេ ដោយព្រោះចៅហ្វាយការងាររបស់គេហើយអញនឹកចាំពីសេចក្តីសន្យារបស់អញ។"អាម៉ែន។វាគឺដំណោះស្រាយដូច្នេះ។ "អញចាំសេចក្តីសន្យានេះ។" នោះជាសម្លេងខាងវិញ្ញាណ។ "យើងបញ្ជូនឯងឥឡូវ អញមកដើម្បីនឹងរំដោះគេ ហើយនឹងបញ្ជូនអ្នកទៅ។"

84 សូមចងចាំ ព្រះជាម្ចាស់មិនធ្វើអ្វីក្រៅពីមនុស្សឡើយ។ អ្នកដឹងហើយ? នោះជាអ្វីដែលនាំឲ្យមនុស្សជំពប់។ ឃើញទេ?

85 នេះជាអ្វីដែលធ្វើឲ្យពួកគេជំពប់ដួលនឹងព្រះយេស៊ូ។ ពួកគេនិយាយ "អ្នកជាមនុស្សតាំងខ្លួនជាព្រះ។" ព្រះអង្គជាព្រះប៉ុន្តែពួកគេមិនអាចយល់បាន។ "ពិតមែនហើយ អ្នកគ្រាន់តែជាមនុស្សប៉ុណ្ណោះ។"

86 គាត់និយាយ "បាទ អ្នកនឹងហៅថាព្យាការី 'ព្រះជាច្រើន' ហើយច្បាប់ របស់អ្នករៀបចំឡើង។ ហើយបើអ្នកហៅពួកគេថាជា'ព្រះជាច្រើន' ដែល ជា ព្រះ បន្ទូលនៃព្រះជាម្ចាស់បានមកតើហេតុអ្វីអ្នកអាចកាត់ទោសខ្ញុំពេលខ្ញុំនិយាយថាខ្ញុំ ជាព្រះបុត្រាព្រះជាម្ចាស់?"

87 មើល សញ្ញា ដើម្បីទាក់ទាញចំណាប់អារម្មណ៍។ និង សូមចាំ បើសិនជាអាចទាក់ទាញចំណាប់អារម្មណ៍ហើយ វាដូចជាបន្ទាត់ចាស់ដែរ គឺមិនមែនមកពីព្រះជាម្ចាស់ទេ។

88 ប៉ុន្តែព្រះជាម្ចាស់ព្យាយាមទាក់ទាញព្យាការីរបស់ព្រះអង្គឥឡូវ ហើយព្រះអង្គប្រទានទីសម្គាល់ និងសម្លេងដែលមកតាមទីសម្គាល់ជាសម្លេងនៃទីសម្គាល់។ "អញបានឃើញរាស្ត្ររបស់អញ។ អញបានឮសម្លេងពួកគេស្រែកយំ។ អញនឹកចាំពីសេចក្តីសន្យារបស់អញ។"

89 ឥឡូវ ព្រះជាម្ចាស់នឹងមានបន្ទូលតាមរយៈព្រះបន្ទូលសន្យារបស់ព្រះអង្គ។ ព្រះអង្គត្រូវតែបញ្ជូន ព្យាការីទ្រង់ ព្រោះព្រះបន្ទូលបានមកដល់ព្យាការី។ ព្រះគម្ពីរនិយាយថា ព្រះអង្គមានបន្ទូលដោយខ្លួនព្រះអង្គផ្ទាល់ "ព្រះអង្គមិនធ្វើ អ្វីទាំងអស់លើកលែងតែព្រះអង្គបានបើកសម្តែងដល់អ្នកបម្រើនិងព្យាការីរបស់ព្រះ អង្គជាមុន។" ឃើញទេ? រួចមក ទីសម្គាល់នឹងត្រូវបានប្រទានមក ហើយបទគម្ពីរ ត្រូវបានកត់សម្គាល់ នោះហើយជាសម្លេងនៃទីសម្គាល់។

90 ឃើញទេ សម្លេងនៃទីសម្គាល់ របស់ម៉ូសេ? ដំបូង ទីសម្គាល់ឆេះគុម្ពោតព្រៃ សម្លេងគឺជាបទគម្ពីរ។

91 ម៉ូសេបានយកជាទីសម្គាល់របស់គាត់ ហើយធ្វើដំណើរទៅអេស៊ីព្ទ និងបានធ្វើទីសម្គាល់ដែលព្រះជាម្ចាស់បានប្រាប់ដល់គាត់ ហើយទីសម្គាល់នោះមានសម្លេងរបស់វា ហើយមនុស្សជឿហើយសម្លេងចេញទៅពួកគេចូលមក។ ហើយពេល ពួកគេដើរក្បួនចេញទៅពួកគេមានភាពសុខសាន្ត ប៉ុន្តែពេលពួកគេចាប់ផ្តើមរអ៊ូប្រឆាំងនឹងសម្លេង ហើយពួកគេបានឈប់។

92 សូមចងចាំ អ៊ីស្រាអែលបានធ្វើដំណើរ។ តើអ្នកដឹងទេថា ពួកគេធ្វើដំណើរឆ្ងាយប៉ុណ្ណា? ពួកគេបាន...មានចម្ងាយតែ៤០ម៉ាយប៉ុណ្ណោះ ប៉ុន្តែពួកគេធ្វើដំណើរសែសិបឆ្នាំឯណោះ។ ហេតុអ្វី? គឺពីព្រោះដោយពួកគេរអ៊ូរទាំទាស់នឹងសម្លេងដែលមានទីសម្គាល់។ តើពួកគេដឹងតិចប៉ុណ្ណា ពេលពួកគេស្រែកពីច្រាំងទន្លេ ហើយរាំដោយវិញ្ញាណ និងម៉ូសេច្រៀងដោយវិញ្ញាណ ពួកគេធ្វើដូច្នេះបានតែបីបួនថ្ងៃប៉ុណ្ណោះ ។ ប៉ុន្តែពួកគេចាប់ផ្តើមរអ៊ូរទាំ និងចង់ធ្វើអ្វីមួយផ្សេង ដូច្នេះពួកគេនៅក្នុងវាលរហោស្ថានសែសិបឆ្នាំពួកគេក៏វិនាសទៅ នោះជាការពិត ព្រោះពួកគេមិនជឿ។ ព្រះជាម្ចាស់មានបន្ទូល "ពួកគេមិនមែននិយាយទាស់នឹងអ្នកទេម៉ូសេ តែទាស់នឹងអញវិញ។" នោះជាសម្លេងរបស់ព្រះជាម្ចាស់មិនមែន ម៉ូសេឡើយ។

93 ឥឡូវ ពិនិត្យមើល ព្រះយេហូវ៉ានឹងមានបន្ទូលតាមសេចក្តីសន្យារបស់ព្រះអង្គ ដូច្នេះព្រះអង្គបញ្ជូនព្យាការីរបស់ព្រះអង្គ។ នោះ បើអ្នកចង់ឃើញ សូមមើល លោ

កុប្បត្តិ ១៥:១៦។ យើងឃើញថាព្រះជាម្ចាស់មានបន្ទូលទៅកាន់អ័ប្រាហាំ "ពូជរបស់អ្នកនឹងធ្វើដំណើរទៅកាន់ទឹកដីថ្មី គេនឹងវិលមកឯណេះវិញ ដ្បិតសេចក្តីទុច្ចរិតរបស់ពួកសាសន៍អាម៉ូរីមិនទាន់ពោរពេញនៅឡើយ។" រាល់សេចក្តីសន្យារបស់ព្រះអង្គដែលបានប្រទានមក នេះព្រះអង្គទាញចំណាប់អារម្មណ៍ព្យាការីតាមរយៈគុម្ពោតព្រៃឆេះ។

94 ឥឡូវបើគម្ពោតព្រៃប្រហែលជាអាច និយាយថា "ម៉ូសេ ព្រះជាម្ចាស់គឺជាព្រះ។"

"មែន ខ្ញុំជឿថាដូច្នេះ។"

95 "អូ អ្នកមិនអីទេ ម៉ូសេ ចូរបន្តទៀត។ អ្នករៀបការជាមួយស្ត្រីស្អាតម្នាក់ នាងជាក្មេងស្រីស្អាតម្នាក់។ នឹងមានកូនប្រុសស្អាត! ជាសិរីរុងរឿងដល់ព្រះជាម្ចាស់!" នោះគឺដូចសាលាចាស់ដដែល។ ឃើញ?

96 ប៉ុន្តែព្រះជាម្ចាស់ត្រៀមរួចជាស្រេចក្នុងការធ្វើអ្វីមួយដូច្នេះព្រះអង្គត្រូវទាក់ទាញបុរសនេះ។ ព្រះអង្គបានប្រទានទីសម្គាល់ពីរដើម្បីធ្វើ ហើយមានបន្ទូល "ទីសម្គាល់នីមួយៗមានសម្លេង។" ដែលបង្ហាញថាវាគឺដូច្នេះ ។ ឥឡូវសូមមើលតើសម្លេងទាំងនោះនិយាយពីអ្វី ទោះបីជាការបង្កើត។ ព្រះយេហូវ៉ាត្រៀមរួចជាស្រេចក្នុងការមានព្រះបន្ទូល ឥឡូវនេះ។

97 ម្តងទៀតហើយ ការមកដល់របស់ព្យាការីគឺជាទីសម្គាល់។ តើអ្នកដឹងថាដូច្នោះទេ? ការមកដល់របស់ព្យាការី សម្រាប់សម័យកាលមួយ ជាទីសម្គាល់។

98 ឥឡូវ ខ្ញុំមិនមានន័យចំពោះបណ្ឌិតទេវសាស្ត្រទេ។ ខ្ញុំមិនមែនមានន័យថាជាគ្រូគង្វាលស្មោះត្រង់ជាមនុស្សល្អណាម្នាក់ទេ។ ពួកគេល្អហើយ។ ពួកគេជាអ្នកបម្រើព្រះជាម្ចាស់។

99 ប៉ុន្តែព្យាការីជាទីសម្គាល់។ ព្រះគម្ពីរនិយាយត្រង់នេះ។ តើទីសម្គាល់នោះសម្រាប់អ្វី? ជាទីសម្គាល់សម្រាប់ព្រះបន្ទូលទ្រង់ដើម្បីបំពេញ ជាការបំពេញដោយសម្លឹងនៃទីសម្គាល់របស់ព្យាការី។

100 ចូរសម្គាល់ការយាងមករបស់ព្យាការីគឺជាសញ្ញាព្រមាននៃការជំនុំជម្រះដែលជិតមកដល់។ តើអ្នកដឹងថាដូច្នេះទេ? ការជំនុំជម្រះត្រៀមរួចជាស្រេចក្នុងការកើតឡើង បើមានព្យាការីមកកាន់ផែនដី។

101 សូមចាំ គាត់ប្រាកដណាស់ ដំបូង បញ្ជាក់ដោយព្រះជាម្ចាស់ និងព្រះបន្ទូលសម្រាប់ពេលនោះ។ រួចមកគាត់ធ្វើទីសម្គាល់។ ហើយរងចាំទីសម្គាល់ដែលគាត់ទាយទុក។ ព្រះអង្គមានបន្ទូល "ចូរស្តាប់អញចុះ បើមានហោរាណានៅក្នុងពួកឯងរាល់គ្នាមកដល់" ជនគណនា១២:៦។ "បើមិនមកទេ បំភ្លេចចោលចុះ។" វាជាទីសម្គាល់នៃបទគម្ពីរដែលព្រះអង្គប្រទាន។

102 ហើយអ្វីទៅដែលព្រះអង្គប្រទានសម្រាប់ជាទីសម្គាល់ ម្តង បើសិនជាព្រះអង្គនៅដូចកាលពីម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ ព្រះអង្គនឹងប្រទានមកដូចគ្នា។ "ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់លោកព្យាការី។"ជាព្រះបន្ទូល។ ហើយព្រះយេស៊ូបានយាងមក ព្រះអង្គជាព្រះបន្ទូល។ ហើយព្រះបន្ទូលស្គាល់ពីគំនិត និង បំណងរបស់ចិត្ត នៅតែបន្ត តទៀត តទៀត។ ឥឡូវ សូមមើល។

103 ការយាងមករបស់ព្យាការី ផ្តល់នូវទីសម្គាល់ "ការជំនុំជម្រះមកជិតដល់" តែងតែដូច្នេះ។

104 សូមឈប់បីបួននាទី។ វាមិនយូប៉ុន្មានទេ។ សូមពិនិត្យរឿងពីរប្រហែល១០នាទី។ ហើយសារដែលនៅសល់ ឬ ជាងដប់នាទី។

105 ណូអេ ជាព្យាការីប្រចាំទឹកដី—នៅក្នុងទឹកដី ជាទីសម្គាល់ដែលការជំនុំជម្រះមកដល់។ ម៉ូសេជាព្យាការីនៅក្នុងទឹកដី ជាទីសម្គាល់ការជំនុំជម្រះមកដល់។ អេលីយ៉ា ព្យាការីនៅក្នុងទឹកដី ជាទីសម្គាល់ការជំនុំជម្រះមកដល់។ យ៉ូហាន ជាព្យាការីនៅក្នុងទឹកដី ជាទីសម្គាល់ការជំនុំជម្រះមកដល់អ៊ីស្រាអែល ពួកគេត្រូវបានកាត់ចេញ។

106 ចំណាំ ទីសម្គាល់! តើទីសម្គាល់នឹងធ្វើអ្វី? ទីសម្គាល់នឹងទាក់ទាញចំណាប់អារម្មណ៍ និង ទទួលអ្នកជ្រើសរើសរួចហើយ ហើយចេញពីផ្លូវដែលការជំនុំជម្រះនឹងមក។ នោះជាអ្វីដែលណូអេធ្វើគឺទទួលអ្នកត្រូវជ្រើសរើសរួចហើយ។ ពួកគេផ្សេងទៀតហើយពួកគេធ្វើអី? ជាទីសម្គាល់ និង សម្លេងនៃទីសម្គាល់។ កាត់ទោសអ្នកមិនជឿ និង យកពួកគេសម្រាប់ការជំនុំជម្រះ។ វាយកអ្នកដែលត្រូវបានជ្រើសរើសរួចហើយសម្រាប់ការរគេច។ នោះជាទីសម្គាល់។ នោះហើយជាអ្វីដែលទីសម្គាល់ បានប្រទានមក សម្រាប់ការជំនុំជម្រះដែលត្រូវមក។ សម្រាប់អ្នកដែលបានជ្រើសរើស ពួកគេនឹងឃើញ។

107 ដូចជាស្ត្រីតូចមួយដែលមានចិត្តស្អាត ហើយ មានរាងកាយដែលត្រូវបង្ខូច និងពួកផារ៉ាស៊ីជាមួយរាងកាយបរិសុទ្ធ តែមានចិត្តខូចវិញ។ វាត្រូវកាត់ទោសម្នាក់ និងសង្គ្រោះអ្នកផ្សេងទៀត។

108 ហើយរាល់ការជំនុំជម្រះដែលសង្គ្រោះម៉ូសេ បានកាត់ទោសលោកកិយវិញ ដោយការអធិប្បាយរបស់គាត់។

109 វាត្រូវបានជ្រើសរើសរួចហើយ។ តើការជ្រើសរើសរួចហើយនោះសម្រាប់អ្វី? ពេលពួកគេឃើញទីសម្គាល់ព្រះជាម្ចាស់ដែលបានប្រទានមក ពួកគេត្រូវត្រឡប់ទៅមើលបទគម្ពីរ និង ឃើញថាតើត្រូវមានបែបនោះឬទេ។ "មែន នៅត្រង់នេះ។" នេះជាអ្វី? ការជំនុំជម្រះចេះតែពន្យាពេល។ តែពួកអ្នកដែលបានជ្រើសរើសនឹងស្តាប់សម្លេង។

110 ប៉ុន្តែពួកអ្នកមិនបានរើសតាំងធ្វើមិនដឹង និង និយាយថា "គ្មានប្រយោជន៍។ បន្តទៀត! យើងនឹងធ្វើដូចសាលាចាស់។" ឃើញ? នោះជារបៀបគេធ្វើនៅសម័យលូធើរ។ នោះជាអ្វីគេធ្វើនៅសម័យវេស្លេ។ នោះជារបៀបគេធ្វើ ពួកគេ—ពួកគេធ្វើនាពេលឥឡូវ ជារបៀបដែលពួកគេតែងតែធ្វើ។

111 ប៉ុន្តែវាមានទីសម្គាល់ ហើយវាមានសម្លេងដែលតាមទីសម្គាល់។ ហើយសម្លេងត្រូវបានកត់សម្គាល់ថាជាសម្លេងខគម្ពីរចាស់។ ឥឡូវសូមកុំភ្លេចការនោះ។ ឥឡូវ រក្សាឲ្យនៅក្នុងនោះ ព្រោះខ្ញុំប្រហែលមិនអាចជួបអ្នកម្តងទៀតឡើយ។

112 ខ្ញុំប្រាថ្នាឲ្យមានផ្លូវចុះពីទីនេះ រួចទទួលយកបងប្អូនទាំងអស់ ពេលដែលពួកគេមិនមានចលនាផុសផុលបន្ត គឺដាក់តង់ និងអង្គុយចុះ ពីមួយថ្ងៃទៅមួយថ្ងៃ ហើយបង្រៀនពួកគេរហូតដល់—រហូតដល់វាបានត្រាំជោគ។ ប៉ុន្តែព្រះអង្គមិនអនុញ្ញាតិ ខ្ញុំមិនគិតចឹងទេ។ ឃើញទេ យើងនៅជិតចុងបញ្ចប់។ ខ្ញុំជឿថាយើងនៅជិតចុងបញ្ចប់ហើយ។

113 ក្នុងសៀវភៅរបស់ខ្ញុំ ដែលខ្ញុំសរសេរតមក។ ក្នុងឆ្នាំ១៩៣៣ នៅព្រឹកមួយកំពុងតែរៀបចំទៅថ្នាក់ថ្ងៃអាទិត្យ សាលាបាបទីស្ទថ្នាក់ថ្ងៃអាទិត្យដែលខ្ញុំធ្វើជាគ្រូគង្វាលពីមុន ហើយព្រះវិញ្ញាណបរិសុទ្ធយាងមក និងបង្ហាញខ្ញុំតមកពេលចុងបញ្ចប់និងបង្ហាញខ្ញុំរឿងប្រាំពីរយ៉ាងដែលកើតឡើង។ ខ្ញុំចំណាំទាំងអស់ទុក។ វាជា ក្រដាសពណ៌លឿងចាស់មួយសន្លឹក។

114 បានប្រាប់ខ្ញុំពីការពិតនៃប្រទេសអាឡឺម៉ង់សាងសង់ជញ្ជាំងបែងចែក និង អាមេរិក បានវាយវាយ៉ាងខ្លាំង គឺដប់មួយឆ្នាំមុនពេល—ជញ្ជាំងបានសង់ឡើង។

115 និយាយពីរបៀបដែលម៉ូសូលីនីលេចឡើង និងពីរបៀបគាត់ទៅអេត្យូពី ហើយពីរបៀបដែលប្រទេសអេត្យូពី "ធ្លាក់ដើរតាមជំហានរបស់គាត់។" ហើយពីរបៀបគាត់ត្រូវស្លាប់យ៉ាងអាម៉ាស់ មានការផ្លាស់ប្តូរ និងមនុស្សរបស់គាត់ស្តោះទឹកមាត់ដាក់គាត់។

116 ហើយខ្ញុំនិយាយ "នឹងមានលទ្ធិបី កុំម្មុយនីស្ត ហ្វាស៊ីស និង ណាស៊ីស។ ពួកវានឹងកើតចេញពីរុស្ស៊ី ក្នុងភាពជាកុំម្មុយនិស្ត។" ហើយវានឹងបំផ្លាញកាតូលិកនិយម។ មើលថាមែនឬក៏អត់!

117 ខ្ញុំនិយាយ "ដំណើរការទាំងនេះនឹងកើតឡើង!" ខ្ញុំនិយាយ "ខ្ញុំឃើញមានយាន ជំនិះដូចជាស៊ុតតាមផ្លូវ។ គឺមានឡានបើកតាមផ្លូវមានប្រភេទជារបស់គ្រប់ គ្រង វាមិនចាំបាច់មានអ្នកនាំផ្លូវ។ ខ្ញុំឃើញគ្រួសារជនជាតិអាមេរិកលេងអុកនៅ ខាងក្រោយឡាន។" ពួកគេមានឡានហើយឥឡូវនេះ ហើយពួកគេមានផ្លូវធំ ដើម្បី បើក។ វ៉ុលវីហ្គិនតូចមួយគឺដូចជាឡានរាងស៊ុតល្អតតខ្វោះគឺពិតណាស់ គឺសំដៅលើឡានផ្សេងៗទៀត។ អ្នកស្រមៃមើល ក្នុងឆ្នាំ១៩៣៣ ឡានមានរាងដូចម្តេច រហូតដល់ឥឡូវ?

118 ហើយ ខ្ញុំទាយទុកម្តងទៀត ថា ការអនុញ្ញាតិឲ្យស្ត្រីបោះឆ្នោត និងអ្វីដែលពួកគេធ្វើ។ ហើយពីប្រទេសនេះយ៉ាងណា ជាប្រភេទ ដូចអ៊ីស្រាអែល ចូលមកទឹកដីនិងបណ្តេញការត្រួតត្រា ហើយទទួលបានទឹកដី។ ហើយស្តេចពីរបីដំបូងដែលគេមាន ដាវីដ និងសាឡូម៉ូន គឺជាស្តេចកោតខ្លាចព្រះជាម្ចាស់។ បន្ទាប់មកពួកគេ មានអាហាប់តាមឈុតឆាក។ ពួកគេជ្រើសរើសមក។ ប្រធានមាន... ក្រុមជំនុំក្លាយជារបស់លោកកិយ។ ហើយយើងមានលីងខុននិងវ៉ាស៊ីនតុនសូមមើលអ្វីដែលមានសព្វថ្ងៃនេះមើល។ មើលថាតើយើងទៅណាឥឡូវ។ កន្លែងណាដែលមាន បន្ទាប់? យើងដល់ពេលចុងក្រោយហើយ។

119 ហើយវាជាទីសម្គាល់ ក្នុងភាពដើម ពិតណាស់។ មានអ្នកត្រូវបានជ្រើសតាំងរួចរាល់ និង មានការជំនុំជម្រះ អ្នកមិនជឿ។

120 "បើសិនជាហោរ៉ានេះពិតប្រាកដ ហើយអ្វីដែលគាត់ថ្លែងនោះកើតឡើង" ព្រះ គម្ពីរ និយាយនៅក្នុងជនគណនា១២:៦ "ចូរស្តាប់អញចុះ ព្រោះវាជាការកាត់សេចក្តីមិនមែនមកពីមនុស្សទេ។" ព្យា—ព្យាការីជាមនុស្សម្នាក់។ ប៉ុន្តែសម្លេងដែលមានការអស្ចារ្យគឺជាសម្លេងតាមបទគម្ពីរ វានឹងកាត់សេចក្តីត្រឹមត្រូវ ហើយវាជា ការព្រមាន។

121 ព្រះបន្ទូលត្រូវបានសរសេរដោយព្យាការី សូមចងចាំ។ នៅក្នុងគម្ពីរពេត្រុសខ្សែរទីពីរផងដែរ១:២១។ ក្នុងគម្ពីរហេប្រឺ១:១ដែរ។

122 សសរភ្លើង ចំពោះម៉ូសេ ជាទីសម្គាល់សម្លេងនឹងនិយាយ។ សសរភ្លើងបង្ហាញថាសម្លេងនឹងនិយាយ។ នោះជាទីសម្គាល់ សសរភ្លើង។ អ្នកជាមនុស្សគួរចងចាំថាមកពីការហូស្តុន មិនយូកន្លងមកទេ។

123 ម៉ូសេ ជាព្យាការី ជាទីសម្គាល់ដល់អ៊ីស្រាអែល នោះជាសេចក្តីសន្យាដែលបានបំពេញ។ ពេលម៉ូសេចូលមកហើយធ្វើទីសម្គាល់នៃព្យាការីពួកគេដឹង ហើយពួកគេប្រមូលផ្តុំគ្នា។

124 ព្រះបន្ទូលរបស់ព្រះអង្គល្អតាមលំដាប់លំដោយណាស់ ពេលនីមួយៗគឺដូចគ្នា។ ទោះបីខ្ញុំនិយាយនៅយប់មុនពីរបៀប យូរីម ធូមីម និងគ្រប់យ៉ាង ដែលជាចម្លើយទៅកាន់ព្រះជាម្ចាស់។

125 ចូរមើលពីព្យាការីម្តងទៀត មួយភ្លែត យូណាស។ ខ្ញុំមានជំពូកទី១នៃគម្ពីរយូណាសសរសេរមក ជំពូកទី១នេះពីការថ្លែងទំនាយ។ យ៉ូណាសចេញពីពោះត្រីជាទីសម្គាល់។ មើលមនុស្សទាំងនោះជាសាសន៍ដទៃ។ ពួកគេថ្វាយបង្គំព្រះនៃសមុទ្រ ហើយព្រះនៃសមុទ្រគឺជាត្រីបាឡែន។

126 ឥឡូវមនុស្សជាច្រើនព្យាយាមកាត់ទោសយ៉ូណាស។ ខ្ញុំតែងតែឈរខាងយ៉ូ ណាស។ យ៉ូណាសមិននៅឆ្ងាយពីផែនការព្រះអម្ចាស់ឡើយ។ "ផ្លូវដើររបស់មនុស្សសុចរិតគឺមានសណ្តាប់ធ្នាប់ តាមព្រះអម្ចាស់។" យើងចង់និយាយថា "គាត់ជាយ៉ូណាស។" ប៉ុន្តែសូមយកវាជា...អ្វីជាតម្លៃរបស់វាម្តង។ខ្ញុំដឹងថាគាត់ត្រូវទៅនីនីវេ ប៉ុន្តែព្រះជាម្ចាស់បណ្តាលឲ្យគាត់ជិះកាប៉ាល់ទៅតាស៊ីសវិញ។ ហើយគាត់ក៏មានបញ្ហានៅក្នុងសមុទ្រ។

127 យ៉ូណាសនិយាយ "ចូរចងដៃជើងរបស់ខ្ញុំ។ ខ្ញុំជាអ្នកធ្វើឲ្យមានបញ្ហា ជាម្នាក់ដែលបង្ករវាឡើង។" ហើយគេបោះគាត់ចូលទៅ។ ហើយត្រីកំពុងតែហែលក្នុងទឹក ជាត្រីធំដែលលេបយ៉ូណាស។ ខ្ញុំដឹងថាពិបាកណាស់សម្រាប់អ្នកវិទ្យាសាស្រ្តដែលជឿ។

128 នៅកាលមិនយូប៉ុន្មានទេ ឡូវីសវីល នៅកេនតាក់គី ប្រហែលដប់ឆ្នាំកន្លង មកហើយ គេមាន—ត្រីបាឡែនដេកពីលើ—ឡានសំប៉ែត។ ហើយមានវីគីតូចមួយនៅទីនោះ គេដឹងពីរបៀបគ្រប់គ្រងណាស់។ គាត់ព្យាយាមបង្ហាញថាព្រះគម្ពីរកុហក់។ គាត់និយាយ"អ្នកដឹងទេអ្នកឮសុភាសិតចាស់នៅព្រះគម្ពីរ ថាត្រីបា ឡែន លេបយ៉ូណាស។" គាត់និយាយ "អ្នកមិនអាចដាក់បាល់ចូលក្នុងបំពង់កវាផង ។ តើអាចលេបមនុស្សមួយទាំងមូលចូល ទៅក្នុងពោះរបស់វាម្តេចបាន?" និយាយ "អ្នកឃើញទេ វាគ្រាន់តែជាសុភាសិតចាស់ប៉ុណ្ណោះ ហើយនៅក្នុងព្រះគម្ពីរពេញ ដោយរឿងបែបនេះ។"

129 នោះគឺវាជ្រុលពេកសម្រាប់—ការគិតរបស់ខ្ញុំ។ ខ្ញុំនិយាយ "លោកខ្ញុំចង់និយាយ ខ្លះពីចំណុចនោះ។"

និយាយ "តើអ្នកចង់និយាយអ្វី?"

130 ខ្ញុំនិយាយ "អ្នកឃើញទេ អ្នកមិនបានអានព្រះគម្ពីរ ត្រឹមត្រូវទេ។" ខ្ញុំនិយាយ "ព្រះគម្ពីរនិយាយថាមានត្រីបាឡែនពិសេស។ 'ព្រះជាម្ចាស់រៀបចំត្រីធំ' នេះជាការរៀបចំពិសេសមួយ ដែលអាចលេបគាត់បាន នោះហើយសម្រាប់ឲ្យវាធ្វើបាន! វាមិន មែនជាត្រីធម្មតាទេ។ ព្រះជាម្ចាស់ធ្វើការងារមិនធម្មតា ដូច្នេះព្រះអង្គមានត្រីមិនធម្មតា។" ឃើញ? គាត់មិននិយាយអ្វីពីនោះទៀតទេ។ ដូច្នេះ ព្រះជាម្ចាស់មានអ្វីពិសេស។

131 ដូចជាកាលមានក្មេងស្រីតូចម្នាក់ចេញពីរោងឧបោសថ សក់របស់គាត់សិតទៅក្រោយ រលោង ល្មមអាចឃើញមុខតូចរបស់គាត់ដូចជាខ្ចីមបារាំង។ គាត់ដើរទៅមានព្រះគម្ពីរទៅជាមួយ។

132 មានបុរសចាស់ម្នាក់ឈ្មោះ ជីម ដសស៊ី រស់នៅក្នុងរដ្ឋយូទីកា។ គាត់ជាអ្នកមិនជឿសាសនា ជាទាហានចាស់ ហើយ—ហើយ គាត់មិនជឿលើព្រះជាម្ចាស់ឡើយ។ ហើយគាត់និយាយ "អ្នកទៅណា ក្មេងស្រីតូច?"

នាងនិយាយ "ចាសខ្ញុំទៅផ្ទះ លោកតា។"

និយាយ "អ្នកកំពុងកាន់អ្វីក្នុងដៃ?"

និយាយ "ជាព្រះគម្ពីរ។"

និយាយ "អ្នកមិនជឿទេ មែនទេ?" ហើយគាត់...

និយាយ "ចាស ខ្ញុំជឿណា លោកតា។"

133 ហើយនិយាយ "តើអ្នកជឿរឿងនៅក្នុងនោះទេ ពីត្រីបាឡែនលេបយ៉ូណាស?"

និយាយ "ហេតុអ្វី ប្រាកដណាស់ ខ្ញុំជឿគ្រប់ពាក្យទាំងអស់។"

134 គាត់និយាយ "តើអ្នកអាចបង្ហាញអ្វីមួយទៀតក្រៅពីជំនឿ អ្វីទៅដែលហៅថាជំនឿនោះ?"

"ហេតុអ្វី" នាងនិយាយ "ពេលខ្ញុំទៅស្ថានសួគ៌ខ្ញុំនឹងសួរយ៉ូណាស" ឃើញទេ?

គាត់និយាយ "យ៉ាងម៉េចដែរ បើគាត់មិននៅទីនោះ?"

135 នាងនិយាយ "ដូច្នេះអ្នកត្រូវសួរគាត់។" ដូច្នេះខ្ញុំគិតថាវាជាការល្អដែលត្រូវពង្រឹង។ ហើយខ្ញុំគិតថាប្រហែលត្រូវហើយ។

136 បើព្រះគម្ពីរនិយាយថា យ៉ូណាសលេបត្រីបាឡែន ខ្ញុំអាចជឿ។ ទ្រង់អាចរៀបចំបែបនេះ។ តែព្រះជាម្ចាស់មានបន្ទូល ព្រះអង្គអាចធ្វើបាន ហើយព្រះអង្គតែងរក្សាព្រះបន្ទូលព្រះអង្គ។ ដូច្នេះ យ៉ូណាស យើងនិយាយលេងពីគាត់ទេ...

137 ប៉ុន្តែអ្នកធ្លាប់សម្គាល់ពីត្រីពេលវាហែលទេ? វាស្វែងរកចំណីរបស់វា។ ហើយពេលវាស៊ី វាស៊ីធ្លាក់ទៅបាតពោះបំផុតហើយផ្ទុកនៅទីនោះ។ សាកដាក់ចំណីអោយត្រីមាសរបស់អ្នកហើយចាំមើលមានអ្វីកើតឡើង។ ពេលពោះរបស់វាឆ្អែត ចំណីនឹងធ្លាក់ចុះ ហើយជាប់នៅបាតពោះ ហើយទុកនៅទីនោះ និង គ្មានរំខានអ្វីឡើយ។

138 ល្អ នេះជាការរៀបចំត្រីអោយមក និង លេបព្យាការីនេះ។ ហើយវាចុះទៅបាតសមុទ្រ ហើយមានជំរៅប្រហែលសែសិបព្យាម។ គាត់ចូលទៅ ហើយសម្រាកនៅក្នុងពោះត្រីនៅបាតសមុទ្រ។

139 ឥឡូវ យើងតែងគិតពីយ៉ូណាស។ ហើយគ្រប់គ្នានិយាយ "ឥឡូវខ្ញុំអធិស្ឋានហើយ តែដៃរបស់ខ្ញុំមិនធូរសោះ។ ខ្ញុំអធិស្ឋាន ប៉ុន្តែខ្ញុំមិនមានអារម្មណ៍ថាស្បើយឡើយ។" តើអ្នកមិនធ្លាប់ស្រែកដាក់យ៉ូណាសទេ។

140 ឥឡូវមើលអាការៈដែលគាត់មាន។ ឥឡូវ ដំបូង គាត់ចេញពីព្យុះរបស់សមុទ្រ ហើយគាត់បានចេញពីគោលដៅដែលព្រះជាម្ចាស់បញ្ជូនគាត់ឲ្យទៅ។ ដៃនិងជើងរបស់គាត់ជាប់ចំណង។ គាត់ត្រូវបានគេបោះចូលទៅក្នុងសមុទ្រព្យុះដែលខ្ជួលខ្ជាញ់ ហើយត្រីបាឡែនលេបគាត់ហើយចុះតាមបំពង់អាហារទៅបាតសមុទ្រ។ ហើយ គាត់ដេកនៅទីនេះជាមួយកំអួត នៅក្នុងពោះត្រី មានសារ៉ាយរុំករបស់គាត់។ បើសិនជាគាត់គិតថា *នេះ*ជាផ្លូវ វាជាពោះត្រីបាឡែន។ គាត់មើលទៅផ្លូវ*នោះ* ក៏នៅតែជាពោះត្រីបាឡែន។ គ្រប់កន្លែងដែលគាត់មើលឃើញ គឺនៅក្នុងពោះត្រីបាឡែន។ អ្នកនិយាយពីករណីអាការៈ ដែលគាត់អាចមាន។ ប៉ុន្តែអ្នកដឹងថាគាត់និយាយអ្វីទេ? គាត់និយាយ "អ្វីទាំងអស់សុទ្ធតែឥតប្រយោជន៍។ ខ្ញុំនឹងមិនមើលទៀតឡើយ ប៉ុន្តែទូលបង្គំសម្លឹងមើលតំណាក់វិសុទ្ធរបស់ព្រះអង្គវិញ។"

141 សម្រាប់ស្តេចសាឡូម៉ូនជាមនុស្សនិស្ស័យនៅលើផែនដីជាអ្នកដែលអធិស្ឋានថ្វាយព្រះវិហារ និយាយថា "ឱព្រះអម្ចាស់បើរាស្ត្ររបស់ព្រះអង្គមានអាសន្ននៅកន្លែងណា ពេលគេសម្លឹងមើលទីវិសុទ្ធនេះ សូមព្រះសណ្តាប់ពីស្ថានសួគ៌។"

142 ហើយ យ៉ូណាសមានជំនឿនៅក្នុងសេចក្តីអធិស្ឋានរបស់សាឡូម៉ូន។ ហើយព្រះជាម្ចាស់បានរំដោះគាត់ពីត្រីបាឡែន បន្ទាប់ពីរយៈពេលបីថ្ងៃបីយប់។ ប្រហែលជាព្រះអង្គដាក់អ៊ុកស៊ីសែននៅក្នុងនោះ។ ខ្ញុំមិនដឹងថាព្រះអង្គធ្វើអ្វីឡើយ ប៉ុន្តែព្រះអង្គរក្សាជិវិតគាត់បីថ្ងៃបីយប់ ស្របតាមព្រះបន្ទូល។ ហើយព្រះបន្ទូលគឺត្រឹមត្រូវ។

143 ល្អ បើយ៉ូណាសស្ថិតនៅក្នុងកាលៈទេសៈនោះ អាចមើលឆាងឧបោសថដែលមនុស្សធ្វើ នោះតើវាល្អប៉ុណ្ណាទៀតដែលអ្នកនិងខ្ញុំនៅយប់នេះ ត្រូវសម្លឹងមើលព្រះវិហារដែលព្រះគ្រិស្តគង់នៅខាងស្តាំនៃព្រះរាជបល្ល័ង្ករបស់ព្រះ ជាមួយព្រះលោហិតព្រះអង្គធ្វើការទូលអង្វរនៃការបញ្ជាក់ការពិត ពីអាការៈរោគសញ្ញារបស់យើង! សូមកុំកាត់ទោសយ៉ូណាស ហើយចូរសម្លឹងមើលអ្វីដែលអ្នកខុសវិញ។ សូមមើលសេចក្តីសន្យា "ព្រះជាម្ចាស់មានបន្ទូលបែបនេះ!" បើអ្នករាល់គ្នាជាកូនរបស់លោ

កអ័ប្រាហាំ "ព្រះអង្គមានបន្ទូលបែបនេះ!" ព្រះអង្គធ្វើសេចក្តីសន្យា ហើយក៏តាំងវាឡើង។

144 សម្គាល់ មនុស្សទាំងអស់នាំគ្នាចេញទៅស្ទូចត្រី ហើយទាញសំណាញ់យើង និងប្រដាប់ប្រដាផ្សេងៗ។ បន្ទាប់ពីមួយរយៈ ទាញមកបានព្រះសមុទ្រ ជាត្រីបាឡែនទាញយកមកដាក់មាត់ច្រាំងភ្លាមៗ។ គ្រប់គ្នាលុតជង្គង់។ ព្រះជាម្ចាស់ជ្រាបពីរបៀបដែលត្រូវធ្វើ។ ហើយត្រីនោះមកដល់ឆ្នេរ ហើយលៀនអណ្តាត ហើយពេលធ្វើដូច្នេះ មានព្យាការីម្នាក់ដើរចេញពីមាត់ត្រីបាឡែន។ ព្យាការី! ព្រះនោះបានខ្ជាក់ព្យាការីចេញមកលើច្រាំង។ គ្មានអ្វីឆ្ងល់ទេ ដែលពួកគេប្រែចិត្ត។ ឃើញទេ?

145 នោះជាទីសម្គាល់។ យ៉ូណាសត្រូវបានចេញពីត្រីបាឡែន នោះជាទីសម្គាល់។ តើគាត់ធ្វើអ្វី? នោះជាទីសម្គាល់ពីព្រះជាម្ចាស់។ តើសម្លេងនិយាយពីអ្វី? "បើមិនប្រែចិត្តអ្នកនឹងវិនាស ក្នុងរយៈពេលសែសិបថ្ងៃទៀត។" ទីសម្គាល់របស់ព្រះជាម្ចាស់ សម្លេងព្រះជាម្ចាស់! ជានិច្ចកាល ពេលព្រះជាម្ចាស់បញ្ជូនទីសម្គាល់ព្រះជា ម្ចាស់បញ្ជូនសម្លេងព្រះអង្គពីក្រោយទីសម្គាល់។ កត់ចំណាំ"បើមិនប្រែចិត្តអ្នកនឹង វិនាសក្រុងទាំងមូលនៅក្នុងរយៈពេលសែសិបថ្ងៃទៀត។"

146 លោកយ៉ូហាន ជាព្យាការីលេចចេញនៅលើផែនដី បន្ទាប់ពីរយៈពេលរាប់រយឆ្នាំដោយគ្មានព្យាការី ទីសម្គាល់បន្ទាប់ពីបួនរយឆ្នាំ គាត់លេចចេញមក។ នោះជាពេលធូស្រាលបន្តិច!

147 ឥឡូវ បើអ្នកជាមនុស្សព្រលឹងវិញ្ញាណ អ្នកនឹងយល់ពីអ្វីដែលខ្ញុំនិយាយ។ សូមឲ្យព្រះជាម្ចាស់បើកការយល់ដឹងរបស់អ្នក។ តើវាយូរប៉ុណ្ណាហើយ!

148 បួនរយឆ្នាំ អ៊ីស្រាអែលមិនមានព្យាការី ក្រុមជំនុំត្រូវបង្កាច់ខូច ហើយក៏មានយ៉ូហានលេចចេញមក។ យ៉ូហានជាព្យាការី ទីសម្គាល់ដែលព្រះមេស៊ីនឹងមានបន្ទូលបន្ទាប់ពីគាត់។ មើល។ ព្រោះម៉ាឡាគី៣ និយាយ "យើងចាត់ទូតរបស់យើងអោយទៅមុន ដើម្បីរៀបចំផ្លូវសំរាប់យើងរៀបចំមនុស្ស។"

149 មើលទៅយ៉ូហាន គ្មានភាពអាត្មានិយមនៅក្នុងគាត់ឡើយ។ គាត់មិនដែលរកសិរីល្អណាមួយ។ គេព្យាយាមហៅគាត់ថាជាព្រះមេស៊ី ប៉ុន្តែគាត់និយាយថា "ខ្ញុំមិនមានឋានៈនឹងស្រាយខ្សែរស្បែកជើងព្រះអង្គផង។"

150 ប៉ុន្តែពេលដែលព្រះយេស៊ូរៀបចំព្រះអង្គទ្រង់ ព្រះអង្គមានទីសម្គាល់ ជាសសរភ្លើង មានពន្លឺពីលើព្រះអង្គ ដូចជាសត្វព្រាបចុះមកព្រមដោយសម្លេងនិយាយ "នេះជាបុត្រស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់។"

151 សម្គាល់ ពេលនោះយ៉ូហាននិយាយភ្លាម "ព្រះអង្គត្រូវតែចំរើងឡើង ហើយខ្ញុំត្រូវតែបន្ទាបចុះ។" គាត់ណែនាំក្រុមជំនុំមកកាន់ព្រះគ្រិស្ត។ អាម៉ែន។

152 យើងត្រូវបានប្រាប់មកថា នៅថ្ងៃចុងក្រោយនឹងមានកើតឡើងម្តងទៀត! នឹងមានសារមកទៀត នឹងបង្ហាញពីព្រះមេស៊ីទៅកាន់មនុស្ស។ ហើយវានឹងដូចរបៀបនេះ ពួកគេនឹងឈរស្រឡាំងកាំងដូចពួកគេធ្លាប់ធ្វើ។ ព្រះអង្គសន្យា។ រួចជំពូកបន្ទាប់នៅក្នុងគម្ពីរម៉ាថាយ ម៉ាឡាគី ប្រាប់ពីរឿងនោះ។ សូមមើល។

153 ពួកគេសួរពីការនោះ។ លក្ខណៈនិស្ស័យរបស់យ៉ូហានសម្គាល់ព្រះអង្គនៅក្នុងវិញ្ញាណនៃអេលីយ៉ា។ ឥឡូវសម្គាល់ពីព្យាការីពីរនាក់។

154 ឥឡូវអេលីយ៉ាជាមនុស្សម្នាក់ដែលងើប ឡើងក្នុងពេលដែលប្រទេសអ៊ីស្រាអែលមានភាពរីករវ។

155 អាហាប់គឺជាស្តេច។ ហើយស្ត្រីត្រូវបានសើចចំអកតាមយ៉េសេបិល ហើយប្រហែលជាមានម៉ូដសក់ក្បាលទឹក និងគ្រប់យ៉ាងដូចយើងសព្វថ្ងៃនេះហើយមើលទៅ។ ហើយអ្វីៗទាំងអស់ស្រេចតែតាមយ៉េសេបិល។ ហើយគំនិតរបស់គ្រូគង្វាលគិត "នោះគឺមិនអីទេ។ ទុកអោយគេធ្វើតែគេទៅ។ ទុកឲ្យពួកគេធ្វើចឹងចុះ។"

156 ហើយនៅពេលនោះ ព្រះជាម្ចាស់លើកមនុស្សម្នាក់ឡើងចេញពីវាលរហោស្ថាន មានឈ្មោះថាអេលីយ៉ា។ យើងមិនទាំងដឹងថាគាត់មកពីណាផង។ គាត់មិនមានសាលាណាដែលបញ្ជាក់ចំពោះអត្តសញ្ញាណគាត់ឡើយ។ ប៉ុន្តែគាត់ងើបឡើង ហើយគាត់កាត់ទោសរឿងផ្សេងៗទាំងនោះ។ គាត់កាត់ទោសប្រព័ន្ធទាំងមូល។

157 បើគាត់អាចចូលមកក្នុងសាច់រឿងសព្វថ្ងៃ គាត់ក៏អាចកាត់ទោសប្រព័ន្ធយើងរៀបចំដែរ។

158 គាត់កាត់ទោសគ្រប់ទាំងយ៉េសេបិលទាំងអស់។ ហើយ វាទីបំផុតគឺជាគាត់ដែលសម្លាប់ព្យាការី។ គេរត់គេ ដូចជាលោកយ៉ូហាន ដេកនៅក្រោមដើម ជូនីពើ ពេលដែលយ៉េសេបិលនឹងសម្លាប់គាត់។ នាងស្អប់គាត់។

159 ហើយយើងឃើញថាពេលយ៉ូហានមកដល់ ចេញពីវាលរហោស្ថានម្តងទៀត ជាអ្នកស្រឡាញ់វាលរហោស្ថាន ជាមួយសារត្រង់ៗទៅកាន់ស្ត្រីទំនើបដែលរស់នៅលែងប្តី និងរៀបការម្តង ហើយម្តងទៀត គាត់កាត់អ្វីៗជាចំរៀក។ គាត់មិនចេញមកពីសាលាណាទេ។ គាត់មកពីព្រះជាម្ចាស់ ជាមនុស្សដែលបានបញ្ជូនមកពីព្រះជាម្ចាស់។ ហើយគាត់កាត់ទោសស្ត្រីទំនើប ទាស់នឹងគេយ៉ាងខ្លាំង ហើយគាត់មិនដែលបញ្ចេញកណ្តាប់ដៃឡើយ។ ប៉ុន្តែគាត់និយាយយ៉ាងច្រើន "ពេលវេលាមកដល់ហើយ ព្រះមេស៊ីនឹងមានបន្ទូល។" ពិនិត្យមើលចុះ។

160 ឥឡូវសូមប្រៀបធៀបពេលវេលាអេលីយ៉ាដំបូងជាមួយនឹងព្យាការីទំនើបបច្ចុប្បន្ន ទុកឲ្យយ៉េសេបិលកាត់សក់របស់ពួកគេ ហើយស្លៀកខ្លី ជក់បារី អ្វីៗដែលគេចង់ធ្វើ ដឹកនាំគេវិលវល់។ មិនបាច់និយាយល្អជាង នាងចាកចេញពីប្រុសម្នាក់ ហើយយកបុរសម្នាក់ទៀត។ ដឹកនាំពួកពួកគេដោយច្បាប់មនុស្សបង្កើត នោះជាការអាម៉ាស់ ជាគោលលទ្ធិនៃមនុស្ស។ ហើយ ដោយធ្វើរបៀបនោះ ពួកគេធ្វើឲ្យបញ្ញាតិរបស់ព្រះជាម្ចាស់គ្មានប្រសិទ្ធិភាព ព្រោះពួកគេអាចចូលរួមក្រុមជំនុំហើយអះអាងថាជាគ្រិស្តបរិស័ទ ហើយក្តោបសិទ្ធិរបស់គេ និង និយាយថាពួកគេជាគ្រិស្តបរិស័ទ និង មានទៀត។ នោះជាអ្វីដែលពួកគេចង់បាន។ ហើយនោះជាអ្វីដែលគេធ្វើ។

161 ប៉ុន្តែ សូមចងចាំ វាជាពេលនៃបែបនោះ ដូចជាព្រះជាម្ចាស់សន្យានៅក្នុងគម្ពីរម៉ាឡាគី៤ ព្រះអង្គបំពេញតាមព្រះបន្ទូលម្តងទៀត។ នោះជាការពិត។ មើលយើងនាបច្ចុប្បន្ន ដូចជាសម័យកាលលោកយ៉ូហានដែរ ដូចជាពេលមួយទៀត។

162 មើលទៅលោកអេម៉ូសកំសត់ម្នាក់នេះដែលងើបឡើង ជាមិត្តតូចចាស់ម្នាក់។ យើងមិនដឹងថាគាត់មកពីណាទេ។ គាត់ជាអ្នកចិញ្ចឹមហ្វូងសត្វ។ ព្រះជាម្ចាស់យកគាត់ចេញពីវាលស្មៅចិញ្ចឹមចៀម និងចេញពីវាលស្មៅចិញ្ចឹមគោ និង បង្វឹក គាត់។ ហើយពេលគាត់មកដល់សាម៉ារី ហើយពេលគាត់ងើបឡើងនៅលើភ្នំនៅពេលនោះ មើលទៅក្រោម។ ហើយពន្លឺព្រះអាទិត្យចាំងលើក្បាលទំពែករបស់គាត់ និងសក់ប្រផេះគាត់ដែរ ហើយភ្នែកគាត់ទាំងពីរសម្លឹងមើលពន្លឺ។ ភ្នែករបស់ គាត់ ធ្មេចៗ

គឺមិនមែនរូបភាពដែលអ្នកទេសចរបានឃើញទេ ព្រោះក្រុងទាំងមូលបានប្រព្រឹត្តធ្លាក់ទៅក្នុងបាប។

163 នរណាជា មនុស្សតូចម្នាក់ជាទីកត់សម្គាល់នេះ? បាទ គឺជាលោកអេម៉ូស ជាព្យាការី។ ទំនាយរបស់គាត់ដែលថ្លែងក្នុងរាជយេរ៉ូបោមទីពីរ ជាស្តេចលះបង់ជំនឿអនុញ្ញាតិឲ្យមនុស្សធ្វើអ្វីក៏បាន។ ហើយពួកសង្ឃនៅគ្រប់កន្លែងនោះ។ គេសង់ព្រះវិហារស្អាតៗ។ គេស្លៀកពាក់ស្អាតៗ។ ហើយស្រីៗរបស់ពួកគេអសីលធម៌។ ពួកគេ ស្លៀកអីក៏បាន ទៅកន្លែងណាដែលចង់ទៅ។ អ្នកទេសចរចូលមកមើលផ្គុំគ្នាគ្រប់កន្លែង ដើម្បីមើលស្រីស្អាត និង បន្តដូច្នេះទៀត។

164 ដូចជា អាមេរិក ទំនើបមួយទៀតដែរ ដែលគិតថាជារាស្ត្ររបស់ព្រះជាម្ចាស់។ គ្មាននរណានិយាយអ្វីពីរឿងនោះទេ។ វាដូចជាការចាប់ទាញមនុស្ស។ ប្រាំ...

165 រយៈពេលដប់ប្រាំបីឆ្នាំហើយមកដល់ឥឡូវ! ពេបេការរបស់ខ្ញុំ អាយុដប់ប្រាំបីឆ្នាំហើយ បច្ចុប្បន្ន។ ដប់ប្រាំបីឆ្នាំ ខ្ញុំដើរកាត់ទូទាំងប្រទេសនេះ ថ្កោលទោសរឿងទាំងនេះ។ ហើយពេលខ្ញុំត្រឡប់មកវិញ ពីមួយឆ្នាំទៅមួយឆ្នាំ មានស្រីៗដែលបួងសក់កាន់តែច្រើនឡើងៗ នោះជាពេលដំបូងដែលខ្ញុំចាប់ផ្តើម។

166 អ្នកអធិប្បាយពេនទីកុស្តដ៏ល្បីនាំខ្ញុំទៅក្នុងបន្ទប់ ប្រហែលមួយឆ្នាំមុនជាមនុស្ស ល្អ ល្បីល្បាញ ជាអ្នកល្បីម្នាក់ទូទាំងពិភពលោក។ គាត់និយាយ ខ្ញុំ..."បងប្រុសប្រានហាំ ចូរឲ្យខ្ញុំដាក់ដៃលើអ្នកនិង អធិស្ឋានសម្រាប់អ្នក។"

ខ្ញុំនិយាយ "ខ្ញុំមិនឈឺទេ។"

167 គាត់និយាយ "ប៉ុន្តែមានអ្វីមួយខុសហើយ។" គាត់និយាយ "បងប្រុសប្រាន ហាំអ្នកបំផ្លាញ ពន្ធ័កិច្ចរបស់អ្នកហើយ។ នឹងគ្មានអ្នកសហការជាមួយឡើយ។ ជាការ ពិតណាស់គ្រូអធិប្បាយមិនសហការជាមួយអ្នកឡើយ គឺរបៀបដែលអ្នកថ្កោលទោសស្ត្រី។" គាត់និយាយ "ពួកគេហៅអ្នកថាជាព្យាការី។"

ខ្ញុំនិយាយ "ខ្ញុំមិនដែលហៅខ្លួនខ្ញុំថាព្យាការីឡើយ។"

168 គាត់និយាយ "ប៉ុន្តែពួកគេហៅអ្នកថាដូច្នេះ។" គាត់និយាយ "ខ្ញុំជឿដូចគ្នា។" គាត់និយាយ "អ្នកត្រូវបានត្រាស់ហៅឲ្យអធិស្ឋានសម្រាប់អ្នកជំងឺ។" គាត់និយាយ "ចូរអធិស្ឋានសម្រាប់អ្នកជំងឺ ហើយទុកស្ត្រីឲ្យនៅតែគេទៅ អ្នកធ្វើឲ្យអារម្មណ៍គេឈឺចាប់ហើយ។"

ខ្ញុំនិយាយ "ដោយរបៀបណា?"

169 គាត់និយាយ "និយាយពីរឿងសក់ខ្លី និង អ្វីៗនោះ។"

ខ្ញុំនិយាយ "គឺវាខុស។"

170 ព្រះគម្ពីរនិយាយថា "ស្ត្រីណា—កាត់សក់ខ្លី ប្តីរបស់នាងមាន សិទ្ធិលែង លះនាងបាន។" ជាការត្រឹមត្រូវណាស់។ "នាងបានបង្ខូចក្បាលរបស់នាងហើយ។" នោះជាអ្វីដែលព្រះគម្ពីរនិយាយ។ ឥឡូវខ្ញុំមិនដឹងថាអ្នកចូលចិត្តឬអត់ ប៉ុន្តែនោះជាអ្វីដែលព្រះគម្ពីរនិយាយ នៅក្នុងកូរិនថូសខ្សែរទីមួយ។

171 [ខ្សែរអាត់សម្លេងទទេ—Ed។]...រឺបស្បែកខ្មៅ រហូតដល់ចេញក្រៅ។ ហើយពួកគេ—មកក្រវែលៗនិយាយថា "ហេតុអ្វី លោកប្រានហាំ នោះជាសម្លៀកបំពាក់ដែលគេដាក់លក់។"

172 ពួកគេនៅមានម៉ាស៊ីនដេរល្អៗ។ គ្មានអ្វីត្រូវដោះសារឡើយ។ ស្ត្រី អាមីស និង ដាំងកាដនៅស្លៀកនៅឡើយ។ ប្រាកដណាស់។ [ក្រុមជំនុំទះដៃ—Ed។]

ហើយ អ្វីកើតឡើង? ពួកគេចញទៅហើយបន្ត។

173 ស្ត្រីម្នាក់និយាយ "ល្អ បងប្រុសប្រានហាំ ខ្ញុំមិនស្លៀកខ្លីទេ។ ខ្ញុំស្លៀកខ្ល-..." ស្អីគេនោះ ជាអៀម-...[បងប្រុសម្នាក់ និយាយ "អៀម"—Ed។] បាទ។ គាត់និយាយ "ខ្ញុំស្លៀកវា។"

174 ខ្ញុំនិយាយ "នោះកាន់តែអាក្រក់ទៀត។" ខ្ញុំនិយាយ "ព្រះគម្ពីរនិយាយ 'វាកាន់តែគួរឲ្យស្អប់ខ្ពើមទៅទៀតចំពោះស្ត្រីណាស្លៀកសម្លៀកបំបាក់សម្រាប់បុរស។'" តើនោះមើលទៅជាការអាក្រក់យ៉ាងណា នៅសហរដ្ឋអាមេរិកឥឡូវ! ឃើញទេ? នោះជាការពិត។

175 ចូរឲ្យខ្ញុំប្រាប់អ្នករឿងខ្លះ ប្អូនស្រី។ អ្នកអាចស្អាតដូចជាផ្កា សម្រាប់ប្តីនិងមិត្តប្រុសរបស់អ្នក ប៉ុន្តែនៅថ្ងៃជំនុំជម្រះអ្នកនឹងត្រូវឆ្លើយតបចំពោះការធ្វើកំផិត។ ព្រះយេស៊ូមានបន្ទូលថា "នរណាដែលសម្លឹងមើលទៅកាន់ស្ត្រី ហើយមានចិត្តសម្រើប អ្នកនោះបានធ្វើការកំផិតហើយ។" បើសិនជាមនុស្សមានបាបគេសម្លឹងមើលអ្នកអ្នកត្រូវតែឆ្លើយតបចំពោះថ្ងៃជំនុំជម្រះ។ អ្នកបង្ហាញខ្លួនចំពោះគាត់។ សមនឹងអ្នកហើយ។ អូ-ហូ។

176 ហេតុអ្វីបានជាស្ត្រីកោតខ្លាចព្រះចង់ស្លៀកបែបនោះ? ហើយប្រកាសថា មានព្រះវិញ្ញាណបរិសុទ្ធ ដោយសារអ្នកនិយាយភាសាដទៃ និងរត់ចុះឡើងលើកម្រាល? គឺយ៉ាងនោះក៏ដោយ ខ្ញុំឃើញសាសន៍ដទៃធ្វើបែបនោះ Hottentots។ ព្រះវិញ្ញាណបរិសុទ្ធមានភាពវិសុទ្ធ បរិសុទ្ធ គ្មានភាពអាក្រក់។ ជាការពិតណាស់។

177 មនុស្សប្រុសនេះ និយាយថា "បើអ្នក...គេជឿថាអ្នកជាព្យាការី។ ហេតុអ្វីបានជាអ្នកមិនបង្រៀនគេពីរបៀបទទួលអំណោយទានព្រះវិញ្ញាណដ៏អស្ចារ្យ និង របៀបធ្វើអ្វីៗថ្វាយព្រះជាម្ចាស់? ហេតុអ្វីអ្នកមិនបង្រៀនពួកគេ បើអ្នកជាព្យាការីហើយនោះ?"

178 ខ្ញុំនិយាយ "តើខ្ញុំអាចបង្រៀនពួកគេពីគណិតវិទ្យាយ៉ាងណា បើពួកគេមិនរៀន អេ ប៊ី ស៊ី របស់ពួកគេផងនោះ?" អ្នកដឹងហើយថា អេ ប៊ី ស៊ី មានន័យយ៉ាងណា? តែងតែជឿព្រះគ្រិស្ត។ អូ-ហូ។ តើអ្នកអាចធ្វើយ៉ាងដូច្នេះ ម្តេចបាន? ឃើញទេ អ្នកចង់ចេញដល់ពីត្រង់*នោះ* ជំនួសឲ្យចាប់ផ្តើមត្រង់*នេះ*។

179 ព្រះជាម្ចាស់នឹងសង់ក្រុមជំនុំព្រះអង្គលើគ្រឹះព្រះយេស៊ូគ្រិស្ត ហើយនោះគឺជាព្រះគម្ពីរ។ ក្រៅពីនោះ ដីផ្សេងទៀត គឺជាខ្សាច់ដែលលិចចុះប៉ុណ្ណោះ។ ព្រះអង្គមិនប្រែប្រួលឡើយ។ និស្ស័យព្រះអង្គក៏មិនប្រែប្រួលដែរ។

180 ព្រះអង្គបង្កើតមនុស្សស្រីខុសពីមនុស្សប្រុស ហើយមនុស្សប្រុសខុសពីមនុស្សស្រី។ ព្រះអង្គស្លៀកពាក់ឲ្យពួកគេខុសគ្នា ហើយព្រះអង្គសព្វព្រះទ័យឲ្យពួកគេស្លៀកបែបនោះ។ ឃើញទេ? មនុស្សស្រីចង់ស្លៀកពាក់ដូចមនុស្សប្រុស ហើយមនុស្សប្រុសចង់ដូចមនុស្សស្រី។ អូ ខ្ញុំ! ជាការជជេស! វា...ហើយរបស់ទាំងអស់ វាដូចជាកញ្ចប់ដៃមនុស្សម្នាក់លើមនុស្សផ្សេងៗ អ្នកមិនអាចផ្លាស់ប្តូរវាបានឡើយ។ មើលទៅដូចជាសត្វចម្លែក ភាពខ្មៅធំមួយ នោះបើអ្នកយល់ពីអ្វីដែលខ្ញុំចង់និយាយ ក្នុងវិញ្ញាណ។ សត្វចម្លែកបានចាប់ក្តោបពួកគេ ហើយពួកគេ—ពួកគេមិនអាចចេញឆ្ងាយទៅបាន ងប់ងុលនឹងហូលីវូដជ្រុល មើលទូរទស្សន៍ជ្រុល ជ្រុលជាមួយអ្វីផ្សេងៗមិនសមទំនង។ អ្វីដែលយើងមាននោះកខ្វក់ហើយ។ មិនឆ្ងល់ទេ "បើការនោះមិនកាត់ឲ្យខ្លី ដើម្បីយល់ដល់អ្នករើសតាំង នឹងគ្មានសាច់ណាបានសង្គ្រោះឡើយ។"

181 អ្នកនិយាយ "ខ្ញុំមិនដែលដឹងរឿងនោះពីមុនឡើយ។" ល្អ ឥឡូវអ្នកស្គាល់វា ពីឥឡូវទៅ។ ឃើញ? នោះគឺ...ខ្ញុំឈប់ប្រសើរជាង។ ត្រឡប់ទៅវិញ។ ចូរសម្គាល់។

182 យ៉ូហានជាទីសម្គាល់។ ហើយចងចាំថា របៀបដែលព្រះអង្គធ្វើ វា ជាលើកដំបូង ហើយនោះជារបៀបដែលព្រះអង្គនឹងធ្វើម្តងទៀត។ ព្រះអង្គសន្យា។ ឥឡូវ ព្រះអង្គពិតជាប្រើក្រុមមនុស្ស ពេលណាក៏បាន សម្រាប់រឿងនោះ។

183 ចងចាំ មានក្រុមមួយ នោះគឺ មានមនុស្សធំម្នាក់ឈ្មោះអាហាប់ គាត់ធ្វើឲ្យគាត់...គាត់យកព្យាការីជនជាតិអ៊ីស្រាអែលបួនរយនាក់។ ឥឡូវ ពួកគេមិនមែនជាព្យាការីសាសន៍ដទៃឡើយ។ ជាព្យាការីជនជាតិអ៊ីស្រាអែលបួនរយនាក់។ ពួកគេមានសញ្ញាប័ត្រ និង គ្រប់យ៉ាងនៅសាលាធំ។

184 មានបុរសម្នាក់ដែលកោតខ្លាចព្រះជាម្ចាស់ឈ្មោះថាយ៉េហូសាផាត ជាស្តេចលើស្រុកយូដា ហើយគាត់ចូលមក។ ហើយមានអ្នកជឿលាយគ្នាជាមួយអ្នកមិនជឿ។ អ្វីៗប្រព្រឹត្តិទៅខុស។

185 ហើយគាត់និយាយថា "រ៉ាម៉ូត-កាឡាដ។" ឥឡូវសូមមើល តើការពិតអាចជាយ៉ាងណា។ គាត់និយាយ "រ៉ាម៉ូដ-កាឡាដជាកម្មសិទ្ធិរបស់យើង នៅទីនោះ។ ទៅដល់ប្រទេសនោះ នោះជារបស់យើង។" យ៉ូស្វេបានចែកទឹកដី ឲ្យដីនោះទៅអ៊ីស្រាអែល។ ហើយភីលីស្ទីន ជាសាសន៍ដទៃ បានមកយកដីនោះធ្វើជារបស់ខ្លួន។ គាត់និយាយ "នោះជារបស់យើង។"

186 ឥឡូវពិនិត្យមើលគោលការណ៍ មនុស្សអាចត្រូវហើយក៏អាចខុសដែរ។ អ្វីនោះជារបស់អ៊ីស្រាអែល។ ប៉ុន្តែសម្រាប់សេចក្តីសន្យាទាំងអស់របស់ព្រះ បងប្អូនអើយ គឺមានលក្ខខណ្ឌ មើល "បើសិនពួកគេដើរក្នុងផ្លូវព្រះអម្ចាស់។"

187 ឥឡូវសូមមើលទីនេះ។ គាត់និយាយ "តើអ្នកនឹងទៅជាមួយខ្ញុំឬ ហើយជួយខ្ញុំឲ្យយកទឹកដីនោះមកវិញ? ល្អ នោះគឺត្រូវតែដូច្នេះ ពួកក្មេងៗភីលីស្ទីនចំអែតពោះដោយទឹកដីនោះ ជាមួយស្រូវសាឡីដែលជាកម្មសិទ្ធិរបស់អ៊ីស្រាអែល។" តាមបទគម្ពីរជាការត្រឹមត្រូវ។ គាត់និយាយ "ជួយខ្ញុំផង ហើយ ទៅយកវា។"

188 និយាយ "ល្អ ខ្ញុំអើយ..." គាត់មានកំហុសត្រង់នោះ។ "រទេះរបស់ខ្ញុំជារបស់អ្នក មនុស្សរបស់ខ្ញុំក៏ដូចជាមនុស្សរបស់អ្នក។ ខ្ញុំនឹងទៅជាមួយអ្នក។"

189 ហើយពេលយ៉េហូសាផាតចាប់ផ្តើមគិត អ្នកដឹងទេ។ "និយាយ តើមិនគួរឲ្យយើងសួរព្រះជាម្ចាស់មុននឹងទៅទេឬ?"

190 "អូ ជាការពិតណាស់" អាហាប់និយាយ "ជាការពិត។ អូ-ហូ។ សូមទោស។ ខ្ញុំ—គួរតែគិតរឿងនោះ។"

"តើមានព្យាការីនៅត្រង់ណាទេ?"

191 "អូ ប្រាកដណាស់ ខ្ញុំមាន—ខ្ញុំមាន—សេចក្តីអធិប្បាយពីពួកគេត្រង់នេះ ជារឿងល្អបំផុតដែលអ្នកមិនធ្លាប់ជួប។ ពួកគេស្លៀកពាក់ស្អាតបំផុត។ ពួកគេជាគ្រូខ្ពង់ខ្ពស់។ ខ្ញុំបានបង្ហាត់ពួកគេ ទៅកាន់ចំណុច។ យើងនឹងនាំពួកគេមក។"

192 ដូច្នេះ ពួកគេទៅ។ ហើយពួកគេហៅមកទាំងអស់គ្នា។ ពួកគេមិនមែនជាអ្នកកុហកឡើយ។ ពួកគេអធិស្ឋានៗៗ រហូតពួកគេឃើញនិមិត្ត។

193 ដូច្នេះពួកគេមក។ ហើយម្នាក់ក្នុងចំណោមពួកគេធ្វើស្នែងធំពីរពីដែក។ គាត់និយាយ "ដោយស្នែងនេះ អ្នកនឹងសង្កត់ពួកភីលីស្ទីនឬ—ពួកអាស៊ីរី ដេញចេញពីទឹកដីបាន។" គាត់និយាយថា "**នេះជាព្រះបន្ទូលព្រះអម្ចាស់**។ ចេញទៅ ព្រះអម្ចាស់គង់នៅជាមួយអ្នក។" ហើយពួកគេទាំងអស់គ្នារួមគ្នាតែមួយ ដោយ វិញ្ញាណ។ ព្យាការីជនជាតិអ៊ីស្រាអែលនិយាយ "ចេញទៅ ព្រះអម្ចាស់គង់នៅជាមួយអ្នក។" អ្នកនិយាយ នេះជាបទគម្ពីរ? "ចេញទៅហើយឲ្យមរតកដល់ប្រជាជន ហើយខ្មាំងកំពុងតែកាន់កាប់។ អ្នកមានសិទ្ធិទៅយកវា។"

ឥឡូវ ពេនទីកុស្ត ខ្ញុំចង់ឲ្យអ្នករៀនមេរៀនត្រង់ចំណុចនេះ។

194 ប៉ុន្តែ យ៉ូហូសាផាតជាមនុស្សកោតខ្លាចព្រះជាម្ចាស់ គាត់និយាយ "មានអ្វីមួយ ដូចជាខុសនៅឡើយ" និយាយ "អ្នកមិនមានហោរាម្នាក់ទៀតទេឬ?"

195 "ម្នាក់ទៀត បន្ទាប់ពីព្យាការីបួនរយនាក់សុទ្ធតែមានការបង្ហឹកហាត់យ៉ាងល្អកំពុងឈរនៅទីនោះ?" កាលបើមានអ្នកជាច្រើននៅត្រង់នេះហើយ។ "គេព្រមគ្នានិយាយថា '**នេះជាព្រះបន្ទូលព្រះអម្ចាស់។**' ត្រឡប់ទៅវិញ និង និយាយថា 'យ៉ូស្វេឲ្យទឹកដីនេះមកយើង។ វាជារបស់យើង។ ទៅយកវាទៅ!'"

196 ប៉ុន្តែ យ៉េហូសាផាត សួររកម្នាក់ទៀត។ និយាយ "តើមិនមាននរណាម្នាក់ទៀតដែលយើងអាចសាកសួរព្រះអម្ចាស់ទេឬ?"

197 គាត់និយាយ "អូ មានម្នាក់ទៀត ប៉ុន្តែ" និយាយ "ខ្ញុំស្អប់គាត់។" អូ-ហូ។ អូ-ហូ។ និយាយ "គាត់គឺជាមីកាយ៉ាជាកូនរបស់អ៊ីមឡា។" និយាយ "ខ្ញុំស្អប់គាត់។ គាត់តែងតែនិយាយអាក្រក់ពីខ្ញុំ។"

និយាយ "សូមព្រះរាជាកុំមានបន្ទូលយ៉ាងនោះឡើយ។ ទៅនាំគាត់មក។"

198 ដូច្នេះគេបញ្ជូនអ្នករត់ការចំពោះរឿងនោះ។ ហើយមានអ្នកខ្លះ នៃពួកគេនិយាយថា "ឥឡូវ មីកាយ៉ា ខ្ញុំចង់ប្រាប់អ្នករឿងខ្លះ។ ឥឡូវ ពួកគេមិនទំនាក់ទំនងជាមួយអ្នក...-ទាក់ទងអ្នកពីការប្រកបគ្នា មិនជាយូរប៉ុន្មាន ព្រោះអ្នកតែងនិយាយអាក្រក់ពីមនុស្ស។ បើសិនជាអ្នកចង់បានកាតប្រកបគ្នាវិញ អ្នកត្រូវនិយាយដូចគ្នាដែលគេធ្វើ ហើយ អូ គេយកសិទ្ធិរបស់អ្នកដាក់ក្នុងដៃ។"

199 ប៉ុន្តែ គាត់កើតឡើងបែបនោះ គាត់គឺជាព្យាការីពិត។ គាត់និយាយ "ដូចជាព្រះអង្គដែលមានព្រះជន្មរស់ ខ្ញុំនិយាយតែអ្វីដែលព្រះអង្គដាក់ក្នុងមាត់របស់ខ្ញុំ។" អូ! ព្រះជាម្ចាស់ប្រទានពរដល់បុរសនោះ។ គាត់និយាយ "រង់ចាំរហូតដល់យប់ និងខ្ញុំនឹងឃើញអ្វីដែលព្រះអម្ចាស់មានបន្ទូលប្រាប់ខ្ញុំ។"

200 ព្រឹកបន្ទាប់ និយាយ "ទៅចុះ ប៉ុន្តែខ្ញុំឃើញអ៊ីស្រាអែលរត់ខ្ចាត់ខ្ចាយដូចជាហ្វូងចៀមឥតអ្នកគង្វាល។" រួចគាត់ចាប់យកនិមិត្តគាត់ និងប្រៀបធៀបជាមួយអ្វីដែលអេលីយ៉ានិយាយ អ្វីកើតឡើងចំពោះអាហាប់។ តើព្រះអង្គអាចឲ្យពរអ្វីដែលព្រះអង្គដាក់បណ្តាសារនោះ? មិនថាវាប៉ុណ្ណាទេ...

201 យើងជាជាតិសាសន៍កោតខ្លាចព្រះជាម្ចាស់។ ក្រុមជំនុំពេនទីកុស្ត បាបទីស្ទ និងមេតូឌីស្ត និងផ្សេងទៀត ជាក្រុមជំនុំគ្រីស្ទាន ប៉ុន្តែអ្នកអាចឲ្យពរអ្វីដែលព្រះជាម្ចាស់ដាក់បណ្តាសសារហើយយ៉ាងណាបាន? ខ្ញុំមិនខ្វល់ អ្នកនិយាយ "ខ្ញុំ—ខ្ញុំចូលរួម*នេះ*។" ខ្ញុំធ្វើ*នេះ*។ នោះមិនមានអ្វីមួយដែលធ្វើជាមួយវាឡើយ។ មើលអ្វីដែលអ្នកបានធ្វើ។ មើលពេនទីកុស្ត មើលពីរបៀបគេទៅរង្គសាល។ មើលអ្វីដែលអ្នកធ្លាប់មក ហើយមើលថាអ្នកឥឡូវ។ មិនគួរឲ្យឆ្ងល់ទេ ភ្នែកគឺ ភ្នែកគឺងងឹតហើយ។

202 ដូច្នេះគាត់ អាហាប់...សង្ឃនេះទះកំភ្លៀងគាត់ចំមាត់។ ហើយនិយាយ "ដាក់គាត់" ហើយអាហាប់និយាយ "ដាក់គាត់នៅទីនេះក្នុងគុក។ បើខ្ញុំមកវិញដោយសុខសាន្ត ខ្ញុំនឹងប្រព្រឹត្តជាមួយគាត់។"

203 គាត់និយាយ "បើសិនជាអ្នកអាចត្រឡប់មកវិញ ព្រះជាម្ចាស់មិនមានបន្ទូលមកខ្ញុំឡើយ។" អូ-ហូ? ឃើញទេ? មានព្យាការី នោះជាទីសម្គាល់ នេះជាសម្លេងរបស់គាត់។ ហើយ បើមិនធ្វើតាម នោះនឹងមានការជំនុំជម្រះ។

204 ព្រះវិញ្ញាណបរិសុទ្ធជាព្យាការីរបស់យើងសព្វថ្ងៃ។ បើមិនស្តាប់តាមសម្លេងរបស់ព្រះអង្គ? ព្រះអង្គត្រូវបានសម្គាល់នៅក្នុងបទគម្ពីរ ថាព្រះអង្គនឹងមានបន្ទូលពីការនេះ។ ព្រះយេស៊ូគ្រិស្ត ជាទម្រង់នៃព្រះវិញ្ញាណបរិសុទ្ធ!

205 ព្រះអង្គធ្វើការជាមួយបុរសម្នាក់នេះ។ នេះ ព្រះជាម្ចាស់មិនដែលធ្វើការជាមួយក្រុមឡើយ វាជាមនុស្សម្នាក់។ អេលីយ៉ាមិនមែនជាក្រុមឡើយ។ យ៉ូណាសក៏មិនមែនជាក្រុមដែរ។ ពួកគេមិនមែនជាក្រុមនៃនិកាយ ក៏ពួកគេម្នាក់ៗមិនមែនជាសមាជិកក្រុមនិកាយដែរ។ ប៉ុន្តែពួកគេទាំងអស់ ត្រូវបានចាត់ទុកដូច្នេះ។ នោះជាការពិត។ លោកយ៉ូហាននិយាយ "តើអ្នកមិនគិតថាយើងមានអ័ប្រាហាំជាឪពុកទេឬ។ ព្រះអង្គអាចធ្វើឲ្យដុំថ្មនេះក្លាយជាកូនរបស់អ័ប្រាំហាំក៏បានដែរ។"

206 ហើយទីសម្គាល់ពេលចុងក្រោយ នឹងមានសម្លេងចុងក្រោយ។ ហើយទីសម្គាល់ ចុងក្រោយនឹងកើតមានតាមអ្វីដែលបានទាយទុកតាមបទគម្ពីរ។ ហើយសម្លេងចុងក្រោយដែល មកតាមទីស្គាល់ចុងក្រោយ នឹងត្រូវបានសម្គាល់ក្នុងបទគម្ពីរ នឹងជាបទគម្ពីរដែលបានសន្យា។

207 ឥឡូវសូមយើងអាននៅក្នុងគម្ពីរលូកា១៧ ពីអ្វីដែលជាទីសម្គាល់ចុងក្រោយអាចមាន តើវានឹងដូចក្រុងសូដុំទេ ជាសេចក្តីសន្យា។ យើងមានលក្ខណៈជាក្រុងសូដុំ ជាធម្មជាតិ ហេតុអ្វីបានជាយើងមិនអាចជឿទីសម្គាល់ខាងវិញ្ញាណនៅទីនេះ? បើអ្នកអាចឃើញបទគម្ពីរ សូមមើលលូកា១៧ជាទីសម្គាល់ និងម៉ាឡាគី៤ជាទី សម្លេង។ទីសម្គាល់ដូចជាការបើកសម្តែងរបស់ព្រះជាម្ចាស់នៅក្នុងសាច់ឈាមដឹង ថាជាអាថ៌កំបាំងនៅក្នុងចិត្ត ហើយសម្លេងនៅក្នុងទីសម្គាល់ម៉ាឡាគី៤បានបំបែរ មនុស្សចេញពីក្រិតវិន័យត្រឡប់មកលើជំនឿចំពោះព្រះបិតា។ នោះជាទីសម្គាល់។

208 អ្នកដឹងទេ? ថាខ្ញុំបញ្ចប់ឥឡូវ។ ទីសម្គាល់តែងតែត្រូវបានគេទទួលយក ជាប្រាកដប៉ុន្តែសម្លេងអូ ទេ។ សម្លេងដែលមកតាមទីសម្គាល់ គេមិនចង់ធ្វើអ្វី ជាមួយនោះទេ។ បាទ។

209 ទីសម្គាល់ព្រះយេស៊ូ ជាព្រះមេស្ស៊ី ប្រោសអ្នកជំងឺ ពួកគេទទួល។ ប៉ុន្តែថ្ងៃមួយព្រះអង្គមានបន្ទូល "ខ្ញុំនិងព្រះបិតាគឺតែមួយ។"

210 អូ ខ្ញុំ សម្លេងនោះមិនត្រូវបានគេទទួលឡើយ។ ពួកគេនិយាយ "អ្នកតាំងខ្លួនឯងជាព្រះ ស្មើនឹងព្រះ។"

ព្រះអង្គមានបន្ទូល "ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់។"

211 "អូ ខ្ញុំអើយ តើព្រះជាម្ចាស់អាចមានព្រះបុត្រាជាយ៉ាងណា? ឃើញទេ វាឆ្ងាយពីព្រះណាស់ដែលថាព្រះជាម្ចាស់មានព្រះបុត្រា!"

212 ប៉ុន្តែ អ្នកឃើញ ពួកគេជឿលើទី—សម្គាល់ អ្នកឈឺអាចជា ហើយ អូ នោះជាការអស្ចារ្យ នោះជាភាពហ៊ឺហារប៉ុណ្ណោះ។ ប៉ុន្តែពេលវាមកចំពោះទីសម្គាល់ ពួកគេមិនចង់ជឿសម្លេងនោះទេ។ តើពួកគេធ្វើអ្វី? ពួកគេដេញព្រះអង្គចេញ។

213 តើអ្នកដឹងថាហេតុអ្វីទេ? ព្រះគម្ពីរប្រាប់យើង ក្នុងវិវរណៈជំពូកទី៣ នៅក្រុមជំនុំក្រុងឡេវឌីសេ នឹងមានរឿងដូចគ្នា។ ព្រះអង្គនឹងនៅក្រៅក្រុមជំនុំ។ នោះជាព្រះ បន្ទូលបើកសម្តែង។ ទ្រង់ជាព្រះបន្ទូលដែលបានបើកសម្តែងចេញមក។ ទ្រង់ជា ជាព្រះបន្ទូលដែលបានសម្តែងឲ្យឃើញ។

214 បើអ្នកជឿទីសម្គាល់ក្រុងសូដុំ ក្នុងគម្ពីរលូកា បើអ្នកអាចជឿ ដូច្នេះហេតុអ្វីអ្នកមិនអាចទទួលយកម៉ាឡាគីជំពូក៤? ឃើញ ហេតុអ្វីអ្នកមិនអាច អ្នក? វាអាចជាការចង្អុលបង្ហាញ។ មានតែរបៀបមួយដែលអាចធ្វើបានគឺ…ទីសម្គាល់ដែលអាចបង្ហាញមក ប៉ុន្តែអ្នកត្រូវទទួលសម្លេង។

215 ម៉ូសេត្រូវបានផ្តល់បេសកកម្មឲ្យចុះទៅ តាមរបៀបធម្មជាតិ និងទីសម្គាល់ខាងវិញ្ញាណ ហើយហៅមនុស្សត្រឡប់មកកាន់សេចក្តីសន្យារបស់ព្រះបិតា។

216 ម៉ាឡាគី៤គឺត្រឡប់ទៅរកប្រជាជន "ត្រឡប់ទៅរកជំនឿនៃព្រះបិតា។" អូ ត្រឡប់ អូ ងងឹត ហើយ បែកចេញ តាមផ្លូវរបស់អ្នកផ្ទាល់!

217 ក្នុងការបញ្ចប់ ខ្ញុំនឹងនិយាយរឿងនេះ នៅមតិចុងក្រោយ។ ព្យាការីនិយាយ "វានឹងមានពន្លឺនៅពេលយប់ព្រលប់។" មើលគាត់និយាយ "នឹងមានថ្ងៃដែលមិនអាចហៅថាជាពេលថ្ងៃឬពេលយប់។" ឥឡូវសូមស្តាប់។ ខ្ញុំបញ្ចប់។ "នឹងមានថ្ងៃដែល…" ចូរគិតឲ្យជ្រៅ ហើយសូមឲ្យព្រះអង្គបានដាក់នៅក្នុងចិត្តទាំងអស់ក្នុងសហគមន៍ យប់នេះ ក្នុងសាលប្រជុំ។ ព្យាការីនិយាយ "នឹងមានថ្ងៃដែលមិនអាចហៅថាជាពេលថ្ងៃឬពេលយប់ ជាប្រភេទគួរសង្វេក មានភ្លៀង មានអ័ព្ទ។ ប៉ុន្តែ" គាត់ និយាយ "នៅពេលយប់ព្រលប់ នឹងមានពន្លឺ។"

218 ឥឡូវសូមចងចាំ ព្រះអាទិត្យរះនៅទិសខាងកើតនិងលិចនៅទិសខាងលិច។ ភាពស៊ីវិល័យដើរតាមព្រះអាទិត្យ។ អ្នកដឹងហើយ។ហើយសូមសម្គាល់ព្រះអាទិត្យ

រះនៅទិសខាងកើត ហើយព្រះអាទិត្យដដែលលិចនៅទិសខាងលិច។ ឥឡូវ ភាពស៊ីវិល័យបានធ្វើដំណើរតាមព្រះអាទិត្យជាប្រាកដ រហូតដល់ទិសខាងកើតនិងទិសខាងលិចជួបគ្នា។ យើងនៅឆ្នេរទិសខាងលិច ខាងកើតនិងខាងលិច។

219 ហើយសូមចងចាំដំណឹងល្អ បានធ្វើដំណើរតាមរបៀបដូចគ្នា។ វារះនៅទិសខាង កើត ជាការយាងមករបស់ព្រះយេស៊ូគ្រិស្ដ បុ-ត្រា មិនមែន ព្រះ-អា-ទិត្យ បុ-ត្រា ជាព្រះបុត្រារបស់ព្រះជាម្ចាស់ រះនៅទិសខាងកើត សម្រាប់ពួកមនុស្សខាងកើត។

220 ហើយឥឡូវ មានថ្ងៃដែលមនុស្សបានចូលរួមក្នុងក្រុមជំនុំ បង្កើតនិកាយ ជាពន្លឺអាចមើលឃើញ"ល្អយើងនឹងមានក្រុមជំនុំ។យើងនឹងសង់*នេះ*។យើងនឹងសង់ សាលារៀន។ យើងនឹងសង់មន្ទីរពេទ្យ។ យើងបង្រៀន។ យើងមានសេចក្ដីអធិប្បាយ។" ពួកគេមានពន្លឺគ្រប់គ្រាន់ដើម្បីធ្វើ។

221 ប៉ុន្តែសូមចាំ ព្រះគម្ពីរនិយាយ ព្យាការីរបស់ព្រះអម្ចាស់ ក្នុងព្រះគម្ពីរ ដែលជា **ព្រះបន្ទូលព្រះជាម្ចាស់** "ព្រះអាទិត្យដដែលដែលបំភ្លឺនៅទិសខាងកើតនិងបំភ្លឺម្ដងទៀតនៅទិសខាងលិច នៅពេលយប់ព្រលប់។ នឹងមានពន្លឺនៅពេលយប់ព្រលប់។"

222 តើព្រះអង្គនឹងធ្វើអ្វី? នោះជាអ្វីជាក់ស្ដែងដែលព្រះអង្គមានបន្ទូលក្នុងគម្ពីរលូកា ជំពូក១៧។ "នៅពេលចុងក្រោយ ពេល បុត្រមនុស្សបានលេចចេញមកគឺនឹងដូច គ្នានឹងពេលព្រះអង្គនៅទិសខាងកើត ព្រះអាទិត្យដដែលដែលបំភ្លឺ អំណាចដដែល ព្រះវិញ្ញាណបរិសុទ្ធដដែលអ្វីដូចគ្នាដដែល។វានឹងមានពន្លឺនៅពេលយប់ព្រលប់។"

223 ព្រះអាទិត្យដដែលដែលធ្វើដំណើរគោចរ ព្រះបុត្រាដដែលដែលធ្វើដំណើរមកឆ្លងមកពីទិសខាងកើត ពីប៉ុល លោតមកដល់ប្រទេសអាឡឺម៉ង់ ទៅលើ ម៉ាទីនលូធើ លោតឡើងម្ដងទៀត ហើយទៅកាន់ម្នាក់ទៀតដែលទ្រង់បានរើស ហើយចេញពីនោះទៅកាន់ប្រទេសអង់គ្លេស មកដល់ចនវេស្លេ លោតឆ្លងសមុទ្រអាត្លង់ទិក មកដល់សហរដ្ឋអាមេរិក មកដល់ពេនទីកុស្ដ ហើយ ឥឡូវពេនទីកុស្ដបានថយចុះ ហើយ យើងនៅតាមឆ្នេរ។

224 គ្រប់គ្នានៃពួកគេ មាននិកាយ ដូចជាពួកគេធ្វើពីដំបូងដែរ បង្កើតអង្គការដែលព្រះជាម្ចាស់ដាក់បណ្ដាសសារ។ ពេនទីកុស្ដ និង អ្វីទាំងអស់នោះ។

225 ប៉ុន្តែព្រះអង្គមានបន្ទូល "នឹងមានពន្លឺនៅពេលព្រលប់។ នឹងមានទីសម្គាល់លេចឡើងនៅពេលយប់ព្រលប់។" កុំឲ្យខកខានឡើយ មិត្តអើយ។ កុំឲ្យខកខានឡើយ។ ឥឡូវព្រះបុត្រាដដែលដែលផ្តល់ពន្លឺដដែល។ ព្រះ-អា-ទិត្យដដែលផ្តល់ពន្លឺដដែល ។ ព្រះ-បុ-ត្រា ដដែល ផ្តល់ពន្លឺដដែលដូចគ្នា។

226 ឥឡូវ នេះមិនមែនជាការនិយាយរបស់ខ្ញុំឡើយ។ គ្រប់គ្នានៅទីនេះ ដឹងហើយថាព្រះគម្ពីរបាននិយាយសូមលើកដៃរបស់អ្នក។ ក្រុមជំនុំនិយាយ "អេម៉ែន"—Ed]។ នោះគឺត្រឹមត្រូវ។

227 ឥឡូវអ្នកអាច វាអាស្រ័យលើអ្នក។ ជឿថាព្រះបុត្រារបស់ព្រះជាម្ចាស់ព្រះយេស៊ូ គ្រិស្តមិនបានសុគតឡើយ។ ព្រះអង្គមានព្រះជន្មរស់។ ព្រះអង្គនៅបន្ទាបខ្លួន។ ព្រះអង្គតែងតែនៅជាវត្តមានជាបែបនោះ។ តាមផ្លូវចូលមក។ បន្ទាបខ្លួនរបស់អ្នក ចេញពីគំនិតផ្ទាល់ខ្លួន និងជឿដល់ព្រះអម្ចាស់យេស៊ូ។ ឃើញទីសម្គាល់ពួកគេ ជឿលើសម្លេង។ ចូរត្រឡប់មកវិញ អូ ពួកអ្នកខ្វាត់ខ្វាយ មកឯខ្លួនអ្នកវិញ!

សូមយើងឱនក្បាលចុះ។

228 "ហើយបើគេមិនជឿសម្លេងទីសម្គាល់ដំបូង ក្នុងដៃ ជាមួយម៉ូសេ ដូច្នេះចូរធ្វើទីសម្គាល់ទីពីរ។ ដូច្នេះបើគេមិនជឿទីសម្គាល់នេះ ដូច្នេះចូរយកទឹក(ទឹកតំណាងជីវិត) ដែលនៅក្នុងសមុទ្រ ចាក់ទៅលើដី វានឹងក្លាយជាឈាម។"

229 ព្រះបិតាគង់នៅស្ថានសួគ៌វាជាពេលយឺតបន្តិចហើយឥឡូវ ប៉ុន្តែព្រះអង្គសន្យាថាមានពន្លឺនៅពេលយប់ព្រលប់។ សូមឲ្យសម្លេងនៃដំណឹងល្អលិចជ្រៅទៅក្នុងចិត្តរបស់មនុស្ស ហើយឲ្យពួកគេសញ្ជឹងគិតពីវានិងសិក្សាវាតាមរយៈព្រះ បន្ទូល។

230 សូមប្រទានពរដល់សហគមន៍នេះ ព្រះអម្ចាស់។ សូមប្រទានពរដល់មនុស្សទាំងនេះ។ សូមទតពួកគេកំពុងអង្គុយនៅទីនេះ ស្រេកឃ្លាន ក្មេងក្រីក្រដែលគេទាត់ចោល និង គាបសង្កត់ ហើយ*ការនេះ* ដោយដឹងថាសាតាំងធ្វើបែបនេះដើម្បីបាំងភ្នែកគេពីអ្វីដែលពួកគេត្រូវទៅ។ សូមឲ្យពួកគេ នៅយប់នេះ រួមគ្នាតែមួយ ជឿដល់ព្រះយេស៊ូគ្រិស្ត ជឿសេចក្តីសន្យារបស់ព្រះអង្គ ដែលព្រះអង្គរស់ពីសុគត។

231 ព្រះអង្គមានបន្ទូល "នៅវេលាដែលពួកគេមិនគិត នោះព្រះបុត្រមនុស្សនឹងយាងមក។"

232 ជាការត្រឹមត្រូវពេលដែលក្រុមជំនុំទទួលបាន វាមានតម្លៃជាលុយ ការរកលុយបានរាប់លានដុល្លា ក្នុងការសាងសង់។ នឹងមានភាពប្រសើរឡើង ព្រះបិតា ទូលបង្គំជឿ សូមត្រឡប់មកឈរនៅខាងជ្រុង វាយ—សំភោ ដែលមានមួកក្នុងដៃពួកគេ ស្គរចាស់នៅជ្រុងដូចជាកងទ័ពរំដោះ ហើយការអង្គុយក្នុងផ្ទះមានបុណ្យសព ប្រសើរជាងការយកត្រាប់តាមលោកកិយ "ដែលមានទម្រង់ជាព្រះជាម្ចាស់ តែបដិសេធអំណាចព្រះវិញ។"

233 សូមទទួលយក ព្រះអម្ចាស់ យប់នេះ ម្តងទៀត ព្រះអម្ចាស់ ដូចជាសាំសុនបានស្រែក "សូមម្តងទៀត ព្រះអម្ចាស់ សូមម្តងទៀត។" សូមឲ្យបានដឹងថា ព្រះអង្គ ជាព្រះគ្រិស្ត ជាបុត្រាព្រះជាម្ចាស់ ដូចកាលពីថ្ងៃម្សិលមិញថ្ងៃនេះ និង រៀងរហូតទៅ។ ហើយសូមបើកសម្គាល់ព្រះអង្គក្នុងកណ្តាលចំណោមទូលបង្គំ ដែលពួកគេអាច ឃើញទីសម្គាល់ ដែលអាចឲ្យពួកគេជឿសម្លេងនោះ។ សូមទូលថ្វាយក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ អាម៉ែន។

234 យើងនឹងហៅខ្សែរអធិស្ឋាន សូមលឿនឡើង។ ខ្ញុំឃើញថា វាជាពេលរួចរាល់ហើយ ឥឡូវយើងកំពុងចេញមក។ ប៉ុន្តែសូម តម្រង់ជួរអធិស្ឋាន ជាខ្សែរអធិស្ឋានតូចមួយ រួចយើងនឹងចាប់ផ្តើមនៅថ្ងៃស្អែក។

235 គាត់បានចែកកាតអធិស្ឋាននៅថ្ងៃនេះ។ យើងចែកកាតរៀងរាល់ថ្ងៃនីមួយៗ ដូច្នេះម្នាក់ៗអាចមានឱកាសដែលពួកគេមក ជាពេលវេលាចម្លែក។ ដើម្បីមកតាម ជួរអធិស្ឋាន នោះមិនមានជាការប្រោសអ្នកឲ្យបានជាឡើយ។ នរណាក៏ដឹងដែរ ក្នុងរាល់ការជួបជុំមានការប្រោសឲ្យជានៅកន្លែងត្រង់នោះច្រើនជាងឡើងមកទីនេះ ឃើញ តែងតែដូច្នេះ។ ព្រះវិញ្ញាណបរិសុទ្ធមានវត្តមានគ្រប់កន្លែង។ ព្រះអង្គតែងព្យាយាមស្វែងរកអ្នកជឿ នោះជារឿងសំខាន់ ព្រះអង្គអាចចូលទៅ។

236 សូមចែកកាតអធិស្ឋានរបស់យើង ភី ដូចជាប៉ូល។ ចាប់ផ្តើម កន្លែងយើងនៅ...ល្អ ហៅពីលេខមួយ។ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់ ចូរឲ្យពួកគេឈរនៅទី*នេះ* បើអ្នកនឹងមាន។ កាតរបស់ពួកគេជា ភី ដូចជាប៉ូល ពីមួយដល់ដប់ ឈរនៅទី*នេះ* បើអ្នកអាចឈរបាន។ បើមិនអាចឈរ សូមឲ្យមាននរណាម្នាក់ជួយអ្នក។ ដប់ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី... ត្រូវហើយ ពីរនាក់ទៀត ប្រាំបី ប្រាំបួន ដប់ ត្រឹមត្រូវ។ ដប់ដល់ដប់ប្រាំ ដប់ដល់ដប់ប្រាំ ប្រាំនាក់ទៀត។ ដប់ប្រាំដល់ម្ភៃ ក្រោកឈរឡើងដូច្នេះខ្ញុំអាចមើលអ្នក

ឃើញថាអ្នកបានក្រោកពិតមែន ភី ដប់ប្រាំដល់ម្ភៃ។ ម្ភៃដល់ម្ភៃប្រាំ។ សូមមើល ឥឡូវ អ្នកនៅទីណាក៏ដោយ។ ឥឡូវសូមឲ្យអ្នកនៅសល់ក្នុងចំណោមអ្នកចូលរួម ធ្វើការគោរព តែ ពីរបីនាទី។ សូមឲ្យអ្នកមានកាតភី ពីមួយដល់ម្ភៃប្រាំ។ ត្រូវទេ? ម្ភៃប្រាំ មួយដល់ម្ភៃប្រាំ។

237 ឥឡូវសូមឲ្យអ្នកទាំងអស់គ្នាផ្តល់ការគោរព។ សូមផ្តល់ការគោរពដល់ព្រះជាម្ចាស់យ៉ាងច្រើន ដែលប្រទានសារមក។ អ្នកជំពាក់ព្រះជាម្ចាស់ សូមរង់ចាំ មួយនាទី និង ពិនិត្យមើល។

238 ឥឡូវ ខ្ញុំគិតថាពួកគេបានរៀបចំមនុស្សរួចហើយ។ អ្នកដែលមិន…បើគេមានកាតអធិស្ឋាន ពួកគេមិនមែនមកតម្រង់ជួរទាំងអស់គ្នានោះទេ ពួកគេរក គេនឹងប្រាប់ខ្ញុំ ខ្ញុំក្នុងពេលបីបួននាទីទៀត ហើយពួកគេនឹង…ហើយយើងនឹងឃើញថាប្រហែលមានអ្នកថ្លង់ ឬ ស្តាប់មិនឮ។

239 ខ្ញុំមិនដឹងថាពួកគេនៅឯណាទេ មិត្តអើយ កាតអធិស្ឋានរបស់គេ។ ក្មេងប្រុសមកនេះ (នរណាចែកឲ្យពួកគេ? អ្នកឬ ប៊ីលលី? ប៊ីលលី?)អ៊ីចឹង ពេលគាត់មកហើយបញ្ចូលកាតពួកគេមុនអ្នកទាំងអស់គ្នាទៅ រួចឲ្យកាតអធិស្ឋានដល់អ្នក មកទីនេះប្រាប់អ្នកទាំងអស់គ្នាឲ្យអង្គុយចុះ ឲ្យកាតអធិស្ឋានដល់អ្នក។ ឃើញ? ខ្ញុំមិនដឹងថាពួកគេនៅឯណាឡើយ។ខ្ញុំព្យាយាមយកក្មេងមកទីនេះឃើញ។ ហើយអ្នកផ្សេងទៀតខ្ញុំ—ខ្ញុំមិនស្គាល់។ ខ្ញុំ—ខ្ញុំមិនដឹងរបៀបដែលស្គាល់។ ខ្ញុំដឹងថាព្រះជាម្ចាស់នឹងតាំងវាតាមរបៀបដែលព្រះអង្គសព្វព្រះទ័យក្នុងការតាំងឡើងបែបនោះ។

240 ឥឡូវ អ្នកទាំងអស់គ្នា ដែលមិនមានកាតអធិស្ឋាន។ សូមលើកដៃ និយាយ "ខ្ញុំមិនមានកាតអធិស្ឋាន ប៉ុន្តែខ្ញុំឈឺ។" សូមលើកដៃឡើង ទោះនៅកន្លែងណាក្នុងអាគារក៏ដោយ។ ខ្ញុំមិនខ្វល់ថាអ្នកនៅកន្លែងណាទេ សូមលើកដៃរបស់អ្នក… ល្អ មិនមានមនុស្សច្រើនទេ នៅទីនេះឥឡូវ។ ល្អតាមរយៈដូច្នេះខ្ញុំនឹងមិនចាំបាច់ចំ ណាយ ពេលអធិស្ឋានយូសម្រាប់ខ្សែអធិស្ឋានឥឡូវនៅថ្ងៃស្អែក។ មានប្រហែលមនុស្សម្ភៃនាក់នៅទីនេះ ដោយគ្មានអ្វីនៅទីនេះ ក្រៅពីអ្នកជំងឺ។

241 ជាការល្អ។ ខ្ញុំរីករាយដោយឃើញអ្នកទទួលយ៉ាងនោះ។ អ្នកមានជំនឿច្រើនជាងខ្ញុំធ្លាប់គិតប្រហែលជាដូច្នេះ។ ឃើញ? ឃើញទេ? បើអ្នកទទួលយកការ

ប្រោស ឲ្យជារបស់អ្នក សូមបោះកាតអ្នកចោលទៅ សូមព្រះប្រទានពរ។ នោះជាជំនឿពិត។ គ្មាននរណាម្នាក់ដាក់ដៃលើអ្នកឡើយ អ្នកបានដាក់ដៃលើព្រះគ្រិស្ត។

242 ឥឡូវ អ្នកនៅទីនេះនៅយប់នេះ នឹងមិននៅតាមជួរអធិស្ឋានឡើយ អ្នកជឿរឿងនេះ។ ប្រៀបដូចជាស្ត្រីម្នាក់ដែលពាល់ជាយក្រណាត់ ហើយព្រះអង្គបែរមក និងជ្រាបថា នាងពាល់ព្រះអង្គ តើប៉ុន្មាននាក់ដែលចងចាំរឿងនេះ? ប្រាកដណាស់អ្នកដឹង។

243 ឥឡូវអ្នកជឿទេ ព្រះអង្គ ព្រះគម្ពីរនិយាយនៅក្នុងហេព្រើ៤ថា "ព្រះអង្គជាសង្ឃដ៏ខ្ពស់ នាពេលឥឡូវ ហើយអាចស្គាល់ជ្រាបពីសេចក្ដីកំហុសរបស់យើង"? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] ល្អ បើព្រះអង្គនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រហូតតទៅ តើព្រះអង្គនឹងមិនប្រព្រឹត្តិដដែលទេឬ? ["អាម៉ែន។"] តើព្រះអង្គមិនធ្វើវាទេឬ ពីមួយយប់ទៅមួយយប់ នៅទីនេះ? ["អាម៉ែន។"] តើប៉ុន្មាននាក់ដែលបាន នៅក្នុងការប្រជុំផ្សេងៗហើយបានឃើញព្រះអង្គធ្វើការ? សូមក្រោកឡើង។["អាម៉ែន ។"] ប្រាកដ។ ឃើញ? នៅជុំវិញពិភពលោក! ព្រះអង្គស្គាល់ព្រះអង្គស្គាល់ទាំងអស់ពីអ្នក។

244 ឥឡូវមើលអ្វីដែលខ្ញុំព្យាយាមធ្វើ។ តើប៉ុន្មាននាក់យល់ពីអ្វីដែលខ្ញុំចង់ធ្វើ? ឃើញ? ខ្ញុំចង់ឲ្យអ្នក មិនចាំបាច់មាននរណាម្នាក់ដាក់ដៃលើអ្នក ខ្ញុំចង់ឲ្យអ្នកដូចជាព្រះបន្ទូលដ៏ពិតរបស់ព្រះជាម្ចាស់និយាយ "ព្រះយេស៊ូគ្រិស្ត ទូលបង្គំជឿព្រះអង្គ។ ឥឡូវទូលបង្គំទទួលព្រះអង្គ ជាអ្នកប្រោសទូលបង្គំឲ្យជា។ ឥឡូវទូលបង្គំទទួលព្រះអង្គជាព្រះសង្គ្រោះ។ ទូលបង្គំជឿអស់ពីចិត្ត សូមឲ្យបានសម្រេច។" ដូច្នេះសូមកាន់ជាប់សេចក្ដីសន្យានោះ ចងចាំពីការសារភាពរបស់អ្នកហើយដើរទៅមុខជាមួយវា។ រង់ចាំមើលអ្វីដែលកើតឡើង។ ឃើញទេ? រង់ចាំមើលអ្វីដែលកើតឡើង។ ឃើញ? នោះជាអ្វីដែលខ្ញុំចង់ឲ្យអ្នកធ្វើ ជាផ្លូវពិតដែលយើងត្រូវតែជឿ។

245 តើអ្នកនឹងនិយាយយ៉ាងណា? [មានអ្នកនិយាយ "បួន និង ដប់ប្រាំបួន"—Ed។] លេខបួន កាតអធិស្ឋាន លេខបួននិងលេខដប់ប្រាំបួនបានបាត់។ កាតអធិស្ឋានលេខបួន។ មើលនរណាម្នាក់ សូមមើលលេខកាតរបស់អ្នកនៅក្បែរអ្នក។ កាត អធិស្ឋានលេខបួន និង លេខដប់ប្រាំបួន។ សូមចាំមួយភ្លែត សូមចាំ។ ឃើញ បើខ្ញុំមិនហៅគាត់ ខ្ញុំនឹងត្រូវហៅម្ដងទៀត ឃើញទេ។ និយាយអ្វី?

និយាយអ្វី? ["បួន។"] អ្នកមានលេខបួន? ចុះលេខដប់ប្រ...មិនទាន់មានលេខដប់ប្រាំបួនទេ។ និយាយ អ្វី? ["ថែមលេខបួន។"] កាតអធិស្ឋានលេខបួនមិនទាន់ឃើញនៅឡើយ ឬដប់ប្រាំបួន។ តើមានអ្នកមានកាតនោះទេ បើមានសូមចូលមកតាមជួរ។ ឬ មើល ឃើញ វាប្រហែល...មាន...តើក្មេងតូចនោះមានកាត? សូមពិនិត្យ តើមិន...មិនមែនលេខនោះទេ។ តើស្ត្រីម្នាក់*នេះ*មានកាតឬទេ ម្នាក់អង្គុយលើកៅអីរុញ? ពិនិត្យលេខរបស់គាត់។ តើវា—ជាលេខរបស់គាត់? ស្ត្រីម្នាក់អង្គុយលើជើងម៉ា ហាស់? គេរកឃើញហើយ។ ពួកគេ ឥឡូវគ្រប់គ្នាហើយ។ អូខេ។ ត្រូវហើយ។ ឥឡូវ—ឥឡូវ អ្នកដែលមានកាតអធិស្ឋាន សូមកាន់។ យើងនឹងដឹកនាំដោយព្រះគុណព្រះជាម្ចាស់។

246 ឥឡូវ មិត្តទាំងឡាយ នេះជាយប់ចុងក្រោយរបស់យើង ស្អែកគឺរសៀលថ្ងៃអាទិត្យ សូមស្ងប់ស្ងាត់ផ្ទាល់ខ្លួន។ ឥឡូវសូមយកគំនិតមិនជឿដែលអ្នកមាន និង រាល់—រាល់គំនិតមិនសមហេតុផល ហើយចុះទៅលើកម្រាល ហើយដាក់ជើងលើនោះ ដូចមុន។ និយាយ "ព្រះអម្ចាស់យេស៊ូ ទូលបង្គំជឿព្រះអង្គ។" តើប៉ុន្មាននាក់ដែលធ្វើដូច្នេះ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed។] សូមអរគុណ។ សូមព្រះប្រទានពរ។

247 ឥឡូវសូមកុំឲ្យនរណាម្នាក់ចេញឡើយ។ សូមអង្គុយនៅស្ងៀម និង ជឿ។ មើលនេះជារបៀប និងសូមមើល។

248 អត្តសញ្ញាណរបស់ព្រះជាម្ចាស់តែងតែស្គាល់ អាចមើលឃើញមុនអ្វីដែលកំពុងកើតឡើង និងប្រាប់ពីអ្វីដែលបានកើតឡើងហើយ និងអ្វីដែលនឹងកើតមាន។ យើងដឹង។ នោះហើយជាអ្វីដែលព្យាការីត្រូវបានគេស្គាល់។ នោះជាអ្វីដែលព្រះយេស៊ូត្រូវបានស្គាល់ថាជាព្រះមេស្ស៊ី។ ហើយព្រះអង្គនៅតែជាព្រះមេស្ស៊ីដដែលនៅបច្ចុប្បន្នដូចព្រះអង្គកាលពីមុនដែរ គ្រាន់តែព្រះអង្គមិនមានរាងកាយនៅលើផែនដីប៉ុណ្ណោះ។ ព្រះអង្គបញ្ជូនព្រះវិញ្ញាណរបស់ព្រះអង្គដើម្បីប្រើរាងកាយរបស់អ្នក រាងកាយរបស់ខ្ញុំ។ ឥឡូវអ្នកប្រហែលជាមិនអាចធ្វើការនេះបាន។ យើងដឹង ក្នុងបទគម្ពីរនឹងមានម្នាក់ក្នុងជំនាន់មួយ។ ប៉ុន្តែ ឃើញ ប៉ុន្តែអ្នកអាចជឿបាន ហើយអ្នកអាចមានអ្វីផ្សេងដែលអ្នកអាចធ្វើបានគ្រប់គ្នា។

249 អ្វីទៅបើម្រាមដៃខ្ញុំសម្រេច ព្រោះនោះមិនមែនជាភ្នែករបស់ខ្ញុំផង នោះមិនមែនជាម្រាមរបស់ខ្ញុំទៀតទេ? ចុះបើដៃនេះនិយាយ "ខ្ញុំនឹងមិនលើកឡើងទៀតទេ

ព្រោះខ្ញុំមិនមែនជាភ្នែក ក៏មិនមែនជាត្រចៀកដែរ តើពេលនោះខ្ញុំមិនមែនជាដៃឬ″? ហេតុអ្វី បានជាវាធ្វើឲ្យរាងកាយខ្ញុំទៅជាខ្វិន។

អ្នកជាអ្វីដែលព្រះជាម្ចាស់ដាក់អ្នកឲ្យជាបែបនោះ។

250 តើប៉ុន្មានដងដែលបានខ្ញុំសរសើរ អូរ៉ូលរ៉ូបឺត ប៊ីលលីហ្គ្រាហាំ ថមមីអូសស្បន!

251 មនុស្សទាំងនោះខ្លះដើរហើយនិយាយ ‟សិរីរុងរឿងជារបស់ព្រះជាម្ចាស់! ជឿចុះ!″ ជំនឿគ្មានតម្លៃ។ ដើរចេញ ដើរចេញពីទីនោះដោយស្រស់ស្រាយតាមតែអាចធ្វើទៅបាន។

252 ប៊ីលលី ហ្គ្រាហាំឈរទ្បើងជាមួយនឹងសារ ហើយនិយាយទៅកាន់មនុស្សពីរបីនាទីនិយាយ ‟ធ្វើការសម្រេចចិត្តរបស់អ្នកចុះចូលមកអាសនា។″ឈរនៅ ទីនោះ កុំឲ្យធ្វើប្តូរទិសដៅទ្បើយ។

គាត់និយាយ ‟ហេតុអ្វីបានជាអ្នកធ្វើបែបនោះ ប៊ីលលី?″

253 និយាយ ‟សាររបស់ខ្ញុំចេញទៅ។ វាមកពីព្រះជាម្ចាស់″ នោះគឺត្រឹមត្រូវ។

254 គាត់ជាក្រុមជំនុំ ក្រុងសូដុំដូចអ្វីដែលធ្លាប់មក។ ឈ្មោះរបស់គាត់បញ្ចប់ដោយ ហាំ មកពីប្រាហាំ អក្សរប្រាំមួយ អាប្រាហាំគឺមានប្រាំពីរអក្សរ។ ឃើញទេសាររបស់ក្រុមជំនុំនោះ ចូលទៅក្នុងបាប៊ីទ្បូន? ជាប្រាកដ។ មិនមាននរណាម្នាក់ក្នុងប្រទេសកាន់ខ្ជាប់សារប្រែចិត្តនោះទ្បើយ ដូចជាប៊ីលីហ្គ្រាហាំ។ គាត់ឈរនៅទីនោះ។ ដើរចេញពីទីនោះ ហើយទៅបរិភោគសាច់ឆ្អឹង-ធី ហើយទៅដេក ផឹកអាហារទឹកដោះគោ។ នោះគឺត្រូវហើយ។

255 ហើយពេលអ្នកត្រូវឈរ និងតយុទ្ធនឹងអារក្ខ! ពេលមួយតាមឆ្នេរនៅទ្បុងប៊ិច បងប្រុសជេក និង ខ្ញុំ…ឪពុករបស់អ្នកឈរនៅទីនេះ។

256 ហើយមានលោក ហ្វុលទ្បឺឈរ លោកឆាទ្បេសហ្វុលទ្បឺ ជាបងប្អូនប្រុសល្អ ម្នាក់ ឈរអធិប្បាយ។ មានមនុស្សប្រមាណពីរឬបីពាន់នាក់ក្នុងល្ងាចនោះ។ យើងអង្គុយនិងស្តាប់ការប្រជុំរបស់គាត់។ ខ្ញុំមានសាលប្រជុំជួល នៅក្បែរគាត់។ បន្ទាប់ពីគាត់ឈរនៅទីនោះនិងថ្លែងការយ៉ាងល្អ។ ហើយនិយាយ ‟តើមាននរណា ម្នាក់ចង់ទទួលព្រះគ្រិស្ត?″ មានមនុស្សពីរបីនាក់ទ្បើងមក ដើម្បីថ្វាយកូនរបស់គេ។ មានស្រ្តីម្នាក់និយាយថាគាត់ចង់ទទួល។ ទ្បើងមកហើយក៏ធ្វើសេចក្តីអធិស្ឋានតូចមួយជាមួយចាស់ទុំម្នាក់រួចត្រទ្បប់ទៅវិញអង្គុយចុះ។ ចាប់ដៃ

បែរជុំវិញរួចដើរចេញ ទៅ។ នោះជាចំណេះរបស់គាត់ជាក្រុមមនុស្សស្លៀកពាក់ស្អាតបាត ចូរដើរចេញពីទីនោះ។

257 មានអ្នកដើរចូលមកខ្ញុំ មានអាវធំចង្អៀត កៅអីកង់ ងងឹត ហើយខ្ចិន ឈប់របួសពិកា។ ពេលដែលជំនឿរបស់អ្នកប្រឈមមុខនឹងអ្វីបែបនោះ!

258 ឥឡូវ នៅទីនេះ តើខ្ញុំប្រកាសពីព្រះគ្រិស្តជាអ្វី? ហើយឥឡូវអ្នកមិនជឿអង្គុយជុំវិញ ចាំចាប់កំហុសណាមួយ ឃើញ ព្យាយាមរកកំហុសណាមួយ។

259 ចងចាំទេ នៅទីនេះមិនយូប៉ុន្មានទេក្នុងតូរិនតូ យើងបានឈរនៅទីនោះកំពុងអធិប្បាយ អធិស្ឋានសម្រាប់អ្នកជំងឺ។ ខ្ញុំមានអារម្មណ៍ចម្លែក វាកំពុងតែនៅខាងឆ្វេងខ្ញុំ។ ខ្ញុំមើលវាជានិច្ច។ មានបុរសម្នាក់កំពុងអង្គុយនៅទីនោះ មានពួកមនុស្សជួលគាត់មកសណ្ដំខ្ញុំ។ គាត់អាចទៅជុំរុំទ័ពនិងអាចសណ្ដំពួកទ័ពក្នុងដៃខ្លួនហើយព្រុសដូចជាឆ្កែនិងអ្វីៗទៀតភាពសណ្ដំ។ ខ្ញុំមានអារម្មណ៍ថាដូចជាវិញ្ញាណអារក្ខ។ ខ្ញុំមិនដឹងថាវាមកពីណាឡើយ។ ខ្ញុំនៅមើលវាជានិច្ច។ ខ្ញុំឃើញស្រមោលខ្មៅ។ ខ្ញុំរង់ចាំបីបួននាទី។ ខ្ញុំនិយាយ "អ្នកជាកូនអារក្ខ ហេតុអ្វីបានជាអារក្ខធ្វើឲ្យគំនិត ទៅជាខ្វាក់ចំពោះអ្វីបែបនោះ? ដោយព្រោះអ្នកមកចង់យកឈ្នះព្រះជាម្ចាស់ ចង់ល្បងព្រះវិញ្ញាណព្រះជាម្ចាស់ គេនឹងដេញអ្នកចេញពីទីនេះ។" គាត់បានក្លាយជាអ្នកស្លាប់រាងកាយក្នុងកៅអីរបស់គាត់ហើយនៅតែស្លាប់ដងខ្លួនដដែល។ ឃើញទេ?

260 យើងមិនលេងសើចជាមួយក្រុមជំនុំទេ។ តើប៉ុន្មានអ្នកដែលបាន នៅក្នុងការប្រជុំ ហើយឃើញអ្វីស្រដៀងនេះកើតឡើង អ្នកដឹង ហើយថាអ្វីកើតឡើង? ប្រាកដ ណាស់។ ហ្នឹងហើយ។ សូមចាំចូរ—ចូរគោរពជានិច្ច។

ឥឡូវ នៅទីនេះ ឧបមាថាខ្ញុំត្រូវ ជាមនុស្សដំបូង។ ត្រូវទេ?

261 ឥឡូវ មើល ខ្ញុំបានអធិប្បាយ បានប្រាប់អ្នកពីអ្វីដែលអាចត្រូវកើតមានក្នុងថ្ងៃនេះ។ នោះជាទីសម្គាល់ បើវាកើតឡើង។ នោះជាទីសម្គាល់ហើយ រួចជឿសម្លេងដែលមកតាមទីសម្គាល់។ ឃើញទេ?

262 ឥឡូវមានស្ត្រីម្នាក់។ ជាការពិត អ្នកមកថ្មីចូលមកចំពោះអ្នក នៅក្នុងគម្ពីរយ៉ូហាន៤ កន្លែងដែលព្រះអម្ចាស់យេស៊ូជួបស្ត្រីម្នាក់នៅអណ្ដូង។ ពួកគេគេមិនដែលជួបគ្នាពីមុនឡើយ ក្នុងជីវិត ព្រះអង្គបានប្រាប់ស្ត្រីនោះពីបញ្ហានៃជីវិត

របស់នាង។ ហើយស្ត្រីនោះក៏កត់សម្គាល់ថាជាព្រះមេស្ស៊ី។ តើអ្នកដឹងរឿងនោះទេ? នៅទីនេះម្តងទៀតហើយមានបុរសម្នាក់ជួបស្ត្រីម្នាក់។ ឥឡូវនាងមិនមែនជាស្ត្រីទេ ហើយខ្ញុំមិនមែនជាបុរសនោះឡើយ ប៉ុន្តែនៅតែជាព្រះដដែល។ ឃើញទេ? ឥឡូវ ព្រះយេស៊ូមានបន្ទូល "កិច្ចការដែលខ្ញុំធ្វើអ្នកនឹងធ្វើដែរ" សាវ័កយ៉ូហាន១៤:១២។

263 ឥឡូវស្ត្រីមិនស្គាល់អ្នក មិនដឹងថាអ្នកឈរត្រង់នោះធ្វើអ្វីឡើយ។ វាប្រហែលជាបញ្ហាក្នុងស្រុក។ ប្រហែលជាសម្រាប់នរណាម្នាក់។ ប្រហែលជាអ្នកឈឺ។ ប្រហែលវាជា...ប្រហែលអ្នកឈរនៅត្រង់នោះកំពុងធ្វើអ្វីមួយ។ បើដូច្នេះមែនតោះទៅរកមើលអ្វីដែលកើតឡើង។ ឃើញទេ? ប្រហែលអ្នកត្រាប់តាមអ្វីមួយ។ អ្វីក៏ដោយ ខ្ញុំមិន...អ្នកជាអ្នកជឿពិតប្រាកដ។ ខ្ញុំមិនដឹងទេ ប៉ុន្តែព្រះជាម្ចាស់ជ្រាប។ ប៉ុន្តែអ្នកនឹងដឹងថាព្រះអង្គប្រាប់អ្នកពិតឬក៏អត់ មិនចឹងឬ? បើវាជាការពិតអ្នកនឹងដឹង។

264 ឥឡូវ ឃើញទេ នោះជាអ្វីដែលជំនឿអ្នកត្រូវតែមាន។ តើអ្នកមកទីនេះចង់បានអ្វី? ឥឡូវបើមានអ្នកគិតថាវាខុស អ្នកមកនេះហើយយកអ្នកជំងឺចុះ មកនេះហើយយកពួកគេទាំងអស់ទៅ។ បើសិនជាអ្នកមិនធ្វើដូច្នេះទេ ដូច្នេះកុំកាត់ទោសខ្ញុំ។ ឃើញទេ?

265 ឥឡូវសូមមើលទីនេះប្អូនស្រីមើលមួយភ្លែត។ ឥឡូវខ្ញុំមិនមានគំនិតអ្វីទេ គ្មានគំនិតអ្វីពីអ្នកឡើយ។ អ្នកគ្រាន់តែជាស្ត្រីម្នាក់ឈរនោះទីនោះ។

266 ឥឡូវ ព្រះអម្ចាស់យេស៊ូគ្រិស្ត ជាព្រះបុត្រាព្រះជាម្ចាស់ ដែលបានបើកសម្តែងមកតាមព្រះគម្ពីរ សន្យាថាព្រះអង្គនឹងត្រឡប់មកវិញនៅថ្ងៃចុងក្រោយ ហើយបង្ហាញព្រះអង្គទ្រង់ក្នុងភាពពេញលេញនៃ ព្រះវិញ្ញាណព្រះអង្គ។

267 ប្រៀបដូចជាក្រុមជំនុំដែលចូលមក វាដូចជាមកពីមនុស្ស ចេញមកតាមជើងដល់ភ្លៅឡើងទៅដល់ក្បាលហើយក្បាលគឺជាក្បាលនៃរាងកាយ។ ហើយរាងកាយចេញមកតាំងពីក្រុមជំនុំដំបូងចេញមកក្នុងនេះក្នុងការផ្លាស់ប្តូរបានមកដល់ឥឡូវ។ វាបានមកតាមរយៈការប្រោសឲ្យវិសុទ្ធការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ។ ឥឡូវជាក្បាល(ព្រះគ្រិស្ត)ចូលមករាងកាយ ជារាងកាយព្រះគ្រិស្ត។ ព្រះអង្គជាអង្គដែលស្គាល់។ ដៃរបស់ខ្ញុំមិនដឹងពីរបៀបធ្វើឡើយ គឺដឹងដោយក្បាលរបស់ខ្ញុំ។ ប៉ុន្តែព្រះអង្គជាអង្គដែលជ្រាបដឹង នេះហើយជាហេតុផលដែលព្រះអង្គជាព្រះបន្ទូល។

268 ខ្ញុំមិនមែនជាព្រះបន្ទូលឡើយ ខ្ញុំជាមនុស្ស។ ប៉ុន្តែ អ្នកឃើញ ព្រះអង្គប្រើរាងកាយនេះ។ ព្រោះ ព្រះអង្គសុគតដើម្បីប្រោសរាងកាយនេះជាវិសុទ្ធ ដែលព្រះអង្គអាចប្រើបាន ហើយនឹងអាចផ្ដល់អំណោយទាន។ ប្រៀបដូចជាកាយទាញហ្គែរ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើ។

269 ដូច្នេះបើសិនជាព្រះអង្គពណ៌នា ឬ ប្រាប់អ្នកពីអ្វីដែលអ្នកធ្វើ អ្វីដែលអ្នកមកទីនេះ ឬ អ្វីពីអ្នក អ្នកជឿចុះ។ ហើយអ្នកចូលរួមនឹងជឿដូចគ្នា? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed។] សូមព្រះអម្ចាស់ទទួលយក។

270 ឥឡូវខ្ញុំយកគ្រប់ទាំងវិញ្ញាណ ក្នុងនេះ នៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ ឥឡូវសូមអង្គុយស្ងៀម។ កុំដូរកន្លែង។

271 មើល ទីនេះ មួយភ្លែត "មើលមកខ្ញុំ" ដូចជា ពេត្រុស យ៉ូហាន និយាយ ឆ្លងកាត់ច្រកទ្វារ។ ឬម្យ៉ាងទៀត សូមយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំបាននិយាយ។ ឃើញទេ?

ព្រះយេស៊ូសួរស្ត្រីនោះបីបួនសំណួរ "ឲ្យទឹកខ្ញុំផឹកផង។"

272 ឃើញខ្ញុំបានអធិប្បាយដូចគ្នា។ ព្រះបិតាបញ្ជូនខ្ញុំមកទីនេះទៅ—បាតុនរ៉ូហ្គ។ ខ្ញុំនៅទីនេះ។

273 ព្រះបិតាមានបន្ទូលថាព្រះអង្គត្រូវទៅសាម៉ារី។ ព្រះអង្គប្រថាប់នៅទីនោះ។ មានស្ត្រីម្នាក់ដែលជាមនុស្សដំបូងមកជួបព្រះអង្គ។ ព្រះអង្គបានធ្វើទីសម្គាល់មួយទៅកាន់ស្ត្រី ហើយក្រុងទាំងមូលក៏ប្រែចិត្ត។ មានអ្វីដែលខុសប្លែកគ្នា...

274 អ្នកគិតមើលបើព្រះអង្គធ្វើការដូចគ្នានៅយប់នេះអ្នកគិតថាបាត់តុនរ៉ូហ្គនឹងប្រែចិត្តទេ? ខ្ញុំសង្ស័យរឿងនោះ តើអ្នកយល់ដូច្នេះទេ? ខ្ញុំពិតជាធ្វើ។ ប៉ុន្តែយើងនៅថ្ងៃចុងក្រោយ ពេលដែលអារក្សវាកាន់តែអាក្រក់ជាងមុនដែលយើងធ្លាប់ស្គាល់។

275 ឥឡូវ ស្ថានភាពរបស់អ្នក។ អ្នកមកទីនេះដើម្បីទទួលការអធិស្ឋាន។ ជាការត្រឹមត្រូវណាស់។ អ្នកមានការឈឺចាប់ក្នុងបំពង់ក។ បើពិតមែនសូមលើកដៃ។ មិនតែប៉ុណ្ណោះទេ មានមនុស្សម្នាក់ដែលអ្នកអធិស្ឋានឲ្យ។ ជាក្មេងមួយ ហើយក្មេងនោះមានបញ្ហាបំពង់ក។ ហើយស្ថានភាពនោះជាស្ថានភាពរបស់ក្មេង វាកើតឡើងក្នុងបំពង់ក។ តើអ្នកជឿថា ព្រះជាម្ចាស់នឹងប្រោសគាត់ឲ្យជា? មានកូនកន្សែងក្នុងដៃរបស់អ្នក ដែលអ្នកលើកថ្វាយព្រះជាម្ចាស់ ជាទីបន្ទាល់។ កុំសង្ស័យឥឡូវនេះ។

ចេញទៅហើយដាក់កូនកន្សែងលើក្មេងចុះ។ កុំសង្ស័យ អស់ពីចិត្ត។ ព្រះអង្គនឹងប្រោសអ្នកទាំងពីរឲ្យជានិងធ្វើឲ្យអ្នកប្រសើរឡើង។ [សម្លេងរបស់ ប្អូនស្រីនិយាយ "សរសើរព្រះអង្គ! ហាលេលូយ៉ា!"—Ed។] អ្នកអាចធ្វើយ៉ាងនោះបានទេ? ["ព្រះយេស៊ូ! អរគុណព្រះអង្គ ព្រះយេស៊ូ!"] ដូច្នេះ អ្នកទៅចុះ ហើយព្រះអម្ចាស់នឹងនៅជាមួយអ្នក។ ["ថ្វាយសិរីល្អដល់ព្រះជាម្ចាស់! ហាលេលូយ៉ា!"]

តើអ្នកសុខសប្បាយទេ? យើងជាអ្នកថ្មីចំពោះគ្នាដែរ។

276 តើអ្នកជឿទេ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed។] នោះជាទីសម្គាល់។ ឥឡូវសម្លេង គឺ "ចូរត្រឡប់ទៅរកព្រះបន្ទូល!"

277 មិនស្គាល់អ្នកទេ តែព្រះអង្គស្គាល់។ បើសិនជាព្រះអង្គនឹងប្រាប់ខ្ញុំពីអ្វីនៅក្នុងអ្នក ដូច្នេះអ្នកជឿថានោះជាព្រះបន្ទូលដែលខ្ញុំបាននិយាយ នឹងកាត់សេចក្តីពាក្យនោះ? នោះគឺ—នោះគឺជាការកាត់សេចក្តីចំពោះវា។ ឃើញទេ? ខ្ញុំនិយាយថាព្រះអង្គនឹងធ្វើ នោះជាការថ្លែងទំនាយ។ ឥឡូវបើការថ្លែងទំនាយបានមកដល់ ដូច្នេះព្រះអង្គមានបន្ទូល "សូមស្តាប់ចុះ។"

278 អ្នកមានបញ្ហាប្រពន្ធ័ប្រសាទធ្ងន់ធ្ងរដែលអ្នករងទុក្ខ រន្ធត់។ ហើយនកមានដុះសាច់ ការដុះសាច់នោះគឺនៅលើជើងរបស់អ្នក។ នោះគឺត្រូវហើយ មិនចឹងឬ? [បងប្អូនស្រីនិយាយ "ចាស។"—Ed។] ឥឡូវអ្នកជឿទេ? ["ចាស លោក។"] ដូច្នេះ តាមផ្លូវរបស់អ្នកហើយជឿចុះ។ ហើយ ដោយព្រោះអ្នកជឿ ដូច្នេះនឹងសម្រេចកើតមានដល់អ្នក។

279 តើអ្នកសុខសប្បាយទេ? ខ្ញុំមិនស្គាល់អ្នកទេ ប៉ុន្តែព្រះជាម្ចាស់ស្គាល់អ្នក។ តើអ្នកជឿថាព្រះជាម្ចាស់អាចប្រាប់ខ្ញុំពីបញ្ហារបស់អ្នកបានទេ? មើលមកខ្ញុំ។ អ្នកមានបញ្ហា។ ប៉ុន្តែអ្នកឈរនៅទីនេះដើម្បីនរណាម្នាក់ទៀត ហើយអ្នកនោះជាអ្នកដែលធំឡើងជាមួយអ្នក។ ជាប្អូនស្រី។ ត្រូវហើយ។ ឥឡូវអ្នកជឿថាព្រះជាម្ចាស់អាចប្រាប់ខ្ញុំពីអ្វីដែលខុសជាមួយបងប្អូនស្រីរបស់អ្នក? អ្នកទទួលទេ? គាត់មានបញ្ហាបេះ ដូង។ ត្រូវទេ។ តើអ្នកជឿថាគាត់នឹងជាទេឥឡូវ? ដូច្នេះ ដោយព្រោះជំនឿអ្នកសូមឲ្យសម្រេចបានចំពោះអ្នក។

280 ចូលមកស្ត្រី។ តើអ្នកសុខសប្បាយទេ? បើសិនជាព្រះអាចប្រាប់ខ្ញុំពីបញ្ហារបស់អ្នក ឬ អ្វីអ្នកធ្លាប់ធ្វើ ឬអ្វីផ្សេងទៀត តើនឹងធ្វើឲ្យអ្នកជឿទេ? អ្នកដឹងថាខ្ញុំ...

ខ្ញុំ—ខ្ញុំ—ខ្ញុំមិនស្គាល់អ្នក។ នោះជាអ្វីដែលជាលក្ខណៈសម្គាល់ក្នុងខ្ញុំ តាមរយៈព្រះបន្ទូលដែលព្រះអង្គបានសន្យា។ [បងប្អូនស្រីនិយាយ "ខ្ញុំជឿវា។"—Ed។] អ្នកជឿ ទេ?["ចាស។ អាម៉ែន។"]

281 អ្នកជាម្នាក់ផ្សេងទៀត តាមពិតអ្នកគួរមានបញ្ហាផ្ទាល់ខ្លួនតាមអាយុរបស់អ្នក ប៉ុន្តែគំនិតធំរបស់អ្នកគឺសម្រាប់អ្នកផ្សេងទៀត។ ចិត្តអ្នកចំពោះព្រះជាម្ចាស់ អ្នកស្វែងរកព្រះជាម្ចាស់មិនមែនសម្រាប់ខ្លួនឡើយ ប៉ុន្តែសម្រាប់អ្នកផ្សេងទៀតនោះជាបុរសម្នាក់។ ជាប្ដីរបស់អ្នក។ ហើយគាត់មានបញ្ហាបេះដូង។ តើអ្នកជឿថាព្រះអង្គនឹង...ព្រះជាម្ចាស់នឹងប្រោសគាត់ឲ្យជា? ទៅជឿចុះ។ ហើយដោយព្រោះអ្នកជឿនឹងសម្រេចកើតឡើងចំពោះអ្នក។

282 ឥឡូវ សូមមើល ការអធិប្បាយទាំងអស់ សម្រាប់ពេលវេលាទាំងអស់ដែលខ្ញុំអធិប្បាយ។ វា នោះជាអ្វីពីមុននោះ ពីរទៅបីម៉ោងដែលមនុស្សបានឆ្លងកាត់ ឥឡូវខ្ញុំពិបាកឈរនៅទីនេះ។ ឃើញ? ឃើញទេ? មើលទៅហ្វូងមនុស្សទាំងអស់មើលទៅដូចមីលគីចឹង នៅជុំវិញនេះ។ ឃើញ? ព្រះយេស៊ូមានបន្ទូល "កម្លាំងចេញពីខ្ញុំទៅ។" ហើយបើស្ត្រីម្នាក់ពាល់ក្រណាត់អាវរបស់ព្រះអង្គ អាចមានកម្លាំងចេញ ពីព្រះអង្គ ហើយព្រះអង្គជាបុត្រារបស់ព្រះជាម្ចាស់ ចុះខ្ញុំវិញជាមនុស្សបាបដែលបានសង្គ្រោះដោយព្រះគុណព្រះអង្គ?

283 ព្រះអង្គមានបន្ទូលថា "អ្វីដែលខ្ញុំធ្វើអ្នកនឹងធ្វើដែរ។ អ្នកនឹងធ្វើ*ច្រើនជាង*នេះទៅទៀត។" ខ្ញុំដឹងថាគម្ពីរយើងចេមនិយាយ "អស្ចារ្យជាង។" ប៉ុន្តែបើអ្នកយកការបកប្រែដើមមកមើល និយាយថា "អ្នកនឹងធ្វើ*ច្រើន*ជាងនេះ។" គ្មាននរណាម្នាក់អាចធ្វើអស្ចារ្យជាងនោះឡើយ។ ព្រះអង្គប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ហើយ បញ្ឈប់ធម្មជាតិ និងធ្វើអ្វីៗទាំងអស់។ ប៉ុន្តែព្រះអង្គមានបន្ទូល "អ្នកនឹងធ្វើ*ច្រើន*ជាងនេះ ព្រោះខ្ញុំទៅឯព្រះវរបិតា។"

284 "លោកកិយនេះមិនឃើញខ្ញុំទៀតឡើយ ប៉ុន្តែអ្នករាល់គ្នាឃើញខ្ញុំវិញ ព្រោះខ្ញុំ..." មើល "ខ្ញុំ" ខ្ញុំ—ខ្ញុំ ជាសព្វនាមផ្ទាល់។ "ខ្ញុំនៅជាមួយអ្នក ហើយនៅក្នុងអ្នក" ដូច្នេះ មិនមែនជាមនុស្សឡើយ។ ជាព្រះគ្រិស្ត។

285 ខ្ញុំនិយាយដូច្នេះ ដូចជាអង្រួនខ្លួនឯងបន្តិច ដូចជាត្រឡប់ទៅវិញ។ អ្នកនឹងចេញទៅចំណុចនោះបន្ទាប់ពីមួយខណៈពេល...មិនមែនជាកំឡុងពេលអ្នកនៅ

ទី*នោះ* ឬចុះមកទី*នេះ* វានៅចន្លោះនោះ។ តើមនុស្សប៉ុន្មាននាក់ដែលយល់បែបនោះ? ខ្ញុំស្គាល់អ្នក—អ្នកគិតថាអ្នកយល់។ ខ្ញុំក៏ដូច្នេះដែរ។

286 តើអ្នកស្គាល់កំណាព្យ និងព្យាការីដែលតែងតែវិកលចារិក? តើមនុស្សប៉ុន្មាននាក់ដឹងយ៉ាងនោះ?

287 ប៉ុន្មាននាក់ដែលបានអានពី វិល្លៀមខៅភឺ ជាកវីកំណាព្យអង់គ្លេសដ៏អស្ចារ្យ? អ្នកដឹង សរសេរ "មានប្រភពទឹកពេញដោយឈាម ហូរចេញពីសរសៃឈាមអេម៉ាញូអែល។" បន្ទាប់ពីសរសេរចម្រៀងនេះ តើអ្នកបានលឺអ្វីដែលកើតឡើងចំពោះគាត់? ខ្ញុំឈរក្បែរផ្នូរគាត់មិនកន្លងយូប៉ុន្មានឡើយ។ គាត់ព្យាយាមសម្លាប់ខ្លួន ហើយលង់ក្នុងទន្លេ។

288 តើមនុស្សប៉ុន្មាននាក់ដែលឮពីស្ទេហ្វិនហ្វូស្ទ័រ ដែលផ្តល់អាមេរិកចម្រៀងប្រជាប្រិយល្អបំផុតរបស់អាមេរិក? គាត់មានវានៅក្នុងដៃប៉ុន្តែមិននៅក្នុងចិត្ត។ រាល់ការជម្រុញតែងតែប៉ះដល់គាត់ គាត់អាចនិពន្ធចម្រៀងបាន។ បន្ទាប់មក ការ ជម្រុញក៏ចេញទៅ គាត់មិនដឹងថាធ្វើយ៉ាងណាជាមួយខ្លួនឯងឡើយ ហើយគាត់វង្វេង។ គាត់—គាត់—គាត់ស្រវឹង។ ហើយទីបំផុតពេលគាត់ចេញពីការ ជម្រុញ គាត់ត្រូវបានហៅថាជាអ្នកបម្រើ ហើយយកកន្ត្រៃកាត់សក់សម្លាប់ខ្លួន។ ជាការត្រឹមត្រូវ។

289 មើលអេលីយ៉ាជាព្យាការី។ គាត់ឡើងទៅហើយហៅភ្លើងពីលើមេឃហៅភ្លៀងនៅថ្ងៃដំបូង ហើយក៏បិទមេឃវិញ រួចធ្វើការទាំងនោះ។ ហើយបន្ទាប់ពីការជម្រុញចេញពីគាត់ គាត់ចេញទៅវាលរហោដ្ឋាន ហើយចង់ស្លាប់។ ហើយព្រះជាម្ចាស់មកជួបគាត់ សែសិបថ្ងៃក្រោយមក ក៏ទាញចូលទៅក្នុងរូងភ្នំវិញ។ ត្រូវទេ?

290 មើលយ៉ូណាស ព្យាការី។ បន្ទាប់ពីផ្តល់សាររបស់គាត់ គាត់ឡើងទៅហើយអង្គុយលើភ្នំ ទូលសូមព្រះជាម្ចាស់ឲ្យគាត់ស្លាប់។ អូហូ។ "សូមឲ្យអ្នកបម្រើព្រះអង្គចាកចេញទៅដោយសុខ។"

291 មនុស្សមិនយល់ឡើយ។ ទេ ទេ អ្នកនឹងមិនយល់។ ក៏មិនអាចឲ្យខ្ញុំពន្យល់ដែរ ក៏គ្មានមនុស្សណាអាចដែរ។ អ្នកមិនអាចពន្យល់ពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ក៏មិនអាចពន្យល់បានពីការស្រាវជ្រាវវិទ្យាសាស្ត្រដែរ។ ព្រះជាម្ចាស់ត្រូវបានស្គាល់ដោយជំនឿ។ យើងជឿព្រះអង្គ។ តើអ្នកអាចពន្យល់យ៉ាងណា? តើជំនឿនោះយ៉ាងណា មានទៀតទេ? យើងស្គាល់ព្រះជាម្ចាស់ដោយជំនឿ។

292 ក្រុមជំនុំនឹងមិនស្គាល់ការងារនិងការបារម្ភ កិច្ចការលំបាកនិងទុក្ខវេទនាដែលព្យាយាមនាំវា សារ។ ព្រះអង្គយល់។ រង្វាន់របស់ខ្ញុំ មិនមកពីមនុស្សឡើយ។

293 មើលមកនេះស្ត្រីអើយ។ បាទ លឿនឡើង។ ស្ត្រីនោះមានស្រមោលនៃសេចក្តីស្លាប់។ ព្រះជាម្ចាស់មិនបានមកជួបស្ត្រីនេះឡើយ ខ្ញុំអាចឃើញ...តើអ្នកឃើញភាពខ្មៅកំពុងជាប់តាមនាងទេ? នាងនឹងស្លាប់ នេះជាអ្វីដែលរបៀបលោកកិយ។ នៅទីនេះមិនជាយូប៉ុន្មាន គេថតបានរូបភាពបែបនោះ ហើយយកទៅផ្ទះ។ នាងមានស្រមោលខ្មៅតាមនាង។ នាងជាស្រមោលនៃសេចក្តីស្លាប់។

294 ស្ត្រីតូចនេះមានការវះកាត់។ ហើយនៅក្នុងការវះកាត់នេះគេវះកាត់សម្រាប់មហារីក។ ឥឡូវនាងកំពុងមានបញ្ហា គ្រប់ប្រភេទទាំង—អស់វាស្មុគស្មាញ។ រឿងមួយ អ្នកខ្សោយណាស់ អ្នកមិនអាចក្រោកឈរបានទេ។ ម្យ៉ាងទៀតមានបញ្ហាមកពីក្រពេញមានខ្ទុះ។ ឥឡូវដូច្នេះអ្នកអាចឃើញថាខ្ញុំមិនគ្រាន់តែនិយាយអ្វីៗនោះទេ។ ឃើញ? នោះជាការត្រឹមត្រូវ។ ប៉ុន្តែស្ត្រី ដុកទ័រព្យាយាម។ ខ្ញុំផ្តល់តម្លៃសម្រាប់គាត់មែន។ ប៉ុន្តែគាត់ជាថ្នាំកែរោគប៉ុន្តែព្រះជាម្ចាស់ជាអ្នកព្យាបាល។ អ្នកនឹងស្លាប់ដោយរបៀបនោះ។ គាត់ធ្វើអ្វីដែលគាត់អាចធ្វើបាន។ អ្នកជឿទេ? [បងប្អូនស្រីនិយាយ "អាម៉ែន។"—Ed។]។ មកនេះមួយនាទី។

295 ដោយបេសកកម្មដែលប្រទានមកខ្ញុំដោយព្រះមានចេស្តា ដែលធ្វើបន្ទាល់ដល់ខ្ញុំដោយទេវតាដែលឥឡូវមានវត្តមានដូចជាសរសេរភ្លើងខ្ញុំកាត់ទោសអារក្ខនេះដែលព្យាយាមយកជីវិតរបស់ប្អូនស្រី។ ដោយព្រះនាមព្រះយេស៊ូគ្រិស្ត។ អាម៉ែន។

ចូរទៅ ជឿឥឡូវ។ ជាមួយអ្វីដែលនៅក្នុងអ្នក ជឿចុះ។

296 អ្នកមានបញ្ហាដែលអាចសម្លាប់មនុស្សជាងអ្វីផ្សេងទៀត បញ្ហាបេះដូង។ គេប្រកាសថាជាជំងឺទីមួយ ប៉ុន្តែមិនមែនទេ លោក។ បាបគឺជាជំងឺលេខមួយ។ តើអ្នកជឿថា ព្រះអង្គអាចប្រោសឲ្យជាបេះដូងនេះ និង ប្រោសអ្នកឲ្យប្រសើរវិញ? [បងប្អូនប្រុស "គាត់ដឹងថាគាត់អាច"—Ed។] ដូច្នេះទៅចុះ ជឿចុះ។ សូមព្រះប្រទានពរ។

297 អ្នកគិតថាព្រះជាម្ចាស់អាចប្រោសអ្នកឲ្យជាខ្នងរបស់អ្នកនិងធ្វើឲ្យអ្នកប្រសើរឡើងវិញទេ? តើអ្នកជឿអស់ពីចិត្តរបស់អ្នកទេ? ទៅចុះ ជឿចុះ បងប្អូនស្រី។ មើលអ្វីដែលកើតឡើង អ្នកនឹងប្រសើរឡើង។

298 ជំងឺឈឺសន្លាក់ និង បញ្ហាបេះដូង។ ប៉ុន្តែអ្នកជឿថាព្រះជាម្ចាស់អាចប្រោសអ្នកឲ្យជាទេ? [បងប្អូនស្រីនិយាយ "ខ្ញុំជឿ។"—Ed។] ដោយអស់ពីចិត្ត? ["ចាស លោក។"—Ed។] អ្នកនឹងទទួល? ["ចាស លោក។"—Ed។] តាមរយៈជំនឿរបស់អ្នក នោះជារបៀបដែលនឹងសម្រេចកើតមានចំពោះអ្នក។ ឥឡូវ ទៅចុះ ជឿអស់ពីចិត្ត។ ហើយព្រះជាម្ចាស់នឹងប្រោសអ្នកឲ្យបានប្រសើរ។

299 អ្នកមានជំងឺឈឺខ្នងដែរ។ តើអ្នកជឿថាព្រះយេស៊ូគ្រិស្តអាចប្រោសអ្នកឲ្យជា? [បងប្អូនស្រីនិយាយ "ចាស លោក។"—Ed។]។ ទៅចុះ ជឿអស់ពីចិត្ត។ ខ្ញុំមិនអាចព្យាបាលអ្នកទេ ឃើញទេ។

300 ជំងឺប្រូស្តាត រន្ទត់ ហើយអ្នកក៏មានជំងឺឈឺសន្លាក់ដែរ។ តើអ្នកជឿថាព្រះជាម្ចាស់អាចប្រោសអ្នកឲ្យជា ព្យាបាលអ្នក? តើអ្នកទទួល? ទៅចុះ ហើយជឿចុះ បើដូច្នេះ។

301 មានអ្វីធ្វើឲ្យអ្នកភ្ញាក់ជានិច្ច ក្អក។ ប៉ុន្តែព្រះជាម្ចាស់បានព្យាបាលហឺត។ តើអ្នកជឿទេ? [បងប្អូនប្រុសនិយាយ "បាទ លោក។"—Ed។]។ អ្នកជឿថាព្រះអង្គប្រោសអ្នកឲ្យជា? ["បាទ លោក។"—Ed។] សូមព្រះប្រទានពរ។ អរគុណ សម្រាប់ជំនឿរបស់អ្នក។

302 តើមានអ្វីបើខ្ញុំមិននិយាយពាក្យណាមួយចំពោះអ្នក។ខ្ញុំដាក់ដៃលើអ្នក អ្នកជឿទេ? [បងប្អូនប្រុសនិយាយ "បាទ។"—Ed។]មកនេះ ខ្ញុំដាក់ដៃលើអ្នក ដោយព្រះនាមព្រះយេស៊ូគ្រិស្ត និង ឲ្យជំងឺឈឺសន្លាក់ចេញពីអ្នក។ វាត្រូវចេញ។

303 មក។ មកនេះបងប្អូនស្រី។ តើអ្នកជឿទេ? [បងប្អូនស្រីនិយាយ "ចាស លោក ខ្ញុំធ្លាប់បានប្រោសឲ្យជាពីព្រះអម្ចាស់ពីមុន"—Ed។] ល្អ នោះជាការអស្ចារ្យ។ ["ហាលេលូយ៉ា!"—Ed។] ដូច្នេះអ្នកចេញទៅបរិភោគអាហារពេលល្ងាចអ្នកចុះ ក្រពះរបស់អ្នកនឹងជា។ ["ហាលេលូយ៉ា! ហាលេលូយ៉ា! ហាលេលូយ៉ា!"]

304 មានជំងឺបញ្ហាខ្នងច្រើន វារំខានអ្នកយូរហើយ។ ទៅចុះជឿអ្នកនឹង...ទៅជឿថាអ្នកនឹងជា ហើយព្រះជាម្ចាស់នឹងធ្វើការនេះចំពោះអ្នក។ [បងប្អូនប្រុសនិយាយ "ព្រះជាម្ចាស់ធ្វើ អាម៉ែន។"—Ed។] អាម៉ែន។ នោះគឺដូច្នេះហើយ។["សរសើរព្រះអង្គ។"] សូមព្រះអម្ចាស់ប្រទានពរអ្នក បងប្អូនប្រុស។ អាម៉ែន។

305 ជំងឺទឹកនោមផ្អែមមិនជាអ្វីឡើយ សម្រាប់ព្រះជាម្ចាស់ព្យាបាល។ ព្រះអង្គអាចប្រោសវាឲ្យជា។ អ្នកជឿទេ? [បងប្អូនស្រីនិយាយ "ខ្ញុំជឿ" —Ed។] ត្រូវហើយ។ ទទួលចុះ ហើយចេញទៅ ជឿព្រះអង្គឥឡូវអស់ពីចិត្ត។

306 អ្នកមានក្នុងឈាមដែរ។ អ្នកជឿថាព្រះជាម្ចាស់នឹងប្រោសឲ្យជា? ទៅចុះ ជឿអស់ពីចិត្ត អ្នកនឹងជា។

307 អ្នកជឿថាព្រះអង្គប្រោសអ្នកឲ្យជាពីអ្វីដែលវាយលុកអ្នក? ព្រះអង្គធ្វើហើយ។

308 បញ្ហាស្ត្រី។ បញ្ហាបេះដូង។ អ្នកជឿទេ?[បងប្អូនស្រីនិយាយ "ជឿ"—Ed។] ទៅចុះ ចូរឲ្យ—បានជាក្នុងព្រះនាមព្រះយេស៊ូ។

309 អ្នកជឿថាព្រះជាម្ចាស់នឹងប្រោសខ្នងអ្នកឲ្យជា តម្រងនោមអ្នក នឹង...ព្រះប្រទានពរដល់អ្នក! ទៅចុះ។

ខ្ញុំមិនព្យាបាលទេ។ ខ្ញុំមិនអាចទេ។ ខ្ញុំមិនមែនជាអ្នកប្រោសឲ្យជាឡើយ។

310 តើអ្នកគិតយ៉ាងណាពេលគាត់និយាយពីខ្នងរបស់គាត់ តើអ្នកជឿថាអ្នកនឹងជាដែរទេ? ត្រូវណាស់ ទៅចុះ ជឿចុះ ដូច្នេះ...សូមជឿចុះ អស់ពីចិត្ត។

311 អ្នកក៏ដូចគ្នាដែរ តើអ្នកជឿថាព្រះជាម្ចាស់ប្រោសអ្នកឲ្យជាទេ? ទៅចុះ ជឿអស់ពីចិត្ត។ ព្រះជាម្ចាស់នឹងទទួលបើអ្នក...យ៉ាងណាអ្នកត្រូវតែជឿ។

312 អ្នកជឿថាព្រះជាម្ចាស់នឹងប្រោសអ្នកឲ្យជាដែរទេ? [បងប្អូនស្រីនិយាយ "សរសើរព្រះអម្ចាស់! ខ្ញុំប្រាកដជាជឿ។"—Ed។] ត្រូវណាស់។ ព្រះប្រទានពរ។ សូម ទៅចុះហើយជឿអស់ពីចិត្ត។

313 មកនេះ លោក។ ពណ៌សចាស់ដែលធ្លាក់ចុះ។ រោគសញ្ញានៃការបង្ហាញថាជាទឹកនោមផ្អែម។ [បងប្អូនប្រុសនិយាយ "ទឹកនោមផ្អែម។"—Ed។] អ្នកជឿថា ព្រះអង្គនឹងប្រោសអ្នកឲ្យជា? ចូរទៅកាល់វ៉ារីសម្រាប់ការផ្លាស់ប្តូរឈាមឥឡូវ។ ដោយជំនឿ ដោយព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត សូមឲ្យបានជា។ អាម៉ែន។ សូមព្រះប្រទានពរអ្នក បងប្អូនប្រុស។ ជឿអស់ពីចិត្តចុះ។ អ្នកជឿទេ? ["ជាការពិត។"]

314 ចុះពួកអ្នកជាអ្នកចូលរួមវិញ? តើអ្នកជឿអស់ពីចិត្ត ព្រះយេស៊ូគ្រិស្តនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ? អ្នកជឿទេ? [ក្រុមជំនុំនិយាយ "អាម៉ែន។"—Ed។]

315 ចុះនៅស្រុក*នេះ*វិញ? ស្ត្រីតូចមួយកំពុងអង្គុយ សូមមើលមកខ្ញុំ មានការរងទុក្ខផ្នែកស្ត្រី តើអ្នកជឿថាព្រះជាម្ចាស់នឹងប្រោសអ្នកឲ្យជា? មានអាវធំពណ៌ខៀវ។ ត្រូវហើយ។ ជឿឥឡូវចុះ ព្រះយេស៊ូគ្រិស្តប្រោសឲ្យបានជា។ ជារឿងធម្មតាទេ។

316 ស្ត្រីម្នាក់កំពុងអង្គុយពីក្រោយអ្នកសក់ខ្មៅ។នាងនិយាយ "អរគុណព្រះអម្ចាស់។" មានអ្វីមួយវាយមកលើនាង។ នាងមិនដឹងថាជាអ្វីឡើយ។ បញ្ហាក្រពេញកូនកណ្ដុរខាងឆ្វេង កំពុងអង្គុយនៅទីនោះ នៅពីក្រោយស្ត្រីម្នាក់ដែលទើបតែជា។ បើអ្នកជឿអស់ពីចិត្ត ស្ត្រី។ អ្នកជឿ? ត្រូវហើយ លើកដៃឡើង បើអ្នកចង់ទទួល។ ព្រះប្រោសអ្នកឲ្យបានជា។

ចុះនៅខាងក្រោមនោះ មាននរណាម្នាក់មក*ទីនេះ*?

317 អ្នកចូលរួមខាងក្រោយ ឥឡូវគោរពគ្នាបន្តិចទៅ។ កុំទៅណា។ ឃើញជំងឺនេះនឹងចេញទៅពីមួយទៅមួយ។

318 ចុះអ្នកវិញ លោក? មនុស្សវ័យច្រើននេះនៅក្នុងកៅអី? អ្នកជឿទេ? អ្នកជឿថាព្រះជាម្ចាស់អាចប្រោសអ្នកឲ្យជាទេ? ជំងឺឈឺសន្លាក់ និង រលាកទងសួត។ អ្នកជឿថាព្រះជាម្ចាស់នឹងប្រោសឲ្យបានជា? អ្នកជឿ? ត្រូវហើយ អ្នកអាចទទួលបាន អ្វីអ្នកសូម "បើអ្នកជឿ!"

319 តើអ្នកគិតយ៉ាងណា ស្ត្រីអង្គុយក្បែរគាត់? អ្នកជឿដែរទេ? អ្នកជឿទេ? អ្នកជឿថាព្រះជាម្ចាស់ប្រាប់ខ្ញុំពីបញ្ហារបស់អ្នកទេ? អ្នកនៅឆ្ងាយពីខ្ញុំ។ តែជឿឥឡូវចុះ។ អ្នកជឿថា ខ្ញុំប្រាប់អ្នកពីកាពិតបានទេ? ដូច្នេះជំងឺលើសឈាមរបស់អ្នកនឹងជា។ អ្នកជឿ?

320 អ្នកលើកដៃ ដែរ។ អ្នកព្យាយាមលើកទឹកចិត្តនាង។ អ្នកជឿថាព្រះជាម្ចាស់អាចប្រាប់ខ្ញុំពី...អ្នក ល្អណាស់ ដែលជួយនាង ឥឡូវព្រះជាម្ចាស់នឹងល្អចំពោះអ្នកដែរ។ អ្នកមានបញ្ហាខាងវិញ្ញាណដែលរំខានអ្នក។ បើនោះត្រឹមត្រូវគ្រវីដៃបែប*នេះ*។ វានឹងត្រូវបានដោះស្រាយហើយឥឡូវនេះ។ ព្រះអង្គនឹងធ្វើអ្វីឲ្យប្រសើរវិញ។

321 តើប៉ុន្មាននាក់ដែលជឿ? តើប៉ុន្មាននាក់នៃអ្នករាល់គ្នានឹងទទួល...នោះមិនមែនជាគ្រិស្ទានទេ មាន—អារម្មណ៍ថាព្រះយេស៊ូមានវត្តមាននៅទីនេះ សូមក្រោកឡើងហើយនិយាយ "ព្រះយេស៊ូ ទូលបង្គំដឹងខ្លួនថាជាមនុស្សបាប សូមព្រះអង្គអត់ទោសបាបដល់ទូលបង្គំ?" ក្រោកឈរឡើង។ ព្រះប្រទានពរ លោក។

ព្រះប្រទានពរ។ ព្រះប្រទានពរដល់អ្នក។ ព្រះប្រទានពរដល់អ្នក។ ព្រះប្រទានពរដល់អ្នក។ព្រះប្រទានពរដល់អ្នក។ នោះគឺ...ព្រះប្រទានពរអ្នក អ្នក អ្នក អ្នក។ នេះ ព្រះអង្គទតមើលអ្នក។ ព្រះអង្គប្រទានពរអ្នក។ ព្រះអង្គនឹងកត់ឈ្មោះអ្នកពេលអ្នកធ្វើដូច្នោះ។

322 ត្រង់នេះ នៅរានហាល សូមក្រោកឡើងនិយាយ "ព្រះអម្ចាស់យេស៊ូ ទូលបង្គំចង់ ចង់បានឲ្យទ្រង់ស្គាល់។ ទូលបង្គំចង់បានការសណ្ដោសសម្រាប់ព្រលឹងទូលបង្គំ"សូមព្រះប្រទានពរលោក។"ទូលបង្គំចង់បានការសណ្ដោសប្រណី ព្រះអម្ចាស់យេស៊ូ។"

323 អ្នកមិនអាចឃើញ មិត្តអើយ ព្រះអង្គគង់នៅទីនេះ? ព្រះប្រទានពរក្មេងប្រុស។ ព្រះប្រទានពរ។ ព្រះប្រទានពរស្រ្តីក្មេង។ នោះជាការអស្ចារ្យដែលអ្នកមិនធ្លាប់ធ្វើ។ ឥឡូវបើនរណាម្នាក់ធ្វើ ក្រោកឡើង ហើយនិយាយ "ទូលបង្គំចង់បានការសម្គាល់ខ្លួន ព្រះអម្ចាស់យេស៊ូ។ ទូលបង្គំសម្គាល់ខ្លួនទូលបង្គំ នៅយប់នេះ។"

324 "អ្នកដែលសារភាពបាប នឹងទទួលបានការសង្គ្រោះ។ អ្នកដែលលាក់បាប នឹងមិនចម្រើនឡើយ។"

325 តើអ្នកនឹង ក្នុងវត្តមានទ្រង់ទេ? សូមព្រះប្រទានពរ ស្ត្រី។ ខ្ញុំចង់...ព្រះប្រទានពរដល់អ្នក។ បាទ។ ហើយព្រះអម្ចាស់ប្រទានពរអ្នក។ សូមព្រះប្រទានពរអ្នកលោក ។ ព្រះប្រទានពរអ្នក ស្ត្រី។ ព្រះអម្ចាស់ប្រទានពរអ្នក។

326 អ្នកនិយាយ "តើមានន័យយ៉ាងណា?" រវាងសេចក្តីស្លាប់ និងជីវិត នោះមានភាពខុសគ្នា។

327 អ្នកសម្គាល់ពីព្រះវត្តមានព្រះអង្គនៅទីនេះឬទេ? តើអ្នកស្គាល់ទេ? អ្នកមានអារម្មណ៍ដឹងទេ? ឃើញ អ្នកឃើញទេ អ្នកឃើញវាដំណើរទេ។ នោះជាទ្រង់។ នោះជាការពិតដែលព្រះអង្គមានបន្ទូលពីអ្វីព្រះអង្គនឹងធ្វើ។អ្នកជឿទេ?[ក្រុមជំនុំនិយាយ "អាម៉ែន"—Ed។]

328 មាននរណាម្នាក់និយាយ "ខ្ញុំចង់បង្ហាញអត្តសញ្ញាណរបស់ខ្ញុំថាជាមនុស្សបាបព្រះអម្ចាស់។ សូមព្រះអង្គអត់ទោសបាបទូលបង្គំឥឡូវ។" បើអ្នកកំពុងតែឈរសូមលើកដៃរបស់អ្នក។ មានអ្នកខ្លះនៅក្បែរជញ្ជាំងងើបឡើង...សូមព្រះប្រទានពរ។ ព្រះជាម្ចាស់ប្រទានពរដល់អ្នក។ មានអ្នកខ្លះទៀតនិយាយ នៅខាងរាន

ខាងមុខអ្នកដែលនៅខាងក្រោយៗ និយាយ "ខ្ញុំចង់សម្គាល់អត្តសញ្ញាណរបស់ខ្ញុំថាជាមនុស្សបាប ព្រះអម្ចាស់យេស៊ូ ទូលបង្គំទូលសូមសេចក្តីមេត្តាប្រណី យប់នេះ ក្នុងព្រះវត្តមានព្រះជាម្ចាស់ ជឿថា មានព្រះពិតតែមួយដែលនឹងជំនុំជម្រះទូលបង្គំ ព្រះវត្តមានព្រះអង្គគង់នៅទីនេះនាឥឡូវ។ ព្រះអង្គជ្រាបថាព្រះអង្គកំពុងមានបន្ទូលមកកាន់ចិត្តទូលបង្គំនិងប្រាប់ទូលបង្គំថាទូលបង្គំខុស។ ទូលបង្គំចង់ក្រោកឡើងហើយនិយាយថាទូលបង្គំខុស។ ទូលបង្គំសារភាពថាទូលបង្គំខុស។ ព្រះអង្គកាត់ទោសទូលបង្គំ ក្នុងចិត្តទូលលបង្គំ។" នោះជាហេតុផលដែលខ្ញុំឈប់អធិស្ឋានតាមជួរ។ សូមព្រះប្រទានពរដល់អ្នក។ សូមព្រះប្រទានពរដល់អ្នក។

329 អ្នកគិតយ៉ាងណាដែលខ្ញុំឈប់? ខ្ញុំ ឈប់ព្រោះខ្ញុំដឹងថាវានឹងកើតឡើង។

330 ឥឡូវ នៅត្រង់នេះ អ្នកផ្សេងទៀត សូមអ្នកក្រោកឈរឡើង? ក្រោកឡើងហើយនិយាយអ្វីដែលកំពុងតែនិយាយទៅកាន់ចិត្តរបស់អ្នក "អ្នកខុសហើយ។" សូមព្រះប្រទានពរដល់អ្នកលោក។ សូមព្រះប្រទានពរដល់អ្នក។ សូមព្រះប្រទានពរដល់ អ្នក។សូមព្រះប្រទានពរដល់អ្នក។ "ទូលបង្គំខុសហើយ ព្រះអម្ចាស់។ ទូលបង្គំ ស្គាល់អត្តសញ្ញាណខ្លួនឯង។ ទូលបង្គំក្រោកឡើង ព្រះអម្ចាស់ ក្នុងព្រះវត្តមានព្រះអង្គ។ ទូលបង្គំដឹងថាព្រះអង្គគង់នៅទីនេះ។ ទូលបង្គំ…ព្រះអង្គយាងមកទីនេះ។ ព្រះអង្គមានបន្ទូលថានេះជាអ្វី—ដែលព្រះអង្គនឹងធ្វើ។ ឥឡូវទូលបង្គំ… ទូលបង្គំឃើញទីសម្គាល់។ហើយទូលបង្គំដឹងថាមានការពន្យល់ឲ្យដឹងថានោះជាទីសម្គាល់ សម្រាប់ថ្ងៃនេះ។ ទូលបង្គំឮសម្លេងដែលហៅឲ្យត្រឡប់ទៅកាន់ព្រះវត្តមានព្រះអង្គវិញ ទូលបង្គំនៅទីនេះ ព្រះអម្ចាស់។ ទូលបង្គំជឿទីសម្គាល់។ ទូលបង្គំឮសម្លេង។"

331 សម្លេងបាននិយាយទៅកាន់អ្នកឥឡូវនេះ! ត្រឡប់មក អូ ចេញមក! ត្រឡប់មក។ អូ ផ្កាយដ៏ស្អាតអើយ! ត្រឡប់មកវិញចុះ អូ អ្នកបានបណ្តេញចេញ! ត្រឡប់មកវិញចុះ នៅយប់នេះ!

332 តើអ្នកមិនត្រឡប់ទេឬ? សូមឈរហើយនិយាយ "ទូលបង្គំខុសហើយ ព្រះអ ម្ចាស់។ ទូលបង្គំស្គាល់អត្តសញ្ញាណខ្លួនឯង ហើយទូលសូមសម្រាប់ក្តីសណ្តោសមេត្តា។" បើអ្នកនឹងធ្វើ តើអ្នកណាទៀតធ្វើ? សូមព្រះប្រទានពរអ្នក ស្ត្រីអើយ។ ព្រះប្រទានពរដល់អ្នកនៅខាងនោះ កូនប្រុស។ បើខ្ញុំភ្លេចនរណាម្នាក់ ព្រះអង្គមិនចេះភ្លេចឡើយ។ សូមព្រះប្រទានពរ ស្ត្រីអើយ។ នោះគឺល្អណាស់។ នោះជាការល្អ

ណាស់។ មាននរណាទៀត? សូមបន្ត...ខ្ញុំចង់នៅជាងមួយនាទីទៀត ព្រោះខ្ញុំនៅមានបន្ទុកនៅត្រង់នេះនៅឡើយ ឃើញ។ មានអ្នកផ្សេងទៀត? ព្រះប្រទានពរអ្នក ស្ត្រីអើយ។ នោះជារបៀបដែលត្រូវធ្វើ។ ត្រូវតែដូច្នេះ។ មានអ្នកផ្សេងទៀត "ទូល បង្គំចង់សម្គាល់អត្តសញ្ញាណខ្លួន សូមលើកខ្លួនទូលបង្គំឡើងនិងនិយាយទូលបង្គំខុសហើយ។ ទូលបង្គំនឹងសូមសម្រាប់ក្តីមេត្តា"? តើអ្នកនឹងធ្វើ? ឆាប់ឡើងមុននឹងទៅបន្តទៀតសូមក្រើឡើងនិងនិយាយ "ទូលបង្គំចង់សម្គាល់អត្តសញ្ញាណខ្លួន ព្រះអម្ចាស់យេស៊ូ។" សូមព្រះប្រទានពរអ្នក ស្ត្រីក្មេង។

333 អ្នកដឹងទេ មុនអ្នកទៅផ្ទះ មានពេលខ្លះ ប្រហែលមានអ័ព្ទត្រជាក់លើផ្ទៃមុខរបស់អ្នក។ ប្រហែលមានព្រឹកខ្លះ ដុកទ័រនឹងមកហើយគាត់មានអារម្មណ៍ថាជីពចររបស់អ្នកដូចជាធាក់ចេញពីដៃអាវផង គ្មានអ្វីអាចជួយបាន។ រួចអ្នកមានអារម្មណ៍ថារលកនៃសេចក្តីស្លាប់អណ្តែតលើមុខរបស់អ្នក។ អ្នកចងចាំអ្វីដែលអ្នកបានធ្វើ។

334 សូមចាំ វាមិនអាចកប់អ្នកទៅក្នុងទីជម្រៅបានឡើយ វាមិនអាចធ្វើអ្វីចំពោះអ្នកបានឡើយ។ ព្រះជាម្ចាស់សន្យា "យើងនឹងលើកអ្នកឡើងសារជាថ្មី នៅថ្ងៃចុងក្រោយ។" មើល។ "អស់អ្នកដែលស្តាប់ឮពាក្យខ្ញុំនិងជឿលើព្រះអង្គដែលយើងនឹងបញ្ជូនមក អ្នកនោះមានជីវិតអស់កល្ប ហើយមិនត្រូវជំនុំជម្រះឡើយ ប៉ុន្តែគេនឹងឆ្លងផុតពីសេចក្តីស្លាប់មកឯជីវិតវិញ។" នរណាម្នាក់អាចលុបវាចេញបើអាចធ្វើបាន។ ព្រះយេស៊ូគ្រិស្តមានបន្ទូលដូច្នេះ។ "អ្នកដែលជឿហើយ ក៏យល់ពីពាក្យរបស់ខ្ញុំ និង ជឿព្រះអង្គដែលបានបញ្ជូនខ្ញុំមក នឹងមានជីវិតអស់កល្ប នឹងមិនត្រូវជំនុំជម្រះឡើយ ឬការកាត់ទោស ប៉ុន្តែនឹងឆ្លងកាត់សេចក្តីស្លាប់មកឯជីវិតវិញ។" ព្រោះអស់អ្នកដែលជឿដល់ព្រះបុត្រាតែមួយ ដែលព្រះអង្គបានលើកឡើងកាលពីពីរពាន់ឆ្នាំមុន ហើយមានព្រះជន្មដល់ឥឡូវ នៅយប់នេះ នឹងបង្ហាញពីភាពជាក់លាក់នៃការរស់ឡើងវិញរបស់ព្រះអង្គ។

335 តើមានអ្នកណាទៀតដែលក្រោកឈរ បន្ទាប់ពីនោះ មានអ្នកនិយាយថា "ខ្ញុំចង់ទទួល។ ខ្ញុំចង់ទទួលព្រះអង្គ។" សូមព្រះប្រទានពរ។ ព្រះប្រទានពរដល់អ្នក។ នោះជាការល្អណាស់ស្ត្រីអើយ។ នោះជាភាពក្លាហាន។ ខ្ញុំចង់ឲ្យអ្នកកត់សម្គាល់។

336 ខ្ញុំសម្លឹងមើលការហៅនៅអាសនា នៅត្រង់នេះជាយូមកហើយ មនុស្សបានមក ទំពារស្កកៅស៊ូ វាយគ្នានៅម្ខាងទៀត។

337 ប៉ុន្តែអ្នកសម្គាល់ឃើញថាមានភាពស្មោះត្រង់លើមុខរបស់ពួកគេទេ? ពួកគេជាស្ត្រីក្មេងៗ ទោះបីជាកាត់ទោសគេចំពោះសក់ខ្លីក៏ដោយ ការតុបតែងរបស់គេក៏ដោយ ដោយមានការតែងខ្លួនបែបនោះ ហើយសក់ខ្លី ឈរត្រង់ហ្នឹងដូចគ្នា "ខ្ញុំជាមនុស្សបាប។ សូមមេត្តាដល់ទូលបង្គំ ព្រះជាម្ចាស់អើយ។" នោះគឺមានគ្រាប់ពូជនៅត្រង់នោះ។ ពេលមានពន្លឺឈចាំងចំលើវា គ្រាប់ពូជដឹង។ សូមព្រះប្រទានពរដល់អ្នក។

សូមយើងឱនក្បាលចុះឥឡូវ។

338 ខ្ញុំចង់ឲ្យអ្នកជឿទាំងអស់នៅទីនេះ ដែលឈរក្បែរមនុស្សឈរនោះ ដាក់ដៃលើគាត់ (អ្នកធ្វើទេ?) អ្នកដែលឈរ។ គេឈរក្បែរអ្នក។ បើអ្នកជាគ្រិស្តបរិស័ទ សូមដាក់ដៃលើគាត់ លើបងប្អូនស្រី បងប្អូនប្រុស "ខ្ញុំដាក់ដៃលើអ្នកឥឡូវ។ ខ្ញុំនឹងអធិស្ឋាន។"

339 ព្រះបិតាដែលគង់នៅស្ថានសួគ៌មានអ្នកទាំងអស់នៅយប់នេះ—ដែលជឿព្រះអង្គ។ "មានគ្រាប់ពូជខ្លះដែលធ្លាក់នៅតាមផ្លូវ" ព្រះអង្គមានបន្ទូល "មានបក្សីមកហើយប្រមូលយកទៅ។ មានខ្លះធ្លាក់នៅលើថ្ម ហើយបន្លានិងដើមបន្លា។ ប៉ុន្តែខ្លះធ្លាក់នៅលើដីដែលល្អ ជាដីមានជីជាតិ។" ហើយព្រះវត្តមានព្រះអង្គគង់នៅទីនេះ យប់នេះ បានបញ្ចុះបញ្ចូលមនុស្សជាច្រើននៅយប់នេះដែលព្រះអង្គជាព្រះបុត្រារបស់ព្រះ ហើយព្រះអង្គមានព្រះជន្មរៀងរហូតទៅ។ ហើយព្រះអង្គសន្យាព្រោះព្រះអង្គមានព្រះជន្មរស់ ទូលបង្គំក៏អាចរស់ដែរ។

340 ព្រះអម្ចាស់យេស៊ូ ពួកគេក្រោកឡើងហើយឈរជាទីបន្ទាល់ថាពួកគេជឿដល់ព្រះអង្គ។ ឥឡូវ ព្រះអម្ចាស់ ទូលបង្គំដឹងថាព្រះអង្គធ្វើឲ្យគេក្រោកឈរសម្រាប់ថ្ងៃចុងក្រោយ។ សូមទទួលយក ព្រះអម្ចាស់។ ទូលបង្គំថ្វាយពួកគេដល់ព្រះអង្គ ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ សូមឲ្យពួកគេទៅកាន់ក្រុមជំនុំល្អ និង ជ្រមុជទឹកក្នុងគ្រិស្តបរិស័ទ។ សូមឲ្យពួកគេចូលរួមក្រុមមនុស្សអ្នកជឿដែលល្អ។ សូមឲ្យពួកគេបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ សូមឲ្យពួកគេជាជ័យភ័ណ្ឌនៃដំណឹងល្អជាត្បូងក្នុងមកុដនាថ្ងៃចុងក្រោយ។ ហើយបើទូលបង្គំមិនបានជួបពួកគេម្តងទៀត សូមឲ្យទូលបង្គំបានឃើញគេនៅថ្ងៃនោះដូចក្នុងនិមិត្ត ដែលនិយាយថា "តើអ្នកមិនស្គាល់ខ្ញុំទេ? ខ្ញុំនៅឯ បាតុនរ៉ូ នៅយប់នោះ ខ្ញុំក្រោកឈរ។" សូមទទួលយក ឱព្រះបិតា។ ពួកគេជារបស់ព្រះអង្គ ដោយព្រះនាមព្រះគ្រិស្ត។

341 នៅត្រង់នេះ នៅពីមុខខ្ញុំ មានប្រអប់នៃកូនកន្សែង ស្បែកជើងតូចៗ ស្បែកជើងប៊ូត កន្សែងដៃ និង ក្រណាត់ទ្រនាប់។ យើងធ្លាប់រៀនមក ក្នុងព្រះគម្ពីរ ដែលពួកគេយកពីរាងកាយរបស់សាវកប៉ូល កន្សែងដៃ វិញ្ញាណអាក្រក់ក៏ចេញពីមនុស្ស។ ឥឡូវសូមព្រះបិតា ទូលបង្គំស្គាល់ថាទូលបង្គំមិនមែនជាសាវកប៉ូល ប៉ុន្តែព្រះអង្គនៅតែជាព្រះដដែល ហើយទូលបង្គំក៏អធិស្ឋានថាព្រះអង្គនឹងអនុញ្ញាតិឲ្យមានលទ្ធផលដដែល ដោយព្រោះសេចក្តីស្មោះត្រង់ជំនឿរបស់មនុស្សជំនាន់នេះ។ ពួកគេមិនដែលជាប៉ូលដោយព្រោះគាត់ជាប៉ូល ពួកគេជឿប៉ូលព្រោះព្រះអង្គ មានអត្តសញ្ញាណព្រះអង្គជាមួយប៉ូល។ ឥឡូវពួកគេជឿនៅយប់នេះដូចគ្នានៅយប់នេះ ព្រះអម្ចាស់ ដែលព្រះអង្គសម្គាល់ព្រះអង្គទ្រង់ក្នុងចំណោមយើង យប់នេះ។ ហើយនៅថ្ងៃណាមួយ យើងនឹងនិយាយ...

342 មានអ្នកនិពន្ធម្នាក់ប្រាប់យើងថា "អ៊ីស្រាអែលគឺតាមផ្លូវនៃសេចក្តីសន្យាដែលជាទឹកដីសន្យា និង សមុទ្រក្រហមក៏នៅក្នុងផ្លូវនោះដែរ ដើម្បីកាត់ពួកគេចេញពីទឹកដីសន្យា។" អ្នកនិពន្ធសរសេរ ថា "ព្រះជាម្ចាស់ទតមើលពីបង្គោលភ្លើងសសរដោយព្រះនេត្រក្រោធ ពេលដែលវាឆ្លងអ៊ីស្រាអែល។ វាបង្កើតភាពងងឹត ភាពងងឹតទៅកាន់អ្នកមិនជឿ ហើយមានពន្លឺទៅកាន់អ៊ីស្រាអែល។ ហើយពេលសមុទ្រក្រហមមកកាត់ផ្លូវវាបង្ករឲ្យមាន ការភ័យខ្លាច ក៏រមូរចង់ថយក្រោយវិញនិងអ៊ី ស្រាអែល ឆ្លងផុតចូលទឹកដីសន្យាដោយដីស្ងួត។"

343 ព្រះជាព្រះអម្ចាស់ សូមទតមកយប់នេះ តាមរយៈព្រះលោហិតព្រះយេស៊ូគ្រិស្តជាព្រះបុត្រាព្រះអង្គ។ កាលបើទូលបង្គំដាក់ដៃលើកន្សែងដៃទាំងនេះ ពេលគេដាក់លើអ្នកជំងឺ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធ ព្រះអម្ចាស់ សូមទតមើលមនុស្សទាំងនោះ ហើយសូមឲ្យជំងឺចេញពីគេ ហើយឲ្យពួកគេចូលទៅកាន់ទឹកដីនោះ និង មានសុខភាពល្អ។ នោះ ព្រះគម្ពីរនិយាយ "លើសទាំងអស់" ដែលពួកគេប្រាថ្នាដែលយើង "មានការចម្រុងចម្រើនផ្នែកសុខភាព" សូមទទួលយក ព្រះអម្ចាស់អើយ។ ទូលបង្គំបញ្ជូនទៅ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត។ អាម៉ែន។

...ខ្ញុំនឹងដើរតាម<br>
កន្លែងណាដែលទ្រង់នាំទៅ...(សូមច្រៀង)...ខ្ញុំនឹងដើរតាម<br>
ខ្ញុំនឹងទៅជាមួយព្រះអង្គ (ឥឡូវព្រះវត្តមានព្រះអង្គគង់នៅ<br>
ទីនេះ ចូរយើងថ្វាយបង្គំព្រះអង្គជាមួយបទចម្រៀង

ផ្អែមល្ហែម) គ្រប់ផ្លូវ។

344 អ្នកអាចច្រៀងបែបនេះ?

កន្លែងណាដែលទ្រង់នាំទៅខ្ញុំនឹងដើរតាម
កន្លែងណាដែលទ្រង់នាំទៅខ្ញុំនឹងដើរតាម
កន្លែងណាដែលទ្រង់នាំទៅខ្ញុំនឹងដើរតាម
ខ្ញុំនឹងទៅ(បើអ្នកនឹងធ្វើ សូមលើកដៃ) ជាមួយ ព្រះអង្គ គ្រប់ផ្លូវ។

ចូរក្រោកឡើង លើកដៃម្ដងទៀត។

...ជាមួយព្រះអង្គក្នុងសួន

345 សូមទាំងអស់គ្នាច្រៀងក្នុងវិញ្ញាណឥឡូវ។ ជាសារចាក់ដោតពិតប្រាកដ។ សូមថ្វាយបង្គំព្រះអង្គក្នុងព្រះវត្តមានព្រះអង្គ។ ព្រះអង្គសព្វព្រះទ័យឲ្យយើងថ្វាយបង្គំ។

...សួនច្បារ
ខ្ញុំនឹងតាមព្រះអង្គដើរកាត់សួន
ខ្ញុំនឹងទៅតាមព្រះអង្គ តាមព្រះអង្គគ្រប់ផ្លូវ។

346 ឥឡូវសូមច្រៀងវា។ "ខ្ញុំអាច..." ឥឡូវពេលធ្វើបែបនេះ ខ្ញុំចង់ឲ្យអ្នកអង្រួនដៃជាមួយអ្នកផ្សេងទៀត និយាយ "សូមព្រះប្រទានពរ អ្នករួមទាំអស់" បែបនោះ។ យើងរួមគ្នាតែមួយជាមួយគ្នា។ មេតូឌីស្ត និង បាបទីស្ត ព្រីសប៊ីធីរៀន ពេនទីកុស្ត ទាំងអស់គ្នាចាប់ដៃអង្រួនទៅវិញទៅមក។ "សូមព្រះប្រទានពរដល់អ្នក ដើរព្យុះហយាត្រា។" គឺយើងទាំងអស់គ្នា: អ្នកដើរក្បួន។

...សួនច្បារ

347 សូមព្រះប្រទានពរអ្នក អ្នកដើរព្យុះហយាត្រា។ សូមព្រះប្រទានពរ បងប្អូនប្រុសប្រានហាំនិងក្រុមជំនុំបន្តចាប់ដៃអង្រួន។ចំណុចទទេខ្សែរអាត់សម្លេង —Ed។]

...សួនច្បារ

ឥឡូវចូរលើកដៃអ្នកឡើង

ខ្ញុំនឹងដើរតាមព្រះអង្គ ជាមួយព្រះអង្គជាផ្លូវ។

348 សូមយើងឱ្យនក្បាលចុះ ដោយបន្ទាបខ្លួន ក្នុងសេចក្តីអធិស្ឋាន។ កុំភ្លេច ក្នុងពេលព្រឹក ថ្នាក់ថ្ងៃអាទិត្យ។

349 ដោយរបៀបណា ឬ ផ្សេងទៀត ខ្ញុំមានអារម្មណ៍ដឹងពីវត្តមានព្រះជាម្ចាស់ពិតណាស់ក្នុងចិត្តខ្ញុំ។ វាពិបាកណាស់ដែលឲ្យខ្ញុំចេញទៅ យប់នេះ ទោះរបៀបណាក៏ដោយ។ ខ្ញុំមានអារម្មណ៍ថាព្រះវិញ្ញាណបរិសុទ្ធសព្វព្រះទ័យ យប់នេះ។ យើងប្រហែលមានការជួបយ៉ាងអស្ចារ្យមួយនៅថ្ងៃស្អែក មើលមនុស្សដែលមកកាន់ព្រះជាម្ចាស់ អ្នកឃើញទេ។ មានអ្នកខ្លះយល់ថាហេតុអ្វីបានជាខ្ញុំមិនធ្វើការហៅពីអាសនា។ ខ្ញុំរងចាំរហូតដល់ខ្ញុំទទួលបានការដឹកនាំឲ្យធ្វើ។ ឃើញទេ?

350 ខ្ញុំទុកចិត្តថា គ្រប់គ្នាដែលលើកដៃ ឬក្រោកឡើង ខ្ញុំទុកចិត្តថាអ្នកនឹងមកព្រះវិហារនៅថ្ងៃស្អែក មកយកកន្លែងក្នុងចំណោមអ្នកជឿ។

351 ពេលអ្នកកំពុងឱ្យនក្បាលនឹងសួរគ្រូគង្វាលនៅទីនេះមកខាងមុខ បើគាត់អាច សូមបំបែកគ្នា។ សូមព្រះប្រទានពរដោយឱ្យនក្បាលនិងចិត្តពីមុខព្រះជាម្ចាស់។

**សម្លេងនៃទីសម្គាល់** KHM64-0321E

(The Voice Of The Sign)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាច ថ្ងៃសៅរ៍ ថ្ងៃទី 21 មិនា 1964 នៅវិទ្យាល័យ Denham Springs, Denham Springs, Louisiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2020 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org